# ទស្សនាវដ្ដី គន្លឹះអប់រំ

លេខ ២, ២៥ សីហា ២០២៦








- STEM និងបាតុភូតៈ ចន្ទគ្រាស និង ព្រះចន្ទក្រហម
- ការបង្កើនប្រសិទ្ធិភាពនៃបណ្ណាល័យសាលារបស់អ្នក
- ការធ្វើទំនើបកម្មការអប់រំមធ្យមសិក្សានៅកម្ពុជាតាមរយៈបញ្ញាសិប្បនិម្មិត៖ បញ្ញាប្រឈម និងកាលានុវត្តភាព

សហការផលិតដោយ៖
អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា
NGS INTERNATIONAL SECRETARIAT

ទស្សនាវដ្ដីនេះត្រូវបានចែករំលែកក្រោមអាជ្ញាប័ណ្ណ គ្រីអេធីវ ខាំមិនស៍ (Creative Commons)

CC BY-NC-ND 4.0

**Attribution-NonCommercial-NoDerivatives 4.0 International**

អាជ្ញាប័ណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់បន្តចម្លង និងចែកចាយឯកសារគ្រប់ទម្រង់ ឬ មធ្យោបាយណាមួយ ក្នុង ***ទម្រង់ដែលគ្មានការកែប្រែតែប៉ុណ្ណោះ*** សម្រាប់ គោលបំណងមិនមែន ពាណិជ្ជកម្ម និង ***លុះត្រាតែមានការផ្ដល់ក្រេឌីត*** ដល់ស្ថាបនិក។

តាមរយៈ CC BY-NC-ND រួមបញ្ចូលធាតុដូចខាងក្រោម៖

**BY (ការផ្ដល់ក្រេឌីត)៖** ត្រូវផ្ដល់ក្រេឌីតដល់ស្ថាបនិក ពេលគឺអ្នកនិពន្ធដែលបានចុះបញ្ជី ជាមួយអត្ថបទនីមួយៗ និងជាមួយអង្គការ ***សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា* (KAPE)** ។

**NC (មិនមែនពាណិជ្ជកម្ម)៖** អនុញ្ញាតឱ្យប្រើប្រាស់ស្នាដៃនេះសម្រាប់តែ *គោលបំណងមិនមែនពាណិជ្ជកម្ម* ប៉ុណ្ណោះ។

**ND (មិនមានការកែប្រែ ឬសម្រួលលើស្នាដៃដើម)៖** *មិនអនុញ្ញាត* ឱ្យមានការបង្កើតស្នាដៃកែច្នៃ ឬកែសម្រួលលើខ្លឹមសារណាមួយនៃស្នាដៃដើមឡើយ។

**ដើម្បីសុំសិទ្ធិក្នុងការបកប្រែ សូមទាក់ទងមកអង្គការខេប (KAPE)**

**តំណភ្ជាប់៖** https://creativecommons.org/licenses/by-nc-nd/4.0/

យើងខ្ញុំចង់កែលម្អកិច្ចការរបស់ខ្លួនឱ្យកាន់តែល្អប្រសើរបន្ថែមទៀត!

ទស្សនាវដ្ដីនេះគឺជាការសាកល្បង។ សម្រាប់លេខបន្ទាប់ដែលយើងនឹងចេញផ្សាយនៅខែមិថុនា ឆ្នាំ២០២៦ យើងនឹងយកមតិកែលម្អរបស់អ្នកមកពិចារណា។

សូមប្រាប់យើងខ្ញុំឱ្យបានដឹង ប្រសិនបើមានប្រធានបទមួយចំនួនដែលអ្នកចង់ឱ្យយើងលើកយកមកបង្ហាញ ឬសំណូមពរផ្សេងៗដែលអ្នកចង់ចែករំលែក។

អ្នកមិនចាំបាច់អានទស្សនាវដ្ដីទាំងមូលដើម្បីបញ្ចេញមតិនោះទេ។

គ្រាន់តែស្កេនកូដ QR ឬចុចលើតំណភ្ជាប់។

**តំណភ្ជាប់៖** https://forms.gle/QZjQfER2iuKrKDWx5

# មាតិកា




## អំពីទស្សនាវដ្ដី

- ទំព័ររក្សាសិទ្ធិ *i*
- មាតិកា *ii*

## សាលប្រជុំ

- ការផ្ដល់ឱកាសទី២ សង្គ្រោះអាជីព ០១

## ការិយាល័យអ្នកប្រឹក្សា

- Magic Approach និងវិធីបង្រៀនក្នុងមុខវិជ្ជាគណិតវិទ្យា ០៤
- ការចុះជួយគាំទ្រ និងបន្ទុករបស់គ្រូបង្រៀនថ្មី ០៧
- ការអំពាវនាវរកសំណួរ ១០

## គិលានដ្ឋាន

- សេវាថែទាំសុខភាពបឋមប្រចាំសាលា ១១

## ផ្នែកភាសា

- ពីការបង្រៀនភាសាអង់គ្លេសបែប សប្បាយៗ ទៅជាការប្រើប្រាស់ភាសា៖ វិធីពីរយ៉ាងក្នុងការប្រើប្រាស់សម្ភារៈយថាភូតក្នុងថ្នាក់រៀន មាតិកា ១៥

## ជ្រុងមួយនៃបណ្ណាល័យ

- ការបង្កើនប្រសិទ្ធភាពនៃបណ្ណាល័យសាលារបស់អ្នក ២០
- ជំនឿមិនពិតដែលពេញនិយមបំផុតអំពីការរៀនសូត្រ និងការអប់រំ ២៤
- កំណត់សម្គាល់អំណាន (បោះពុម្ពលើកទី២) ២៧

## ភាពជាអ្នកដឹកនាំ

- ភាពជាអ្នកដឹកនាំក្នុងបរិបទនៃភាពចម្រូងចម្រាស៖ យុទ្ធសាស្ត្រឈ្នះ-ឈ្នះ ដើម្បីគ្រប់គ្រងឥទ្ធិពលអវិជ្ជមានក្នុងសាលារៀន ៣០

## បន្ទប់ប្រជុំ

- ការកសាងសហគមន៍សិក្សាសម្រាប់គ្រូបង្រៀននៅក្នុងសាលា៖ ជំហានងាយៗដើម្បីឱ្យសហគមន៍សិក្សាដំណើរការ ៣២

## បន្ទប់គ្រូបង្រៀន

- ការជួយក្មេងស្រីខ្វះភាពកក់ក្ដៅក្នុងគ្រួសារ ៣៦






## សួនកុមារ


- ល្បែងសិក្សារបស់គីម ៤០
- ល្បែងសម្លឹងកែរភ្នែក ៤១
- ខ្សឹបជាភាសាចិន ៤២
- ល្បែងសិក្សាគណិតវិទ្យា ៤៣
- គុណរហ័ស ៤៤


## មន្ទីរពិសោធន៍ព័ត៌មានវិទ្យា និងទូរគមនាគមន៍


- ការធ្វើបរិវត្តកម្មការអប់រំមធ្យមសិក្សានៅកម្ពុជាតាមរយៈបញ្ញាសិប្បនិម្មិត៖ បញ្ហាប្រឈម និងកាលានុវត្តភាព ៤៥


## មន្ទីរពិសោធន៍វិទ្យាសាស្ត្រ


- ការពិសោធន៍ដ៏ត្រឹមត្រូវ ៤៩
- ការស្វែងរកឧទាហរណ៍នៃការពិសោធន៍ ៥១


## សួនច្បារ


- STEM និងបាតុភូត «ចន្ទគ្រាស និង ព្រះ ៥៤


## ក្តារខៀនព័ត៌មាន


- Announcement CICME ៥៧


## ម៉ាស៊ីនកាហ្វេ


- របៀបបង្រៀន អ្វីមួយដែលមិនមានសោះ
- វិន័យ និងភាពខុសគ្នាខាងវប្បធម៌ ៥៨



## អ្នកចូលរួមចំណែកក្នុងទស្សនាវដ្តីគន្លឹះអប់រំ ៥៩




# សាលប្រជុំ

ដោយ៖ បណ្ឌិត ស៊ុន សុម៉ារ៉ា

# ការផ្តល់ឱកាសទី២ សង្គ្រោះអាជីព

## A SECOND CHANCE, SAVE THE PROFESSION

ក្នុងពិភពនៃការអប់រំដែលពោរពេញដោយការប្រគួតប្រជែង សម្ពាធ និងការរំពឹងទុកខ្ពស់ ការមានចំណេះដឹងតែម្យ៉ាងគឺមិនទាន់គ្រប់គ្រាន់ឡើយ។ រឿងរ៉ាវពិតដែលស្តែងចេញពីបទពិសោធរបស់ «លោកគ្រូដារ៉ា» គឺជាមេរៀនជីវិតដ៏មានតម្លៃសម្រាប់អ្នកដឹកនាំសាលារៀនគ្រប់រូប អំពីអានុភាពនៃការផ្តល់ឱកាស និងការចេះសម្លឹងមើលសក្តានុពលដែលលាក់កំបាំងក្រោមភាពខ្វះចន្លោះនៃបទពិសោធ។

### ពីភាពអស់សង្ឃឹម មកជាពន្លឺនៃក្តីសង្ឃឹម

ដើមឡើយ លោកគ្រូដារ៉ាគឺជាគ្រូបង្រៀនភាសាអង់គ្លេសដែលទើបបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រអប់រំ ឯកទេសការបង្រៀនភាសាអង់គ្លេសថ្មីថ្មោង ប្រកបដោយឆន្ទៈ និងចំណេះដឹងខ្ពស់គួរសម។ ប៉ុន្តែ ការពិតនៃថ្នាក់រៀនជាក់ស្តែងបានផ្តល់មេរៀនយ៉ាងចាស់ដៃដល់រូបគាត់។

ដោយសារខ្វះជំនាញគ្រប់គ្រងថ្នាក់រៀន វិធីសាស្ត្របង្រៀនរបស់គាត់មិនទទួលបានការគាំទ្រពីសិស្សានុសិស្សនោះទេ រហូតឈានដល់មាន ការដាក់លិខិតតវ៉ាទៅកាន់គណៈគ្រប់គ្រងសាលារៀនថែមទៀតផង។ ក្នុងវិនាទីនោះ ពិភពលោករបស់គ្រូបង្រៀនម្នាក់នេះហាក់ដួលរលំ ភាពអស់សង្ឃឹមបានចូលមកជំនួស ហើយការបោះបង់អាជីព គឺជាជម្រើសតែមួយគត់ដែលគាត់បានគិតឃើញនៅពេលនោះ។

ប៉ុន្តែ សំណាងល្អដែលសាលារៀននោះមានអ្នកដឹកនាំប្រកបដោយមេត្តាធម៌ និងវិជ្ជាជីវៈ គឺ លោកនាយកសុវណ្ណ។ ជំនួសឱ្យការស្តីបន្ទោស ឬការបញ្ឈប់ការងារ លោកនាយកបានប្រើប្រាស់យុទ្ធសាស្ត្រ «វិនិច្ឆ័យដោយភស្តុតាង និង ការតម្រង់ទិស» ដូចខាងក្រោមជំនួសវិញ៖

១) លោកនាយកមិនសម្រេចចិត្តតាមតែពាក្យបណ្តឹងតវ៉ារបស់សិស្សានុសិស្សឡើយ ប៉ុន្តែលោកបានចុះសង្កេតថ្នាក់រៀនដោយផ្ទាល់ដើម្បីស្វែងរកចំណុចខ្លាំង និចំណុចខ្វះខាតដែលគួរកែលម្អពិតប្រាកដ។

២) លោកនាយកបានណែនាំឱ្យលោកគ្រូដារ៉ាចុះសង្កេតថ្នាក់រៀនរបស់សហការីជើងចាស់ម្នាក់ ដែលមានបទពិសោធបង្រៀនយូរឆ្នាំ ដើម្បីរៀនសូត្រពីរបៀបគ្រប់គ្រងថ្នាក់រៀន។

៣) លោកនាយកក៏បានផ្តល់មតិត្រឡប់បែបស្ថាបនា ដែលជួយជំរុញឱ្យលោកគ្រូដារ៉ាកែលម្អចំណុចខ្វះខាតបន្តិចបន្តួចបន្ថែមលើការគ្រប់គ្រងថ្នាក់រៀន។

រូបភាពរចនាដោយ Google Gemini



ជាលទ្ធផលនៃ«ឱកាសទី២»នេះ បានផ្លាស់ប្តូរវាសនារបស់លោកគ្រូដារ៉ាទាំងស្រុង។ គាត់មិនត្រឹមតែទទួលបានការគាំទ្រពីសិស្សានុសិស្សវិញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានក្លាយជាគ្រូបង្រៀនដ៏ជោគជ័យម្នាក់ថែមទាំងដែលបន្តបេសកកម្មអប់រំនៅតាមសាកលវិទ្យាល័យនានាមិនថាទាំងរាជធានីភ្នំពេញ និងតាម បណ្តាខេត្តមួយចំនួនផងដែរ។

## បន្តវេននៃមេត្តាធម៌៖ យុទ្ធសាស្ត្រសង្គ្រោះអាជីពសហការី

ច្រើនឆ្នាំកន្លងផុតទៅ កង់ប្រវត្តិសាស្ត្របានវិលមកជួបនឹងករណីស្រដៀងនឹងបទពិសោធរបស់គាត់ ម្តងទៀត នៅពេលលោកគ្រូដារ៉ាបានក្លាយជានាយកសាលារៀនឯកជនមួយ។ គាត់បានជួបនឹង លោកគ្រូ ប៊ុនធឿន ដែលជាគ្រូបង្រៀនម្នាក់មានប្រវត្តិការងារមិនសូវល្អពីកន្លែងការងារចាស់របស់គាត់ (ធ្លាប់ត្រូវបានបញ្ចប់កិច្ចសន្យា និងរងការរិះគន់លើអាកប្បកិរិយា)។ ក្នុងនាមជាអ្នកដឹកនាំ លោកនាយកដារ៉ាបានឈរលើគោលការណ៍«ការផ្តល់ឱកាស គឺជាការសង្គ្រោះអាជីព» ព្រោះគាត់យល់ច្បាស់ពីតម្លៃនៃឱកាសដែលគាត់ធ្លាប់ទទួលបានពីមុនមក។ លោកនាយកដារ៉ាមិនបានសម្រេចចិត្តដោយអារម្មណ៍ឡើយ ប៉ុន្តែគាត់បានអនុវត្តតាមជំហានវិជ្ជាជីវៈ ដូចខាងក្រោម៖

១) **ភាពច្បាស់លាស់នៃលក្ខខណ្ឌ** (Probation with Terms)៖ ផ្តល់ឱកាសឱ្យសាកល្បងការងាររយៈពេល៣ខែ ជាមួយនឹងលក្ខខណ្ឌកែលម្អអាកប្បកិរិយា និងវិជ្ជាជីវៈឱ្យបានល្អប្រសើរ។

២) **ការលើកចិត្តចំពោះគំនិតច្នៃប្រឌិត៖** លោកនាយកបានទទួលយកគម្រោងផែនការ «បង្កើតបរិយាកាសនិយាយភាសាអង់គ្លេស» សម្រាប់សិស្សអនុវត្តបំណិននិយាយភាសាអង់គ្លេសរបស់ពួកគេក្នុងបរិវេណសាលារៀនរបស់លោកគ្រូប៊ុនធឿន (ដែលគម្រោងនេះ ធ្លាប់ត្រូវបានបដិសេធពីកន្លែងចាស់)។




៣) **ការផ្តល់វេទិកាបង្ហាញសមត្ថភាព៖** អនុញ្ញាតឱ្យលោកគ្រូប៊ុនធឿនបានបញ្ចេញសក្តានុពលរបស់ខ្លួនបានពេញលេញក្នុងការដឹកនាំគម្រោងផ្សេងៗទៀតនៅក្នុងសាលារៀន។ ជាលទ្ធផលដ៏អស្ចារ្យ លោកគ្រូប៊ុនធឿនបានកែប្រែខ្លួនឯងក្លាយជាបុគ្គលិកឆ្នើម និង ឈានជើងចូលក្នុងជួរគណៈគ្រប់គ្រងសាលារៀនថែមទៀតផង។




## អនុសាសន៍សម្រាប់អ្នកដឹកនាំសាលារៀន៖ «ពន្លឺនៃចិត្តបើកគន្លឹះបេះដូង»

សាច់រឿងខាងលើបានផ្តល់នូវអាវុធយុទ្ធសាស្ត្រ និង ការបំផុសគំនិតសម្រាប់អ្នកដឹកនាំអប់រំគ្រប់រូប៖

១) **កុំវិនិច្ឆ័យមនុស្សត្រឹមតែក្រដាសមួយសន្លឹក៖** របាយការណ៍អវិជ្ជមានពីអតីតកាល អាចកើតចេញពីបរិយាកាសការងារមិនអំណោយផល ឬ កង្វះការតម្រង់ទិស។

២) **មេត្តាធម៌អមដោយវិន័យ៖** ការផ្តល់ឱកាសមិនមែនជាការបណ្តោយខ្លួនឡើយ ប៉ុន្តែគឺជាការកំណត់ព្រំដែនឱ្យកែខ្លួនក្នុងរយៈពេលជាក់លាក់ណាមួយ។

៣) **សាងវប្បធម៌នៃការរៀនសូត្រ៖** ការជួយឱ្យគ្រូបង្រៀនបានរៀនសូត្រពីគ្នាទៅវិញទៅមក គឺជាវិធី សាស្ត្រអភិវឌ្ឍបុគ្គលិកដែលចំណាយតិច តែមានប្រសិទ្ធភាពខ្ពស់។

សរុបជារួមមក «ការផ្តល់ឱកាសទី២» មិនត្រឹមតែជាការជួយសង្គ្រោះអាជីពរបស់មនុស្សម្នាក់នោះទេ ប៉ុន្តែវាគឺជាការសាបព្រោះគ្រាប់ពូជនៃមេត្តាធម៌ និងវិជ្ជាជីវៈនៅក្នុងប្រព័ន្ធអប់រំ។ ក្នុងនាមជាអ្នកអប់រំ ចូរចងចាំថា ការផ្តល់ពន្លឺដល់ចិត្ត និងការបើកគន្លឹះបេះដូងសហការី នឹងបង្កើតបាននូវអនាគតដ៏ភ្លឺស្វាងសម្រាប់ទាំងគ្រូបង្រៀន និងសិស្សានុសិស្សជំនាន់ក្រោយ។

# ការអំពាវនាវរកការចូលរួមចំណែក
# (Call for Contributions)



អ្នកប្រហែលជាបានចាប់អារម្មណ៍ឃើញឈ្មោះអ្នកនិពន្ធថ្មីៗ មួយចំនួននៅក្នុងព្រឹត្តិបត្រ «គន្លឹះអប់រំ» ច្បាប់នេះរួចមកហើយ។ ប៉ុន្តែ យើងនៅតែបន្តស្វែងរកសមាជិកបន្ថែមដើម្បីពង្រីកក្រុមការងាររបស់យើង។ យើងនឹងបន្តបោះពុម្ពផ្សាយពីរដងក្នុងមួយឆ្នាំ។ យើងទទួលយកការចូលរួមចំណែកគ្រប់ពេលវេលា ប៉ុន្តែសូមចងចាំថា ដំណើរការទាំងមូលនៃការពិនិត្យកែសម្រួល និងការគ្រប់គ្រងគុណភាពអាចនឹងត្រូវចំណាយពេលយូរគួរសម អាស្រ័យលើគុណភាពនៃសេចក្ដីព្រាងដំបូង ។ ហេតុនេះ ប្រសិនបើអ្នកចង់ឱ្យអត្ថបទរបស់អ្នកត្រូវបានបោះពុម្ពផ្សាយក្នុងលេខណាមួយជាក់លាក់នៃទស្សនាវដ្ដីនេះ អ្នកគួរតែផ្ញើសេចក្ដីព្រាងរបស់អ្នកយ៉ាងហោចណាស់ ២ ខែ មុនពេលកំណត់នៃការបោះពុម្ពផ្សាយ។ ច្បាប់ផ្សាយបន្ទាប់នឹងចេញផ្សាយនៅក្នុង ខែមករា និងខែកក្កដា ឆ្នាំ២០២៧។ ពិតណាស់ យើងនឹងរួមដំណើរជាមួយអ្នកពេញមួយដំណើរការនេះ និងជួយអ្នកក្នុងការកែលម្អស្នាដៃរបស់អ្នក។

យើងបើកចំហក្នុងការទទួលរាល់ការចូលរួមចំណែកគ្រប់ទម្រង់ ជាពិសេស៖

- អ្នកនិពន្ធ ដើម្បីសរសេរអត្ថបទសម្រាប់ផ្នែក/ជួរឈរផ្សេងៗ (សូមមើលតំណភ្ជាប់ខាងក្រោម)
- អ្នកសម្ភាស ដើម្បីជួបជុំជាមួយអ្នកអប់រំដែលបង្កើតការបំផុសគំនិតនៅក្នុងវិស័យនេះ និងប្រមូលព័ត៌មានពីពួកគាត់
- អ្នកថតរូប ដើម្បីរួមដំណើរជាមួយអ្នកសម្ភាស
- អ្នកត្រួតពិនិត្យអក្ខរាវិរុទ្ធ (Proofreaders) ដើម្បីពិនិត្យវេយ្យាករណ៍ និងអក្ខរាវិរុទ្ធ ព្រមទាំងធានាគុណភាពនៃទស្សនាវដ្ដី
- អ្នករចនាក្រាហ្វិក (Graphic designers) ដើម្បីជួយអ្នកនិពន្ធក្នុងការបង្កើតរូបភាព និងកែលម្អប្លង់ទូទៅនៃទស្សនាវដ្ដីឱ្យកាន់តែប្រសើរឡើង

សម្រាប់បញ្ជីពេញលេញនៃផ្នែក/ជួរឈរ (Rubrics) និងការណែនាំសម្រាប់អ្នកនិពន្ធ សូមស្កេនកូដ QR ឬចុចលើតំណភ្ជាប់៖

https://drive.google.com/drive/folders/15tc-n1pE4112WlrLbkUEtkNO5GkKOxQn?usp=drive_link

ប្រសិនបើអ្នកមានចំណាប់អារម្មណ៍ សូមផ្ញើមកយើងនូវ

- ព័ត៌មានទំនាក់ទំនងរបស់អ្នក
- ទីតាំងរបស់អ្នក (ជាពិសេសប្រសិនបើអ្នកចង់ចុះធ្វើសេចក្ដីរាយការណ៍ផ្ទាល់ ឬធ្វើការសម្ភាសនៅតាមមូលដ្ឋាន)
- តារាងចំណាត់ថ្នាក់ (Rubrics) ដែលអ្នកមានចំណាប់អារម្មណ៍
- ជំនាញឯកទេសរបស់អ្នក
- ការណែនាំសង្ខេបអំពីខ្លួនអ្នក រួមជាមួយព័ត៌មានណាមួយដែលពាក់ព័ន្ធនឹងទស្សនាវដ្ដី (ដូចជា បទពិសោធន៍បង្រៀន, ស្នាដៃផ្នែកបច្ចេកទេស, ការចូលរួមក្នុងគម្រោងអប់រំផ្សេងៗ ជាដើម)
- ភស្តុតាងណាមួយដែលបង្ហាញពីជំនាញរបស់អ្នក
  ឧទាហរណ៍៖ អ្នកអាចសរសេររឿងរ៉ាវពិតខ្លីៗពីបទពិសោធន៍បង្រៀនរបស់អ្នកសម្រាប់ផ្នែក «ម៉ាស៊ីនឆុងកាហ្វេ (Coffee Machine)» ឬអត្ថបទណាមួយដែលអ្នកយល់ថាមានតម្លៃគួរតែបោះពុម្ពផ្សាយ។

សូមផ្ញើអ៊ីមែលរបស់អ្នកមកកាន់៖

Educational.magazine.cambodia@gmail.com

# Magic Approach និងវិធីបង្រៀនក្នុងមុខវិជ្ជាគណិតវិទ្យា

ដោយ៖ **Stanislas Kowalski** បកប្រែដោយ៖ **គង់ សុគន្ធា**

Magic Approach និង វិធីបង្រៀនក្នុងមុខវិជ្ជាគណិតវិទ្យា ពេលដែលចុះគាំទ្រ និងសង្កេតការបង្រៀនរបស់គ្រូបង្រៀនគណិតវិទ្យា នៅវិទ្យាល័យមួយឃើញថាលោកគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា បានប្រើប្រាស់វិធីបង្រៀនបែបរិះរក (Inquiry-based learning) ដែលចុងបញ្ចប់នៃមេរៀនឃើញថា គ្រូបង្រៀនមិនសម្រេចបាននូវវត្ថុបំណងនៃមេរៀន និង ជាលទ្ធផលឃើញថាសិស្សមិនសូវបានអនុវត្តលំហាត់គំរូ ឬលំហាត់អនុវត្តបានច្រើននោះទេ ដោយសារតែការពិភាក្សាក្រុមចំណាយពេលជាច្រើននាទី និងមិនប្រាកដថាគ្រប់គ្នាជាសមាជិកក្នុងក្រុមបានអនុវត្តលំហាត់គ្រប់គ្នានោះដែរ។ ពេលដែលផ្តល់មតិកែលម្អ ក្រោយការសង្កេតថ្នាក់រៀនគ្រូបង្រៀនបានពន្យល់ពីមូលហេតុ ដែលគាត់ប្រើប្រាស់វិធីបង្រៀនបែបរិះរកគឺដោយសារតែ ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនដទៃទៀតក្នុងក្រុមមុខវិជ្ជាដូចគ្នាបានណែនាំឱ្យគាត់ប្រើប្រាស់វិធីបង្រៀននេះ និង យល់ថាការសាកល្បងប្រើប្រាស់វិធីបង្រៀនមួយនេះ ទើបអាចសន្មតថា គាត់ពិតជាបានប្រើប្រាស់នូវវិធីបង្រៀនបែបសកម្ម ប៉ុន្តែត្រូវបានណែនាំឱ្យប្តូរទៅជាវិធីបង្រៀនបែបសកម្មនិងធ្វើឱ្យគាត់មិនសូវមានទំនុកចិត្តក្នុងការបង្រៀន ហើយលំនាំនៃការបង្រៀននៅមានការអាក់រអួល។ សំណួររបស់លោកគ្រូនៅពេលនោះគឺ "តើគាត់គួរតែធ្វើយ៉ាងដូចម្តេចដើម្បីសម្រេចបាននូវវត្ថុបំណងនៃមេរៀន និងគោលដៅក្នុងការរៀននិងបង្រៀនមុខវិជ្ជាគណិតវិទ្យា?"

**ចម្លើយ**

## ការជ្រើសរើសវិធីបង្រៀនឱ្យសមស្រប

នេះគឺជាសំណួរដ៏ល្អមួយ ព្រោះវាដាស់តឿនយើងថាវិធីបង្រៀនថ្មីមួយមិនមែនសុទ្ធតែសមស្របគ្រប់ពេលនោះទេ ហើយវាថែមទាំងអាចផ្តល់ផលអវិជ្ជមានវិញ ប្រសិនបើការអនុវត្តមិនបានត្រឹមត្រូវ។ អ្នកមិនគួរប្រើប្រាស់វាគ្រាន់តែដើម្បីឱ្យគាប់ចិត្តគ្រូឧទ្ទេសនោះឡើយ។ អ្នកត្រូវប្រើវាលុះត្រាតែអ្នកយល់ច្បាស់ពីវា និងនៅពេលដែលវាសមស្របទៅនឹងមេរៀនដែលត្រូវបង្រៀន។ អ្នកគួរតែសម្រេចចិត្តដោយខ្លួនឯងប្រកបដោយទំនុកចិត្ត។

ការរៀនតាមបែបរិះរក (Inquiry-Based Learning - IBL) អាចជាយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍការគិតបែបវិភាគ និងបណ្តុះស្មារតីរៀនសូត្រពេញមួយជីវិត។ ហេតុដូច្នេះហើយ យើងនឹងព្យាយាមពន្យល់ពីរបៀបដែលយើងអាចធ្វើឱ្យវាដំណើរការទៅបានក៏ដូចជាចំណុចខ្វះខាតដែលត្រូវចៀសវាង។ ប៉ុន្តែ វាមិនមែនជាឱសថទិព្វសម្រាប់ដោះស្រាយគ្រប់បញ្ហានោះទេ។ ជាពិសេស វាមិនមានភាពសមស្របឡើយនៅពេលបង្រៀនលើជំនាញមូលដ្ឋានងាយៗ។

គោលវិធីបង្រៀនដោយផ្ទាល់ (Direct approach) គឺប្រសើរជាង ប្រសិនបើយើងនិយាយអំពីមេរៀនដែលកុមារត្រូវតែយល់ឱ្យបានច្បាស់លាស់បំផុត ឧទាហរណ៍ដូចជាការបង្ហាញតាមលំនាំ "គ្រូធ្វើឱ្យមើល យើងធ្វើជាមួយគ្នា សិស្សធ្វើដោយខ្លួនឯង" (I do, we do, you do) ជាដើម។ ក្នុងចំណុចនេះ ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ថាសកម្មភាពរបស់សិស្សអាចកើតឡើងនៅដំណាក់កាលផ្សេងៗគ្នានៃមេរៀន។

ការធ្វើលំហាត់អនុវត្តក៏នៅតែជាសកម្មភាពមួយដែរ បើទោះបីជាវាអាចមានភាពប្រឈមតិចជាងសកម្មភាពស្វែងយល់ (Discovery activity) ដែលសិស្សមានសេរីភាពក្នុងការគិតច្រើនជាងក៏ដោយ។ វិធីបង្រៀនបែបរិះរក IBL គួរតែត្រូវបានប្រើដើម្បីស្វែងយល់ពីគំនិតដែលស៊ីជម្រៅនៅពេលដែលយើងអាចទទួលយកបាននូវលទ្ធផលដែលខុសៗគ្នាពីសិស្ស។ ឧទាហរណ៍ វារឹតតែមានប្រសិទ្ធភាពខ្លាំងនៅក្នុងមុខវិជ្ជាប្រវត្តិវិទ្យា ឬភូមិវិទ្យា។ វាមិនសំខាន់ទេ ប្រសិនបើសិស្សទទួលបានព័ត៌មានមិនទាន់គ្រប់ជ្រុងជ្រោយអំពីប្រាសាទអង្គរវត្ត ឬអំពីប្រទេសជប៉ុន ដរាបណាពួកគេមានការចង់ដឹងចង់ឃើញនិងរៀនពីរបៀបស្វែងរកព័ត៌មាន។ ចំពោះមុខវិជ្ជា

គណិតវិទ្យា វាកាន់តែមានភាពប្រឈមព្រោះយើងពិតជាត្រូវការឱ្យសិស្សយល់ពីគោលគំនិតឱ្យបានត្រឹមត្រូវបំផុត បើទោះបីជាការប្រើ IBL នៅតែអាចធ្វើទៅបានក៏ដោយ។ ដោយសារខ្ញុំមិនបានដឹងពីប្រធានបទនៃមេរៀន ឬ កម្រិតរបស់សិស្ស ខ្ញុំមិនអាចបញ្ជាក់ឱ្យច្បាស់ថា តើការប្រើ IBL ក្នុងករណីរបស់អ្នកគឺសមស្របដែរឬយ៉ាងណានោះទេ។

## ការបង្រៀនតាមបែបរិះរក ≠ ការរៀនតាមបែបសហការ

មុននឹងយើងពន្យល់អំពី របៀបអនុវត្តវិធីបង្រៀនតាមបែបរិះរក (Inquiry-Based Learning - IBL) ឱ្យមានប្រសិទ្ធភាព ខ្ញុំសូមបញ្ជាក់ចំណុចមួយចំនួនជាមុនសិន ដើម្បីកុំឱ្យមានការភាន់ច្រឡំ។ ការរៀនតាមបែបរិះរក (IBL) មិនមែនទាមទារឱ្យមានកិច្ចសហការរវាងសិស្សានុសិស្សជានិច្ចនោះទេ (ចំណុចនោះគឺជាការសិក្សាបែបសហការ (Collaborative Learning)។ ការសិក្សាបែបរិះរកគឺជាយុទ្ធសាស្ត្រមួយដែលកើតចេញពីការចោទសួរ (ហេតុនេះហើយទើបគេប្រើពាក្យថា Enquiry ឬការសាកសួរ)។ តាមរយៈការឆ្លើយសំណួរ សិស្សនឹងរៀនបាននូវខ្លឹមសារមេរៀនជាក់លាក់ណាមួយ។ ជាទូទៅវិធីបង្រៀននេះត្រូវបានធ្វើឡើងតាមរយៈការអាន និងការវិភាគឯកសារ ឬតាមរយៈការឆ្លុះបញ្ចាំងពីគំនិតផ្ទាល់ខ្លួន។ ឯកសារទាំងនោះអាចផ្តល់ឱ្យដោយគ្រូ ឬ ស្វែងរកដោយសិស្សខ្លួនឯងនៅបណ្ណាល័យ ឬនៅលើអ៊ីនធឺណេត។

ចំពោះផ្នែកនៃការឆ្លុះបញ្ចាំងគំនិត ជារឿយៗត្រូវបានអនុវត្តក្នុងអំឡុងពេលការងារក្រុម ជាពិសេសនៅពេលដែលសំណួរមានភាពស្មុគស្មាញ ព្រោះសិស្សអាចជួយគ្នាទៅវិញទៅមកក្នុងការរុករក និងពិនិត្យមើលលទ្ធភាពផ្សេងៗបានកាន់តែច្រើន។ ទោះជាយ៉ាងណាក៏ដោយ វាមិនមែនជាការចាំបាច់ដែលត្រូវតែបញ្ចូល IBL និងការសិក្សាបែបសហការជាមួយគ្នានោះទេ។ សិស្សមួយចំនួនប្រហែលជាមានអារម្មណ៍ស្រណុកចិត្តជាងក្នុងការសង្ខេបឯកសារ ឬសរសេរអត្ថបទខ្លីៗដែលពួកគេរៀបចំឡើងដោយខ្លួនឯង។

## តើការរៀនតាមបែបរិះរកនៅក្នុងមុខវិជ្ជាគណិតវិទ្យាមានលក្ខណៈដូចម្តេច?

នៅកម្រិតវិទ្យាល័យ វាហាក់ដូចជាកម្រណាស់សម្រាប់សិស្សក្នុងការរៀនសូត្រនូវគោលការណ៍គ្រឹះថ្មីៗ នៃគណិតវិទ្យាទាំងស្រុងតាមរយៈការអាន ឬការឆ្លុះបញ្ចាំងគំនិតផ្ទាល់ខ្លួន។ ចំណុចនេះគឺសម្បូរជាងនៅកម្រិតសាកលវិទ្យាល័យ។ ការអានសៀវភៅគោលគណិតវិទ្យា និងការយល់ដឹងដោយខ្លួនឯងទាមទារឱ្យមានផ្នត់គំនិតជាក់លាក់ និងកម្រិតនៃការយល់ដឹងបែបអរូបីយ (abstraction) ខ្ពស់។ អ្នកនៅតែអាចឱ្យសិស្សអានមេរៀនក្នុងសៀវភៅពុម្ពដោយខ្លួនឯងមុន នឹងឱ្យពួកគេធ្វើលំហាត់ ប៉ុន្តែវានៅមានកម្រិតនៅឡើយ។ វានឹងមិនមានកម្រិតនៃការរុករក (exploration) ដូចអ្វីដែលមិត្តរួមការងារផ្នែកប្រវត្តិវិទ្យារបស់អ្នកអាចធ្វើបានតាមរយៈសកម្មភាពប្រើប្រាស់អ៊ីនធឺណេតនោះទេ។ អ្វីដែលពួកគេតែងតែធ្វើនៅក្នុងកម្រិតវិទ្យាល័យ គឺមានលក្ខណៈស្រដៀងទៅនឹង ការសិក្សាបែបដោះស្រាយបញ្ហា (Problem-Based Learning - PBL) ដែលក្នុងនោះអ្នកយកគោលការណ៍ដែលបានរៀនរួចទៅអនុវត្តលើសំណុំបញ្ហាដែលមានលក្ខណៈខុសប្លែកគ្នាបន្តិចបន្តួច។ ខ្ញុំនឹងមិនពិភាក្សាអំពីភាពខុសគ្នារវាង IBL និង PBL នៅទីនេះទេ ព្រោះថាពាក្យបច្ចេកទេសទាំងនេះមិនសូវជាមានភាពដាច់ស្រឡះពីគ្នាខ្លាំង ហើយការអនុវត្តជាក់ស្តែងតែងតែមានភាពស្ទួនគ្នា។ គ្រាន់តែចងចាំថា ការជ្រើសរើសសំណួរដើម្បីសួរគឺមានសារៈសំខាន់ណាស់ដូចដែលយើងនឹងឃើញនៅខាងក្រោម។

## សំណួរដែលល្អសម្រាប់ការរៀនតាមបែបសហការ

ប្រសិនបើអ្នកចង់អនុវត្តចំពោះ ការរៀនតាមបែបសហការ (Collaborative Learning) ក្នុងមុខវិជ្ជាគណិតវិទ្យា តើលក្ខខណ្ឌអ្វីខ្លះដែលនាំឱ្យទទួលបានជោគជ័យ? វាមានកត្តាពាក់ព័ន្ធជាច្រើន ហើយខ្ញុំអាចនឹងរំលងចំណុចខ្លះ ប៉ុន្តែនេះគឺជាកត្តាទូទៅបំផុត។ ជាដំបូង ត្រូវតែមានអ្វីមួយសម្រាប់ពិភាក្សា។ នៅកម្រិតវិទ្យាល័យ ជាទូទៅគណិតវិទ្យាមានភាពច្បាស់លាស់ណាស់។ អ្នកមានរូបមន្ត រួចអ្នកអនុវត្តរូបមន្តនោះយ៉ាងហ្មត់ចត់។ ប្រសិនបើវាមានចម្លើយត្រឹមត្រូវតែមួយ នោះវាមិនមានអ្វីត្រូវពិភាក្សាឡើយ។ សិស្សអាចនឹង "ដឹង" ឬ "មិនដឹង" ប៉ុន្តែវាមិនមានចន្លោះសម្រាប់ជជែកវែកញែកទេ។ ក្នុងករណីនោះ ការសិក្សាបែបសហការគឺជាការខាតពេល ហើយយើងនឹងឃើញនូវអ្វីដែលអ្នកបានរៀបរាប់គឺ សិស្សម្នាក់ក្នុងក្រុមដែលពូកែជាងគេនឹងធ្វើការងារទាំងអស់ ព្រោះអ្នកផ្សេងទៀតមិនចាំបាច់ត្រូវជួយអ្វីឡើយ។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងគណិតវិទ្យាអនុវត្ត (គណិតវិទ្យាដែលអនុវត្តលើបញ្ហាជាក់ស្តែង) មានស្ថានភាពខ្លះដែលកិច្ចសហការអាចនឹងមានប្រយោជន៍។ ខ្ញុំសង្កេតឃើញមានករណីសំខាន់ៗយ៉ាងហោចណាស់ពីរ៖

**ករណីទី១៖** នៅពេលដែលបញ្ហាមិនមែនត្រឹមតែជារឿងគណិតវិទ្យា ប៉ុន្តែជារឿងនៃ "ការសម្រេចចិត្ត"។ សាកល្បង

ស្រមៃពីបញ្ហាអត្រាការប្រាក់កម្ចី។ អ្នកមានការផ្តល់ជូនបីជម្រើសពីធនាគារដើម្បីប្រៀបធៀប។ តាមរយៈរូបមន្តងាយៗ អ្នកអាចគណនាថ្លៃដើមសរុបនៃប្រាក់កម្ចី និងកំណត់ថាជម្រើសណាមួយចំណាយតិចជាងគេ (ជាទូទៅគឺជាជម្រើសដែលមានរយៈពេលសងត្រឡប់ខ្លី)។ មកដល់ត្រឹមនេះ វាមិនមានអ្វីត្រូវពិភាក្សាទេ។ សិស្សម្នាក់ឯងអាចធ្វើវាបានក្នុងរយៈពេល ៥នាទី។ បើធ្វើជាក្រុមពួកគេអាចនឹងចំណាយពេលដល់ ១ ម៉ោង ដែលនេះគឺជាបរាជ័យនៃវិធីសាស្ត្របង្រៀន។ ប៉ុន្តែ ចំណុចសំខាន់គឺតែងតែស្ថិតនៅក្រោយពាក្យ "ប៉ុន្តែ" នេះឯង។ នៅក្នុងជីវិតជាក់ស្តែង មានកត្តាផ្សេងទៀតដែលត្រូវពិចារណា។ ប្រសិនបើបន្ថែមព័ត៌មានមួយទៀតទៅក្នុងលំហាត់ គឺ "ប្រាក់ខែរបស់អ្នកខ្ចី" តើគាត់អាចសងវិញបានប៉ុន្មានក្នុងមួយខែ? ពេលនោះហើយ ទើបមានចន្លោះសម្រាប់ការពិភាក្សា។ វាច្បាស់ណាស់ថា អ្នកមិនអាចប្រើប្រាស់ប្រាក់ខែទាំងអស់ ដើម្បីសងបំណុលផ្ទះនោះទេ។ អ្នកត្រូវរក្សាប្រាក់សម្រាប់អាហារ ការធ្វើដំណើរ ការសិក្សា និងរបស់របរផ្សេងៗទៀត។ អ្នកនៅតែត្រូវគណនាលេខ ប៉ុន្តែអ្នកក៏ត្រូវធ្វើការសម្រេចចិត្ត និងជជែកវែកញែកការពារមតិខ្លួនឯងផងដែរ។ សិស្សខ្លះអាចនឹងសុខចិត្តរស់នៅដោយសន្សំសំចៃបំផុត ដើម្បីឱ្យរួចផុតពីបន្ទុកបំណុលបានលឿន។ សិស្សខ្លះទៀតអាចនឹងជ្រើសរើសសុវត្ថិភាព ដោយបង់ប្រាក់ក្នុងចំនួនតិចតួចដើម្បីធានាថាពួកគេតែងតែមានលុយជាប់ខ្លួនគ្រប់គ្រាន់ ទោះបីជាវាមានន័យថាពួកគេត្រូវបង់ប្រាក់សរុបច្រើនជាងមុនក៏ដោយ។

**ករណីទី២៖** នៅពេលដែលមាន "វិធីច្រើនយ៉ាង" ក្នុងការដោះស្រាយបញ្ហា យើងអាចស្រមៃមើលលំហាត់មួយដែលសិស្សត្រូវគណនាក្រឡាផ្ទៃនៃរូបធរណីមាត្រដែលស្មុគស្មាញ។ សិស្សខ្លះនឹងព្យាយាមបូកបញ្ចូលគ្នានូវផ្នែកតូចៗ សិស្សខ្លះទៀតនឹងចាប់ផ្តើមពីការគណនារូបធំ រួចដកផ្នែកដែលខ្វះចេញ។ អ្នកគណិតវិទ្យាអាជីពតែងតែជជែកវែកញែកគ្នាថា តើវិធីសាស្ត្រណាមួយដែល "ស្រស់ស្អាត" (elegant) ជាងគេក្នុងស្ថានភាពខុសៗគ្នា។ អាល់ហ្គោរីត (Algorithm) ខ្លះដំណើរការបានល្អជាមួយលេខតូចៗ ប៉ុន្តែអាចក្លាយជាសុបិនអាក្រក់សម្រាប់លេខធំៗ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះទាមទារឱ្យសិស្សបានដឹងពីវិធីផ្សេងៗរួចជាស្រេចសម្រាប់ជ្រើសរើស។ វាមិនសូវមានប្រសិទ្ធភាពឡើយចំពោះមេរៀនដែលថ្មីស្រឡាងទាំងស្រុង។

## ការរៀបចំជាក់ស្តែង

នៅពេលដែលអ្នកមានសំណួរដែលល្អគ្រប់គ្រាន់សម្រាប់ការសិក្សាបែបសហការហើយ អ្នកត្រូវពិចារណាថា តើគួរមានសិស្សប៉ុន្មាននាក់ក្នុងមួយក្រុម។ តាមរយៈការសង្កេតក្នុងថ្នាក់រៀនជាច្រើនដង ខ្ញុំអាចប្រាប់បានថាក្រុមដែលមានសិស្សលើសពី ៤ នាក់ គឺជាការខ្វះខាត។ ប្រសិនបើក្រុមធំពេក វាពិតជាពិបាកខ្លាំងណាស់សម្រាប់សិស្សក្នុងការចូលរួមក្នុងកិច្ចពិភាក្សា។ ចំណុចនេះនាំទៅរកបញ្ហាបន្ទាប់៖ តើអ្នកចង់ឱ្យពួកគេផ្តល់ចម្លើយក្នុងទម្រង់បែបណា? ប្រសិនបើអ្នកឱ្យក្រុមច្រើនពេកឡើងមកបង្ហាញចម្លើយនៅលើក្តារខៀន វានឹងចំណាយពេលយូរណាស់។ ដូច្នេះ ចម្លើយទាំងនោះប្រហែលជាគួរផ្ញើចូលក្នុងក្រុម Telegram ឬសរសេរលើក្រដាសវិញ។

ប្រសិនបើអ្នកចង់ឱ្យសិស្សសហការគ្នាលើសកម្មភាពកម្រិតទាប (លំហាត់សាមញ្ញៗ) អ្នកគួរតែផ្លាស់ប្តូរការរៀបចំទាំងស្រុង។ ជាឧទាហរណ៍ អ្នកអាចផ្តល់សន្លឹកកិច្ចការដែលមានលំហាត់ច្រើន ហើយឱ្យសិស្សប្រកួតប្រជែងគ្នាជាក្រុម ដើម្បីធ្វើលំហាត់ទាំងនោះឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ ជាធម្មតា ចំនួនសំណួរគួរតែមានច្រើនពេកដែលមិនអាចឆ្លើយអស់ក្នុងរយៈពេលដែលបានកំណត់។ ក្រុមនីមួយៗ នឹងត្រូវជ្រើសរើសវិធីបែងចែកការងារគ្នា ដើម្បីបង្កើនឱកាសឈ្នះឱ្យបានខ្ពស់បំផុត។ ប្រសិនបើអ្នកផ្តល់ពិន្ទុសម្រាប់រាល់ចម្លើយដែលត្រឹមត្រូវ និងដកពិន្ទុសម្រាប់រាល់កំហុស នោះពួកគេនឹងមានទឹកចិត្តក្នុងការត្រួតពិនិត្យចម្លើយឡើងវិញមុននឹងប្រគល់ឱ្យអ្នក។ ឬប្រសិនបើអ្នកមិនចង់ឱ្យមានការប្រកួតប្រជែង អ្នកគ្រាន់តែអាចប្រាប់ថាសិស្សម្នាក់ៗត្រូវតែបំពេញសន្លឹកកិច្ចការទាំងនោះរៀងៗខ្លួន ប៉ុន្តែពួកគេអាចសុំជំនួយពីសមាជិកក្នុងក្រុមបាន។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីនោះ កិច្ចសហការមានដែនកំណត់។ សិស្សម្នាក់ៗមានសិទ្ធិធ្វើការងារម្នាក់ឯង ឬធ្វើជាមួយដៃគូក៏បាន។

## សរុបសេចក្តី

សរុបមក វិធីបង្រៀនបែបរិះរក (IBL) គ្រាន់តែជាឧបករណ៍មួយផ្សេងទៀតនៅក្នុងប្រអប់ឧបករណ៍បង្រៀនរបស់អ្នកតែប៉ុណ្ណោះ។ វាមិនចាំបាច់ត្រូវជំនួសឱ្យវិធីធម្មតារបស់អ្នកទាំងស្រុងនោះទេ។ ចូរចាត់ទុកវាជាមធ្យោបាយមួយដើម្បីឈានទៅដល់កម្រិតថ្មីមួយទៀត និងធ្វើឱ្យសិស្សរបស់អ្នកចេះគិតពិចារណាបានស៊ីជម្រៅ នៅពេលដែលពួកគេបានយល់ដឹងពីគោលការណ៍គ្រឹះរួចរាល់ហើយ។ ហើយសម្រាប់ការជ្រើសរើសរវាងការងារបុគ្គល ការងារជាគូ ឬការសិក្សាបែបសហការ អ្នកគួរតែពិចារណាថា តើការរៀបចំមួយណាដែលនឹងធ្វើឱ្យសិស្សខិតខំធ្វើការបានច្រើនជាងគេ ដោយមិនចាំបាច់សន្មតថាវិធីបង្រៀនណាមួយល្អជាងវិធីណាមួយនោះឡើយ។

# ការចុះជួយគាំទ្រ និងបន្ទុករបស់គ្រូបង្រៀនថ្មី

ដោយ៖ **Stanislas Kowalski** បកប្រែដោយ៖ **ស៊ី ហុង**

លោកគ្រូវង្ហា គឺជាគ្រូបង្រៀនកិច្ចសន្យាថ្មីម្នាក់ដែលទទួលបន្ទុកបង្រៀនភាសាអង់គ្លេសកម្រិតមូលដ្ឋាន។ នៅក្នុងការចុះសង្កេតការបង្រៀនជាក់ស្តែង គ្រូបង្រៀនបានប្រើប្រាស់សៀវភៅ English for Children ឃើញថាផែនការមេរៀនស្តីពី ការណែនាំពីអក្សរ QR របស់គាត់នៅមានចំណុចខ្វះខាតបច្ចេកទេសមួយចំនួនដែលទាមទារឱ្យមានការកែលម្អជាបន្ទាន់ដើម្បីធានាបាននូវលទ្ធផលសិក្សារបស់សិស្ស។ ចំណុចដែលបានរកឃើញពីការបង្រៀននោះគឺគ្រូបង្រៀនកិច្ចសន្យារូបនោះមានភាពមិនច្បាស់លាស់នៃវិធីបង្រៀនដែលគ្រូប្រើប្រាស់ដែលគាត់បានសរសេរនៅក្នុងផែនការមេរៀនត្រឹមតែពាក្យថា វិធីបង្រៀន និង បច្ចេកទេស ប៉ុន្តែមិនបានបញ្ជាក់ឱ្យច្បាស់ថាតើគាត់នឹងប្រើប្រាស់វិធីបង្រៀនអ្វី (ឧទាហរណ៍៖ វិធីបង្រៀនបែបសកម្ម ឬការរៀនតាមរយៈការលេង) ឱ្យសមស្របនឹងខ្លឹមសារមេរៀននោះទេ។ បើក្រឡេកទៅមើលវត្ថុបំណងនៃមេរៀនហាក់មិនសូវមានភាពច្បាស់លាស់ មិនបានកំណត់ថាក្រោយបញ្ចប់ការសិក្សា សិស្សនឹងទទួលបានចំណេះដឹង និងបំណិនអ្វីខ្លះឱ្យពិតប្រាកដនោះទេ រីឯខ្លឹមសារមេរៀនផ្តោតខ្លាំងលើការបង្ហាញរបស់គ្រូ ជាជាងការបង្កើតសកម្មភាពអន្តរកម្ម ដែលធ្វើឱ្យសិស្សមានភាពសកម្មក្នុងការរៀន។ មួយវិញទៀត ការបញ្ចេញសំឡេងមិនទាន់ចំសូរសំឡេង ហើយការពន្យល់អំពីសូរអក្សរ Q មិនត្រូវបានរៀបរាប់លម្អិត ដែលអាចធ្វើឱ្យសិស្សមានការភ័ន្តច្រឡំ។ ចុងក្រោយសង្កេតឃើញថាគ្រូបង្រៀនហាក់មិនមានការវាយតម្លៃលើការសិក្សារបស់សិស្សថា តើសិស្សយល់មេរៀនបានកម្រិតណានៅក្នុងមេរៀន ឬក្រោយពេលបង្រៀន។ សំណួរសួរថា តើនេះមកពីគ្រូបង្រៀនរូបនោះមានភាពស្រពេចស្រពិលលើការជ្រើសរើសវិធីសាស្រ្តបង្រៀនឬយ៉ាងណា? តើគ្រូបង្រៀនរូបនោះមិនសូវច្បាស់លើការកំណត់វត្ថុបំណងមេរៀនមែនឬទេ? តើកត្តាអ្វីខ្លះដែលអាចជះឥទ្ធិពលលើការប្រើប្រាស់គោលវិធីគ្រូមជ្ឈមណ្ឌលក្នុងការបង្រៀនភាសាអង់គ្លេស? ហេតុអ្វីបានជាគាត់មិនវាយតម្លៃការយល់ដឹងរបស់សិស្សបន្ទាប់ពីបង្រៀនមេរៀននោះរួច?

**មតិត្រឡប់៖** ពេលខ្ញុំអានសំណួរនេះ ខ្ញុំបារម្ភពីការវាយតម្លៃរបស់យើងចំពោះលោកគ្រូវ័យក្មេងម្នាក់នោះ។ យើងគួរមានការរំពឹងទុកសមល្មម។ វាហាក់ដូចបច្ចេកទេសខ្លាំងពេក និងការរំខានច្រើនពេកចំពោះមេរៀនមួយ ដែលសាមញ្ញដូចអក្សរមួយតួ។ ខ្ញុំបារម្ភថា វិធីបង្រៀនច្រើនពេកនឹងធ្វើឱ្យស្ថានការណ៍កាន់តែយ៉ាប់ជាជាងជួយគ្រូបង្រៀនជាក់ស្តែង។ ហើយពេលខ្ញុំពិនិត្យមើលសៀវភៅណែនាំ វាធ្វើឱ្យខ្ញុំមានអារម្មណ៍កាន់តែយ៉ាប់។ សៀវភៅ English for Children ជាឧបករណ៍ដែលខ្សោយណាស់។ វាមានគម្លាតធំណាស់រវាងការរំពឹងទុករបស់អ្នកនិងឧបករណ៍នោះ ដែលហាក់ដូចការសាងសង់ផ្ទះដោយប្រើថវិកាត្រឹមតែ១០០០០រៀលប៉ុណ្ណោះ។

កុំសូវតឹងតែងជាមួយការប្រើប្រាស់ពាក្យពេចន៍ពេក។ ភាពខុសគ្នារវាងគោលវិធី វិធីសាស្រ្ត និង បច្ចេកទេស អាចនឹងមានប្រយោជន៍ពេលខ្លះ នៅពេលយើងសាកល្បងអ្វីដែលស្មុគស្មាញ។ ប៉ុន្តែ មែនទែនទៅ តើវាមានភាពពាក់ព័ន្ធអ្វីជាមួយនឹងមេរៀនអក្សរ Q ? អ្នកមិនចាំបាច់ទាល់តែមានសញ្ញាបត្របណ្ឌិតដើម្បីបង្រៀនក្មេងអាយុ៧ឆ្នាំទេ។ ធ្វើឱ្យវាសាមញ្ញ។ មនុស្សយើងនិយាយពាក្យពេចន៍ជាសុភាសិត តែពុំដឹងថាខ្លួនកំពុងនិយាយពាក្យពេចន៍ជាសុភាសិតនោះទេ ហើយវាពិតជាគ្មានបញ្ហាអ្វីទេ ទាល់តែពួកគេរៀនពីការតែងកំណាព្យ។ អ្នកអាចបង្រៀនពាក្យសាមញ្ញៗនិងណែនាំពាក្យបច្ចេកទេសទាក់ទងវិទ្យាសាស្រ្តមួយជំហានម្តងៗ។ អ្នកគួរតែអនុវត្តដូចគ្នានេះជាមួយគ្រូបង្រៀនកិច្ចសន្យា មុនពេលពួកគាត់មានអារម្មណ៍នឿយណាយជាមួយការងារមួយនេះ។ ចាប់ផ្តើមពីរឿងដែល

អាចអនុវត្តបានជាក់ស្តែង ចាប់ផ្តើមពីមូលដ្ឋានគ្រឹះបច្ចេកទេស មិនមែនពីវិធីសាស្ត្រ ឬ ទស្សនវិជ្ជាទេ។ គាត់នឹងរៀនអំពីការធ្វើចំណាត់ថ្នាក់នោះនៅពេលក្រោយ។

ខ្ញុំគ្រាន់តែចង់រំឭកអ្នកពីអ្វីដែលខ្ញុំលើកឡើង នៅក្នុងចំណងជើង ទស្សនាវដ្តីលេខមុន។ កិច្ចតែងការបង្រៀនត្រូវបានរៀបចំឡើងដើម្បីជួយគ្រូបង្រៀនធ្វើការសម្រេចចិត្ត។ លុះត្រាណាពួកគាត់យល់ច្បាស់ពីអ្វីដែលខ្លួនចង់ធ្វើឬអនុវត្ត ទម្រង់ណាមួយក៏អាចទទួលយកបានដែរ។ ប្រសិនបើសិស្សអាចរៀននិងសប្បាយរីករាយជាមួយនឹងការរៀន សូមកុំទៅរំខានគ្រូបង្រៀននឹងរឿងលម្អិតឬចំណុចតូចតាច។

## ការស្វែងរកសម្ភារឧបទេសសមស្រប

ឥឡូវយើងសាកគិតពិចារណាពីបញ្ហាស្នូល។ ទំនងជាអាចផ្តើមពីការវិភាគសៀវភៅសិក្សាគោលនិងរកមើលថាតើមានបញ្ហាអ្វីខ្លះនិងរកអ្វីដែលយើងបន្ថែមបន្ថយបានខ្លះ ពីព្រោះសៀវភៅ English for Children នេះខ្លីនិងស្ទើរតែគ្មានមាតិកាមេរៀនសោះ ដោយគ្រាន់តែផ្តោតយ៉ាងខ្លាំងលើការបង្រៀនអក្ខរក្រមភាសាអង់គ្លេស ពុំមានអ្វីផ្សេងទៀតនោះទេ ហើយជាសៀវភៅភាគដំបូងទៀត។ ការស្គាល់តែអក្សរមិនគ្រប់គ្រាន់ឡើយ តាមស្តង់ដារណាមួយ ទោះបីជាសម្រាប់ថ្នាក់ទី២ ឬសម្រាប់រយៈពេលកំណត់ក៏ដោយ។ សូមកុំយល់ច្រឡំ។ អក្ខរក្រមភាសាសំខាន់ណាស់ ហើយត្រូវតែបង្រៀនយ៉ាងច្បាស់។ ប៉ុន្តែចំណេះដឹងនោះត្រូវភ្ជាប់ជាមួយអ្វីផ្សេងទៀត។ ក្នុងឆ្នាំដំបូងនៃការរៀនភាសាអង់គ្លេស យើងរំពឹងថាសិស្សយ៉ាងហោចណាស់មានមូលដ្ឋានវាក្យសព្ទ និងសំណង់វេយ្យាករណ៍មូលដ្ឋានមួយចំនួន។ វាមិនចាំបាច់ត្រូវមានលក្ខណៈបច្ចេកទេសទេ ប៉ុន្តែត្រូវមានន័យ។ យើងក៏រំពឹងថាមានការសន្ទនាសាមញ្ញខ្លះៗ ដោយប្រើឃ្លាពេញលេញមួយចំនួន។ គ្មានវិធីណាដែលសិស្សអាចចងចាំអក្សរបានទេ ប្រសិនបើពួកគេមិនអាចភ្ជាប់វាជាមួយឧទាហរណ៍ជាច្រើន។ ខ្ញុំមានការភ្ញាក់ផ្អើលណាស់ដែលសិស្សមិនបានរៀនសូម្បីតែរបៀបណែនាំខ្លួនឯង។ សូមជួយគ្រូបង្រៀនរកសៀវភៅណែនាំមួយ ដែលមានយ៉ាងហោចណាស់លក្ខណៈមូលដ្ឋានទាំងនេះ។ នៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី គ្រូបឋមសិក្សាប្រើសៀវភៅ Happy Campers។ កម្រងសៀវភៅនេះមានសៀវភៅណែនាំគ្រូល្អៗ ដែលពិពណ៌នាពីបច្ចេកទេសអនុវត្តមានប្រសិទ្ធភាព ដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្ស និងជំរុញឱ្យពួកគេចូលរួម។ ក្រសួងអប់រំ យុវជន និងកីឡា ក៏មានសៀវភៅផ្លូវការថ្មីមួយគឺ English is Fun។ វាមិនល្អឥតខ្ចោះទេ ប៉ុន្តែយ៉ាងហោចណាស់វាមានសកម្មភាពផ្សេងៗជាច្រើន។ សៀវភៅទាំងនេះអាចរកបានជាទម្រង់អេឡិចត្រូនិក (យ៉ាងហោចណាស់សម្រាប់ English is Fun)។ គ្មានហេតុផលណាមួយដែលត្រូវបន្តប្រើសៀវភៅ English for Children ទៀតឡើយ។ សូមរក្សាវាទុកជាភស្តុតាងប្រវត្តិសាស្ត្រនៃការធ្លាក់ចុះនៃការអប់រំកម្ពុជានៅចុងសតវត្សទី២០។

## ការបង្រៀនអក្ខរក្រមភាសាអង់គ្លេស

អំពីការបង្រៀនអក្សរដោយផ្ទាល់ ខ្ញុំមានអនុសាសន៍បច្ចេកទេសមួយចំនួន។ ខ្ញុំនឹងព្យាយាមធ្វើឲ្យវាសាមញ្ញ។ ដូចដែលបាននិយាយពីមុន នេះជាបច្ចេកទេស មិនមែនជាទស្សនវិជ្ជាទេ។ ជំហានដំបូង គោលដៅដែលល្អសម្រាប់មេរៀនមួយគឺ ឱ្យសិស្សអាច (១) ស្គាល់អក្សរ (២) សរសេរអក្សរហ្នឹង និង (៣) បញ្ចេញសំឡេងវាឱ្យបានត្រឹមត្រូវ។ វាមានលក្ខណៈសាមញ្ញ។ អ្វីដែលសំខាន់គឺកុំបំបែកការអានការសរសេរ និងការបញ្ចេញសំឡេងចេញពីគ្នា ព្រោះជំនាញទាំងនេះគាំទ្រគ្នាទៅវិញទៅមក។ អក្សរប៉ុន្មានអាចបង្រៀនចប់ក្នុងមួយម៉ោង ប្រសិនបើសិស្សបានយល់ពីគោលការណ៍អក្សររួចហើយ។ បើមិនដូច្នោះទេ អាចបង្រៀនតែមួយអក្សរបានគ្រប់គ្រាន់។

ទីពីរ អ្នកអាចរៀបចំសម្ភារៈបន្ថែមដើម្បីគាំទ្រសៀវភៅសិក្សាគោល (សូម្បីតែសៀវភៅ English is Fun) ដើម្បីបង្រៀនអក្សរឱ្យបានល្អនិងសមស្រប។ សៀវភៅសិក្សាភាសាបរទេសភាគច្រើនមិនផ្តោតខ្លាំងលើចំណុចនេះទេ ព្រោះពួកគេសន្មតខុសថាវាងាយរៀន។ សៀវភៅដែលបង្កើតដោយអ្នកបោះពុម្ពអាមេរិក ឬអង់គ្លេស សន្មតថាសិស្សស្គាល់អក្សរឡាតាំងរួចហើយ។ ចំណែកសៀវភៅរបស់ក្រសួងអប់រំ (MoEYS) វាបង្ហាញអក្សរយ៉ាងលឿននៅដើមសៀវភៅ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជា Nippon Foundation (ដែលបានបង្កើតសៀវភៅ) មិនបានពិចារណាថាភាសាខ្មែរមានប្រព័ន្ធអក្សរខុសពីឡាតាំង ដូចជាភាសាជប៉ុន។ ដូច្នេះ ខ្ញុំសូមណែនាំឱ្យចំណាយពេលគ្រប់គ្រាន់ក្នុងការបង្រៀនអក្ខរក្រមយ៉ាង ម៉ត់ចត់។ គ្រូបង្រៀនថ្នាក់ខ្ពស់ជាច្រើនតែងតែរអ៊ូពីសិស្សដែលមិនចេះអក្សរនេះ។ អក្សរនីមួយៗត្រូវតែបង្រៀនដោយភ្ជាប់ជាមួយឧទាហរណ៍ជាច្រើន ប៉ុន្តែសៀវភៅ English for Children មិនបានធ្វើដូច្នោះទេ។ ការបញ្ចេញសំឡេងត្រូវតែត្រឹមត្រូវ។ ការសរសេរសំឡេងជាអក្សរខ្មែរក្នុងសៀវភៅដូចគ្នានោះ មិនបានជួយច្រើនទេ ហើយថែម

សំឡេងបានល្អជាងមនុស្សពេញវ័យ(1)។ ទាំងបង្កការភាន់ច្រឡំផងដែរ។ យល់ល្អ ប្រើសំឡេងថត (audio) ឬបទចម្រៀងងាយចងចាំ (rhyming songs) ដែលអ្នកអាចរកបានយ៉ាងងាយលើ YouTube។ គ្រូមិនចាំបាច់ព្រួយបារម្ភច្រើនអំពី ការបញ្ចេញសំឡេងឱ្យបានល្អឥតខ្ចោះដោយខ្លួនឯងទេ ព្រោះកុមារមានសមត្ថភាពស្តាប់ និងចាប់សំឡេងបានល្អជាងមនុស្សពេញវ័យ[1]។ គ្រាន់តែធានាថាពួកគេអាចស្តាប់ការបញ្ចេញសំឡេងត្រឹមត្រូវបានគ្រប់គ្រាន់។ ក្នុងភាសាអង់គ្លេស ការបញ្ចេញសំឡេងពិបាកណាស់ ដូច្នេះត្រូវធានាថាគ្រូបានបង្រៀនគ្រប់លក្ខណៈនានានៅពេលណាមួយ (ប៉ុន្តែមិនចាំបាច់នៅក្នុងមេរៀនតែមួយទេ)។ ការបញ្ចូលអក្សរជាគូ (ដូចជា ch, th) ក៏ត្រូវបង្រៀនផងដែរ។ គ្រូមិនអាចបង្រៀនអក្សរដែលមិនបញ្ចេញសំឡេងទាំងអស់បានទេ ប៉ុន្តែត្រូវពន្យល់សិស្សឱ្យដឹងថាវាមាន។ វាសំខាន់ណាស់ក្នុងការយល់ថាភាសាអង់គ្លេសមានភាពស្មុគស្មាញបន្តិច ហើយការអនុវត្តជាញឹកញាប់គឺជាវិធីតែមួយដើម្បីធ្វើឱ្យបានត្រឹមត្រូវទាំងអស់។ មានការបង្ហាញពីរបៀបសរសេរអក្សរ (ductus) នៅក្នុងសៀវភៅសិក្សា ដូច្នេះត្រូវប្រាកដថាសិស្សបានអនុវត្តគ្រប់គ្រាន់ក្នុងការសរសេរអក្សរ។ សំខាន់បំផុត គឺពួកគេត្រូវពង្រឹងមេរៀនមុនៗជាលក្ខណៈប្រព័ន្ធ។ រាល់ពេលដែលគ្រូណែនាំអក្សរថ្មី គ្រូគួរតែរំលឹកអក្សរដែលបានបង្រៀនពីមុន ហើយបង្រៀនឱ្យសិស្សចេះផ្សំវាជាមួយគ្នា។

## ការធ្វើឱ្យសិស្សសកម្ម?

សម្រាប់ការប្រើប្រាស់វិធីសាស្ត្រសកម្ម យើងត្រូវតែបញ្ជាក់អំពីគំនិតមួយចំនួនជាមុនសិន។ ជាទូទៅ អ្វីដែលសំខាន់ពិតប្រាកដ គឺសិស្សត្រូវតែមានសកម្មភាពផ្លូវបញ្ញា។ វាមិនមានន័យថាត្រូវចូលរួមពិភាក្សា ឬធ្វើចលនាជុំវិញថ្នាក់រៀនជានិច្ចនោះទេ។ សិស្សដែលកំពុងគិតដើម្បីធ្វើលំហាត់ គឺជាសិស្សដែលសកម្មផ្លូវបញ្ញា។ សិស្សដែលខិតខំអានសៀវភៅក៏ជាសិស្សសកម្មផ្លូវបញ្ញាដែរ។

ក្នុងករណីមេរៀនភាសាអង់គ្លេស ជាក់ស្តែង ភាពសកម្មរួមមានការនិយាយ ការអាន ការសរសេរ និងការស្តាប់។ បញ្ហាប្រឈមគឺជម្រុញសិស្សនិយាយឱ្យបានច្រើន និង រក្សាការយកចិត្តទុកដាក់របស់សិស្សទាំងអស់។ វាជារឿងពិបាក ព្រោះបើសិស្សប្តូរវេនគ្នានិយាយ ឬអាន ពួកគេនឹងមានពេលត្រឹមតែ ១ ឬ ២ នាទីក្នុងមួយម៉ោងរៀនធម្មតាប៉ុណ្ណោះ។ គន្លឹះសំខាន់គឺរក្សាចលនានៃមេរៀនឲ្យមានបន្តបន្ទាប់។ កុំឱ្យសិស្សនៅស្ងៀមទំនេរ នៅពេលពួកគេកំពុងរង់ចាំមិត្តរួមថ្នាក់ឆ្លើយសំណួរ។

គ្រូអាចធ្វើបានដោយសួរសំណួរទៅកាន់សិស្សដោយចៃដន្យ។ គួរតែមានការផ្លាស់ប្តូររវាងពេលដែលសិស្សអានជាក្រុម និងពេលដែលអានជាលក្ខណៈបុគ្គល។ ការផ្លាស់ប្តូរនេះគួរតែធ្វើឱ្យលឿននិងភ្លាមៗ។ គ្រូអាចធ្វើបានដោយប្រើកាយវិការសាមញ្ញ ដូចជាអ្នកដឹកនាំក្រុមតន្ត្រី។

គួរតែមានពេលខ្លះដែលសិស្សធ្វើការជាគូ ឬជាក្រុមតូចៗ។ វាជួយផ្លាស់ប្តូរបរិយាកាស និងផ្តល់ពេលឲ្យសិស្សគិតអំពីចម្លើយរបស់ពួកគេច្រើនឡើង។

ស្រដៀងគ្នានេះ មានវិធីជាច្រើនក្នុងការត្រួតពិនិត្យថាសិស្សបានយល់ឬអត់។ ការវាយតម្លៃផ្លូវការដោយការដាក់ពិន្ទុ មិនតម្រូវជានិច្ចទេ។ ធ្វើការវាយតម្លៃបែបដំណាក់ផ្ទាល់មាត់ តាមរយៈការសួរសំណួរសិស្សជាច្រើននាក់ដោយចៃដន្យ ឬគ្រាន់តែដើរតាមជួរដើម្បីពិនិត្យសៀវភៅកត់ត្រារបស់សិស្ស។ ក្នុងការសរសេរ ក្តារឆ្នួន (slate) គឺជាវិធីល្អមួយ ដើម្បីឱ្យសិស្សច្រើននាក់សរសេរនៅពេលតែមួយ និងអាចពិនិត្យបានយ៉ាងឆាប់រហ័ស។ អ្វីដែលសំខាន់គឺជៀសវាង "ចំណុចមិនឃើញ"។ ខ្ញុំចង់មានន័យថា នៅក្នុងថ្នាក់រៀន គ្រូជាញឹកញាប់ផ្តោតលើតែសិស្សមួយចំនួនប៉ុណ្ណោះ។ គ្រូល្អម្នាក់នឹងមិនទុកសិស្សណាម្នាក់ចោលនោះទេ។ ក្នុងសកម្មភាពនិយាយ គាត់នឹងហៅសិស្សដែលអឹមអៀនចូលរួមផងដែរ។ ដូច្នេះ ការសួរសំណួរដោយចៃដន្យ គឺសំខាន់ ដោយមិនពឹងផ្អែកលើអ្នកស្ម័គ្រចិត្តតែប៉ុណ្ណោះ។ ប្រសិនបើច្បាស់តាំងពីដំបូងថាសិស្សគ្រប់គ្នាត្រូវនិយាយ ហើយសកម្មភាពរៀនមិនស្មុគស្មាញពេក ភាពខ្មាសអៀននឹងមិនជាបញ្ហាធំឡើយ។ ចុងក្រោយ កុមារនឹងស្វែងយល់និងសម្របខ្លួនបាន។

ការបង្រៀនអក្ខរក្រម និងភាសាបរទេសគឺជាបញ្ហាស្មុគស្មាញមួយ ដែលយើងមិនអាចពិពណ៌នាបានពេញលេញក្នុងអត្ថបទតូចមួយបែបនេះទេ។ ប៉ុន្តែខ្ញុំសង្ឃឹមថាចំណុចខ្លះៗទាំងនេះ អាចជួយណែនាំគ្រូថ្មីឲ្យចាប់ផ្តើមបានត្រឹមត្រូវ។ រឿងផ្សេងៗទៀតអាចអភិវឌ្ឍបន្ថែមតាមដំណាក់កាលដោយរៀនបច្ចេកទេសមួយម្តងៗ ដោយមិនចាំបាច់គិតច្រើនពេកពីគោលវិធីគ្រូមជ្ឈមណ្ឌលឬសិស្សមជ្ឈមណ្ឌលឡើយ។ ពេលខ្លះ អ្នកបណ្តុះបណ្តាលគ្រូគួរតែឈប់សម្រាកបន្តិច ហើយទុកឱ្យគ្រូព្យាយាមអស់ពីសមត្ថភាពរបស់ពួកគេ។

(1) សូមមើលការពន្យល់នៅក្នុងអត្ថបទពី Dehaene នៅក្នុងការផ្សាយដំបូងរបស់ទស្សនាវដ្តី។

# ការអំពាវនាវរកសំណួរ (ការិយាល័យគ្រូប្រឹក្សាគរុកោសល្យ)

លោកគ្រូ អ្នកគ្រូត្រូវបានទឹកចិត្តឱ្យដាក់ ឬផ្ញើជាសំណួរ និងចែករំលែកពីកង្វល់របស់ខ្លួនជាមួយ ទស្សនាវដ្តី **គន្លឹះអប់រំ** របស់យើងខ្ញុំ។ ការិយាល័យគ្រូប្រឹក្សាគរុកោសល្យរបស់យើង នឹងផ្ដល់ជាដំណោះស្រាយ។ នេះមិនមានន័យថា ខាងយើងអាចដោះស្រាយ គ្រប់បញ្ហាបានទាំងអស់នោះទេ ប៉ុន្តែយ៉ាងហោចណាស់ យើងអាចជួយដល់លោកគ្រូ អ្នកគ្រូក្នុងការវិភាគពីបញ្ហា និងផ្ដល់ជាគន្លឹះចាំបាច់មួយចំនួនសម្រាប់ដោះស្រាយ។ តាមបទពិសោធន៍ និងជំនាញ គ្រូប្រឹក្សាគរុកោសល្យយើងបានទទួលការបណ្ដុះបណ្ដាលពីស្ថាប័នជំនាញនោះគឺ **ដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី** (NGPRD) ហើយចំណេះ ជំនាញ និងបទពិសោធន៍ដែលបានពីការបណ្ដុះបណ្ដាលពិតជារឹងមាំក្នុងការប្រឹក្សាយោបល់ដល់លោកគ្រូ អ្នកគ្រូ។

ដើម្បីបង្កើនប្រសិទ្ធភាព និងភាពពាក់ព័ន្ធនៃចម្លើយ សូមផ្ដល់បរិបទបន្ថែមត្រឹមពីរបីបន្ទាត់ភ្ជាប់ជាមួយសំណួររបស់លោកគ្រូ អ្នកគ្រូ។ សូមពិពណ៌នាពីបញ្ហាដែលលោកគ្រូ អ្នកគ្រូកំពុងប្រឈម ដូចជា **ប្រភេទសាលា (សាលាជំនាន់ថ្មី សាលាស្តង់ដាគំរូ សាលារដ្ឋធម្មតា។ល។) ទំហំសាលា (ផលធៀបគ្រូនិងសិស្ស) កម្រិតសមត្ថភាពសិស្សក្នុងថ្នាក់ ភេទសិស្ស** និងផ្សេងៗទៀត អាស្រ័យលើស្ថានភាព។

អ្នកអាន (លោកគ្រូ អ្នកគ្រូ) ដែលបានផ្ញើបញ្ហាមកខាងយើងខ្ញុំ នឹងទទួលបានការឆ្លើយតបមុនគេតាមរយៈអ៊ីម៉ែលឯកជន ព្រោះវាអាចជាករណីបន្ទាន់។ ផងដែរ យើងនឹងបោះពុម្ពផ្សាយរាល់បញ្ហាដែលលោកគ្រូ អ្នកគ្រូបានផ្ញើមកខាងយើងខ្ញុំ ដោយមិនបញ្ចេញអត្តសញ្ញាណ។ ដើម្បីសុវត្ថិភាព និងភាពងាយស្រួលផ្ទាល់ខ្លួន យើងនឹងមិនចែករំលែកឈ្មោះរបស់លោកគ្រូ អ្នកគ្រូ ឬឈ្មោះសាលាទេ (ប៉ុន្តែលោកគ្រូ អ្នកគ្រូនៅតែអាចលើកឡើងពីឈ្មោះនៅក្នុងសំណើរបស់ខ្លួន ដើម្បីធានាខាងយើងខ្ញុំបានយល់ពីបញ្ហាកាន់តែ ច្បាស់លាស់ មុននឹងផ្ដល់ការវិភាគ និងគន្លឹះដោះស្រាយផ្សេងៗ)។




សូមផ្ញើអ៊ីម៉ែលរបស់អ្នកមកកាន់៖

Educational.magazine.cambodia@gmail.com



# សេវាថែទាំសុខភាពបឋមប្រចាំសាលា

ដោយ៖ **សុីម វណ្ណាសុខាលីលី**

## “ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សក្នុងម៉ោងសិក្សាសំខាន់ជាងមេរៀនទៅទៀត”

**សំណួរ៖** ***ដូចនេះ អ្នកគ្រូអាចណែនាំខ្លួនបន្តិចបានទេ? និងព្រមទាំងណែនាំអំពីប្រវត្តិការងារជាគិលានុបដ្ឋាយិកាផងដែរ?***

ចាស! អ្នកគ្រូ! នៅទីនេះ យើងមានគិលា-នុបដ្ឋាយិកា (school nurse) តែម្នាក់ទេអ្នកគ្រូ បើនិយាយអំពីប្រវត្តិការងារជាគិលានុបដ្ឋាយិកា ខ្ញុំសូមសង្ខេបជូនដូចតទៅ៖

- **២០១៤ - ចាប់ផ្តើមអាជីពដំបូង៖** ខ្ញុំបានបម្រើការងារនៅគ្លីនិកធម្មតាមួយនៅចំការដូងរយៈពេល ២ឆ្នាំ អំឡុងពេលនឹងខ្ញុំបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួនពីរគឺនៅវិទ្យាស្ថានជាតិអប់រំសុខភាពសាធារណៈ និងវិទ្យាស្ថានសុខាភិបាលខេមរភូមិន្ទ។

- **ការថែទាំសុខភាពកម្មករ (រោងក្រពើ/ជីបម៉ុង)៖** បម្រើការងារឯកជនផ្តល់សេវាថែទាំសុខភាពជូនកម្មករនិយោជិតរបស់ក្រុមហ៊ុន ជីបម៉ុង នៅអន្លង់ក្រពើ រយៈពេល ២ ទៅ ៣ឆ្នាំ។

- **បទពិសោធន៍ការងារនៅអង្គការ (RHAC)៖** បម្រើការងារជាង ១ឆ្នាំ ជាជាអ្នកថែទាំសុខភាពផ្លូវចិត្ត និង ការពន្យល់សុខភាពសាធារណៈតាមរយៈសិល្បៈ ល្ខោន និងការច្រៀងតាមស្រុកភូមិ (អតីតអង្គការ UNDP)។

- **ព្រឹត្តិការណ៍កូវីដ-១៩ ការវិលត្រឡប់មកភូមិកំណើត៖** ធ្លាប់បានចុះឈ្មោះជាពេទ្យស្ម័គ្រចិត្ត ហ៊ុន ម៉ាណែត ប្រឈមមុខនៅសមរភូមិកំពង់សោម ប៉ុន្តែដោយសារគ្រួសារបារម្ភ ទើបសម្រេចចិត្តមករស់នៅខេត្តកំពង់ចាមវិញ។

- **២០២២ - បច្ចុប្បន្ន៖** ខ្ញុំបានចូលបម្រើការងារជាគិលានុបដ្ឋាយិកាប្រចាំសាលារៀន ក្រោមកម្មវិធីសាលារៀនជំនាន់ថ្មី (NGS) រហូតមកទល់សព្វថ្ងៃ។

**សំណួរ៖** ***មុនពេលដែលអ្នកគ្រូចូលមកបម្រើការនៅវិទ្យាល័យនេះ តើវិទ្យាល័យនេះមានគិលានុបដ្ឋាយិកាពីមុនមកដែរឬទេ?***

ពីមុនគឺមានគិលានុបដ្ឋាយិកា (school nurse) ដែរ គឺមានចំនួន២នាក់ ប៉ុន្តែនៅពួកគាត់បានការងារនៅកន្លែងផ្សេងក៏ពួកគាត់សម្រេចចិត្តឈប់ពីការងារនៅទីនេះ ហើយសាលាក៏បន្តរើសថ្មី។

**សំណួរ៖** ***សូមអ្នកគ្រូរៀបរាប់ពីគំនិតផ្តួចផ្តើមក្នុងសេវាថែទាំសុខភាពប្រចាំសាលា។***

ចាស! បានមិនអីទេ។ ក្នុងកិច្ចការនេះ ជំហានដំបូងខ្ញុំបានទាក់ទងនឹងសាលារៀននិងពិភាក្សាគ្នារហូតបង្កើតបានជាបេសកកម្ម និង សកម្មភាពស្នូលនៃសេវាសុខភាពប្រចាំសាលាដូចជា៖

**១. ការសង្គ្រោះបឋម និងថែទាំសុខុមាលភាពប្រចាំថ្ងៃ៖**

- ទទួលខុសត្រូវពិនិត្យ និងព្យាបាលជំងឺបែបងាយៗ (ឈឺក្បាល ចុកពោះ) ដើម្បីការពារកុំឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិត និងរៀបចំបញ្ជូនអ្នកជំងឺបន្តពេលចាំបាច់

**២. ការអប់រំសុខភាពតាមកម្រិតវ័យ៖**

- កម្រិតបឋមសិក្សា (ថ្នាក់ទី១ ដល់ទី៦)៖ បង្រៀនអំពី ការបម្រែបម្រួលរាងកាយ ការថែទាំ សម្អាតរាងកាយ និងការដុសធ្មេញ។
- កម្រិតវិទ្យាល័យ (ថ្នាក់ទី៧ ឡើងទៅ): បង្រៀនអំពីជំងឺទឹកនោមផ្អែម ការប្រើប្រាស់សំឡីអនាម័យ ការប្រែប្រួលវ័យជំទង់ និងការលូតលាស់ពេញវ័យ។

**៣. យុទ្ធនាការសុខភាពសាធារណៈ និង កិច្ចសហការជាមួយក្រសួង៖**

សហការជាមួយមន្ទីរពេទ្យរដ្ឋ និងក្រសួង ចុះយុទ្ធនាការ ២ ដល់ ៣ ដងក្នុងមួយឆ្នាំ ដូចជាការចាក់វ៉ាក់សាំងបង្ការជំងឺមហារីកមាត់ស្បូន (HPV) ជូនសិស្សស្រីអាយុចាប់ពី ៩ ឆ្នាំឡើងទៅ។

**៤. ការចុះពិនិត្យគុណភាពចំណីអាហារ និងសោភ័ណភាព៖**

- ចុះពិនិត្យតូបលក់អាហារ ក្នុងសាលារៀនរាល់ ១ ឬ ៦ ខែម្តង ដើម្បីបែងចែកប្រភេទអាហារណាដែលគួរលក់ និងអាហារហាមឃាត់តាមបទបញ្ជារបស់ក្រសួង។






**សំណួរ:** ***តើអ្នកគ្រូអាចរៀបរាប់បានទេពីការងារសំខាន់ៗរបស់អ្នកគ្រូក្នុងនាមជាគិលានុបដ្ឋាយិកាប្រចាំសាលារៀន?***

ចាស! តួនាទីស្នូលជាគិលានុបដ្ឋាយិកាប្រចាំសាលាមានដូចជា៖

- ការងារប្រចាំថ្ងៃរបស់គិលានុបដ្ឋាយិកា គឺការតាមដាន និងថែទាំសុខភាពសិស្សទាំងវេនព្រឹក និងវេនរសៀល ដើម្បីធានាបាននូវសុវត្ថិភាព និងអាយុជីវិតក្នុងម៉ោងសិក្សា។

- តួនាទីគិលានុបដ្ឋាយិកាសាលា គឺផ្តោតលើការសង្គ្រោះបឋម និងរក្សាជង្ហើមអ្នកជំងឺឱ្យរួច និងរក្សាជង្ហើមអ្នកជំងឺឱ្យរួចផុតពីគ្រោះថ្នាក់ដល់អាយុជីវិតមិនមែនជាការផ្តល់ការព្យាបាលឱ្យជាដាច់ស្រឡះនៅនឹងកន្លែងនោះឡើយ។ ឧទាហរណ៍៖ ករណីសិស្សប្រកាច់ និងរឹងដៃរឹងជើងដោយសារការប្រើប្រាស់បារីអេឡិចត្រូនិច Vape) អាចជួយពន្យារពេលវេលា និងសង្គ្រោះជីវិតសិស្សមុនបញ្ជូនដល់មន្ទីរពេទ្យ។

- ការងារប្រចាំសាលាមិនមែនត្រឹមតែការលាបប្រេងកូឡា ឬរឹតបន្តិចបន្តួចនោះទេ ប៉ុន្តែវាទាមទារនូវស្មារតីការត្រៀមលក្ខណៈ និង បច្ចេកទេសខ្ពស់ក្នុងការទប់ស្កាត់ហានិភ័យអាយុជីវិតសិស្សដែលផ្តល់ភាពកក់ក្តៅដល់អាណាព្យាបាល។

**សំណួរ:** ***ក្នុងសិទ្ធិអំណាចជាគិលានុបដ្ឋាយិកា តើមានចំណុចអ្វីខ្លះដែលអ្នកគ្រូអាចធ្វើបាន? តើចំណុចអ្វីខ្លះដែលអ្នកគ្រូមិនអាចធ្វើបាន?***

ចាស! ខ្ញុំសូមបញ្ជាក់ត្រង់នេះបន្ទិចថា៖

- គិលានុបដ្ឋាយិកាប្រចាំសាលារៀន គឺមានសិទ្ធិត្រឹមតែសង្គ្រោះបឋម និងពន្យារពេលដើម្បីរក្សាជីវិតសិស្ស មុនពេលបញ្ជូនបន្តទៅកាន់វេជ្ជបណ្ឌិតជំនាញតែប៉ុណ្ណោះ។
- ចំណែកឯជំនាញខាងសង្គ្រោះបន្ទាន់វិញគឺការយល់ដឹងពីគ្រោះថ្នាក់នៃការស្ទះផ្លូវដង្ហើម និង ការខាំអណ្តាតវិធានការសង្គ្រោះរួមមានការផ្អៀងខ្លួនអ្នកជំងឺឱ្យបានត្រឹមត្រូវនិងការការពារការខាំអណ្តាត មុនពេលបញ្ជូនទៅមន្ទីរពេទ្យ។
- កម្រិតវិជ្ជាជីវៈ និងសញ្ញាបត្រវិញគឺជំនាញដែលអាចចាក់ថ្នាំ ឱ្យថ្នាំតាមអាការៈជំងឺ និងដេររបួសបាន អាស្រ័យតាមកម្រិតសញ្ញាបត្រជាក់ស្តែង។

**សំណួរ:** ***តាមរយៈការលើកឡើងខាងលើ តើកន្លងមកអ្នកគ្រូបានជួយសិស្សយ៉ាងដូចម្តេចខ្លះក្នុងជួយលើសុខភាពផ្លូវចិត្តនិងអារម្មណ៍របស់សិស្ស?***

*១. ការរកឃើញបញ្ហាផ្លូវចិត្តពីកសាងរាងកាយ។* ឧទាហរណ៍៖ ពេលសិស្សមករកសេវាព្យាបាលជំងឺរាងកាយធម្មតា (ដូចជាឈឺពោះ ឬចុកពោះ) តាមរយៈការពិនិត្យសាកសួរ និងជជែកលេង ធ្វើឱ្យដឹងថាពួកគាត់មិនមានជំងឺក្នុងសរីរាង្គកាយទេ ប៉ុន្តែឈឺចាប់លើផ្នែកផ្លូវចិត្ត និង អារម្មណ៍ជំនួសវិញ។

*២. វិធីសាស្ត្រប្រឹក្សាយោបល់ និងស្វែងយល់។* ឧទាហរណ៍៖ ប្រើប្រាស់វិធីសាស្ត្រសាកសួរពីជីវភាពរស់នៅប្រចាំថ្ងៃ និងការយកចិត្តទុកដាក់របស់គ្រួសាររហូតដល់សិស្សបើកចិត្តជជែកទាក់ទងនឹងអារម្មណ៍ការសិក្សា និងទំនាក់ទំនងគ្រួសារ។

*៣. ការបញ្ជ្រាបការគ្រប់គ្រងអារម្មណ៍៖* ផ្តល់ការប្រឹក្សា និង បញ្ជ្រាបវិធីសាស្ត្រគ្រប់គ្រងអារម្មណ៍ ការប្រាស្រ័យទាក់ទងក្នុងគ្រួសារ និង ជាមួយមិត្តភក្តិក្នុងកម្រិតសមស្រប ព្រោះវាអាស្រ័យលើកិច្ចសហការពីសំណាក់សិស្សផ្ទាល់។



**សំណួរ:** ***ក្នុងការងារប្រចាំថ្ងៃ តើស្ថានភាពបែបណាដែលអ្នកគ្រូជួបញឹកញាប់ជាងគេ?***

**ស្ថានភាពជំងឺប្រចាំថ្ងៃ៖** សិស្សមានអាការៈឈឺថ្កាត់ជាប្រចាំដូចជា ចុកពោះ រាគរូស ក្តៅខ្លួន ក្អួត និងប្រកាច់ ដែលមានចំនួនសរុបក្នុងមួយខែមិនក្រោម ៣០០ នាក់ឡើយ (ទាំងកម្រិតបឋមសិក្សានិងវិទ្យាល័យ)។

**ការថតរូបភាពសកម្មភាព៖** ពេលកំពុងជួយសង្គ្រោះ ព្យាបាល លាបរបួស ផ្តល់ថ្នាំ និងពិនិត្យជំងឺបឋម គិលានុបដ្ឋាយិកាតែងតែផ្តិតយករូបភាព សកម្មភាពទាំងនោះ ដើម្បីធ្វើជាបាយការណ៍ជូនដំណឹងដល់អ្នកពាក់ព័ន្ធ និងមន្ត្រីកម្មវិធី។

**ការបង្រៀនជំនួស៖** ស្ថិតនៅក្នុងករណីគ្រូបង្រៀនអវត្តមាន គិលានុបដ្ឋាយិកាតែងតែឆ្លៀតចូលទៅបង្រៀនបញ្ច្រាបអំពីចំណេះដឹងអំពី បញ្ហាសុខភាពកំពុងផ្ទុះ ការបម្រែបម្រួលរូបរាង និងជំងឺទឹកនោមផ្អែមដល់សិស្ស។

**សំណួរ:** ***តើកន្លងមកធ្លាប់មានករណីសិស្សកុហកថាខ្លួនឯងឈឺដែរឬទេ?***

កន្លងមកមាន សិស្សខ្លះគាត់មិនឈឺអីសោះគាត់កុហកថាគាត់ឈឺ។ មូលហេតុនោះគឺ យើងរកឃើញថាគាត់ចង់គេចម៉ោងរៀន ចង់រកលេសបានខ្ជិលមិនចូលរៀនហើយមកសម្រាកនៅបន្ទប់ថែទាំជំងឺរបស់សាលា។ ហើយដំណោះស្រាយក្រោយពេលដែលរកឃើញថា គាត់មិនមានឈឺអ្វីនោះទេ ក៏បានអនុញ្ញាតឱ្យគាត់ទៅថ្នាក់រៀនរបស់គាត់វិញ ឬទៅប្រឡងវិញជាដើម។

**សំណួរ:** ***កន្លងមកអ្នកគ្រូធ្លាប់បានទំនាក់ទំនងជាមួយលោកគ្រូ/អ្នកគ្រូនៅសាលារៀននេះដែរឬទេ? មានលក្ខណៈបែបណា? អំពីបញ្ហាអ្វីខ្លះ?***

សម្រាប់លោកគ្រូអ្នកគ្រូនៅ សាលារៀននេះគឺ ក្រោយពេលដែលគាត់បានដឹង បានទំនាក់ទំនង ក្រោយពេលប្រជុំរួមជាមួយនឹង ការណែនាំសេវាសុខភាពប្រចាំសាលារៀន និងមានគិលានុបដ្ឋាយិការួចមកគឺសង្កេតឃើញថា គាត់(លោកគ្រូ/អ្នកគ្រូ)ភាគច្រើន ពេលដែលគាត់ឈឺវិលមុខ ឬមានអាការៈធ្វើទុក្ខមិនស្រួលក្នុងខ្លួន គឺគាត់មកពិនិត្យ ឬមកសម្រាក មកព្យាបាល និងទទួលថ្នាំតាមអាការៈរោគនៅខាងយើង ភាគច្រើន។ ពេលខ្លះទៀត លោកគ្រូអ្នកគ្រូខ្លះ គាត់ទៅទិញថ្នាំពីខាងក្រៅតាមវេជ្ជបញ្ជារបស់គ្រូពេទ្យនៅខាងក្រៅ ហើយគាត់ពឹងពាក់ឱ្យខាងគិលានុបដ្ឋាយិកាប្រចាំសាលារៀនជួយចាក់ថ្នាំ ដាក់សារ៉ូមកម្លាំង ឬបន្តមើលថែជំងឺជាដើម។

**សំណួរ:** ***តើអ្នកគ្រូយល់ថា លោកគ្រូអ្នកគ្រូ(គ្រូបង្រៀន)នៅសាលារៀនយើងនេះគួរយល់ដឹងអំពីអ្វីខ្លះ ដើម្បីឱ្យពួកគាត់កាន់តែយល់ច្បាស់ពីតួនាទីរបស់គិលានុបដ្ឋាយិកា?***

ករណីនេះមិនពិបាកនោះទេអ្នកគ្រូ នៅរៀងរាល់ពេលប្រជុំប្រចាំខែឬពេលគោរពទង់ជាតិ លោកនាយកតែងតែងយកចិត្តទុកដាក់លើសារៈសំខាន់នៃសេវាសុខភាពប្រចាំសាលារៀន មានគិលានុបដ្ឋាយិកាហើយសេវានេះនៅក្នុងសាលារៀនយើងគឺសំខាន់ក្នុងការផ្តល់សេវាសុខភាពពិនិត្យព្យាបាលជំងឺ ដល់លោកគ្រូអ្នកគ្រូគ្រប់គ្នាក្នុងម៉ោងការងារ។ ប្រសិនបើលោកគ្រូអ្នកគ្រូមាន ការឈឺថ្កាត់ក្នុងម៉ោងការងារលោកគ្រូអ្នកគ្រូអាចមកទទួលសេវាថែទាំសុខភាពនៅសាលាបាន។

ការផ្សព្វផ្សាយនេះបានធ្វើឡើងជារឿយៗ នៅពេលមានការប្រជុំ ការជួបជុំសិស្ស ពេលគោរពទង់ជាតិ ឬប្រជុំបណ្តាញគ្រូបង្រៀន គណៈនាយកជាដើមដែលធ្វើនៅសាលារៀនរបស់យើង ដែលគណៈនាយកធ្លាប់បានបញ្ជាក់យ៉ាងច្បាស់ថាសេវានេះមិនតម្រូវឱ្យបង់ប្រាក់ថ្លៃឈ្នួលក្នុងការព្យាបាលនោះទេ។

លើសពីនេះទៅទៀត គណៈនាយកក៏បានបញ្ជាក់យ៉ាងច្បាស់លើសេវាកម្មដែលគិលានុបដ្ឋាយិកាអាចផ្តល់ជូន ក្នុងករណីពិនិត្យ ព្យាបាលជំងឺនិងសង្គ្រោះបឋមប៉ុណ្ណោះ រីឯសេវាសុខភាពដល់ការចាក់ថ្នាំ ផ្តល់ថ្នាំផ្សំដល់ជាដាច់គឺមិនមាននោះទេសម្រាប់ករណីនេះដើម្បីឱ្យលោកគ្រូអ្នកគ្រូបានយល់ច្បាស់ពីអ្វីដែលអាចទទួលបាន និងសេវាដែលមិនអាចផ្តល់ជូនបាន។

**សំណួរ:** ***តើអ្នកគ្រូយល់ថា លោកគ្រូអ្នកគ្រូ(គ្រូបង្រៀន)នៅសាលារៀនយើងនេះគួរយល់ដឹងអំពីអ្វីខ្លះ ដើម្បីឱ្យពួកគាត់កាន់តែយល់ច្បាស់ពីតួនាទីរបស់គិលានុបដ្ឋាយិកា?***

ក្នុងបរិបទនេះ លោកគ្រូ អ្នកគ្រូសុទ្ធសឹងតែជាអ្នកចេះដឹង ហេតុនេះចំពោះចំណុចដែលពួកគាត់គួរធ្វើមានដូចជា ការទំនាក់ទំនងមកជាមុនសម្រាប់ការជួយព្យាបាលជំងឺពួកគាត់សុទ្ធតែបានគិតល្អិតល្អន់ដែរក្នុងទំនាក់ទំនងរវាងគិលានុបដ្ឋាយិកានិងលោកគ្រូ អ្នកគ្រូ ឬលោកគ្រូអ្នកគ្រូ និងគិលានុបដ្ឋាយិកា ដូចជាមិនមានចំណុចណាដែល គ្រូបង្រៀនមិនគួរធ្វើនោះទេដោយសារក្នុងនាមខ្ញុំជាគិលានុបដ្ឋាយិកាគឺយើងយល់ច្បាស់ពីតួនាទីរបស់ យើងក្នុងសាលារៀនក្នុងទំនាក់ទំនងរបស់គ្រូបង្រៀន និងគិលានុបដ្ឋាយិកា។ ហេតុនេះខ្ញុំគិតថា គាត់អាចទាក់ទងបានគ្រប់ពេលក្នុងម៉ោងការងារ ឱ្យតែទាក់ទងនឹងសេវាសុខភាពដែលបានលើកឡើងខាងលើ។

**សំណួរ:** *តើអ្នកគ្រូចង់ឱ្យពួកគាត់ធ្វើអ្វី (ឬមិនត្រូវធ្វើអ្វី)ដើម្បីឱ្យកិច្ចសហការកាន់តែប្រសើរឡើង?*

ក្នុងបរិបទនេះ លោកគ្រូ អ្នកគ្រូសុទ្ធសឹងមាន៖

- **ការយល់ដឹង និងកិច្ចសហការ៖** លោកគ្រូ អ្នកគ្រូសុទ្ធសឹងជាអ្នកចេះដឹង និងបានពិចារណាល្អិតល្អន់រួចហើយ មុនពេលទំនាក់ទំនងមករកសេវាព្យាបាល។
- **ភាពបត់បែនក្នុងទំនាក់ទំនង៖** គ្មានចំណុចណាមួយដែលគ្រូបង្រៀនមិនគួរធ្វើនោះឡើយ ព្រោះគិលានុបដ្ឋាយិកាបានយល់ច្បាស់ពីតួនាទី និងដែនកំណត់ក្នុងកិច្ចសហការរវាងគ្នា។
- **ភាពទាក់ទងគ្នាក្នុងម៉ោងការងារ៖** លោកគ្រូ អ្នកគ្រូអាចទាក់ទងមកបានគ្រប់ពេលក្នុងម៉ោងការងារ ឱ្យតែពាក់ព័ន្ធនឹងសេវាថែទាំសុខភាពដែលបានកំណត់។

**សំណួរ:** *តើមានសិស្សដែលមកពិគ្រោះជាមួយអ្នកគ្រូអំពីបញ្ហាផ្លូវចិត្ត ឬបញ្ហាអារម្មណ៍ដែរទេ? តើពួកគេចូលមកជួបអ្នកគ្រូដោយរបៀបណា? តើអ្នកគ្រូមានប្រតិកម្ម ឬឆ្លើយតបទៅវិញយ៉ាងដូចម្តេច? តើអ្នកគ្រូមានវិធានការ ឬដំណោះស្រាយអ្វីខ្លះដែលត្រូវដាក់ឱ្យអនុវត្ត? តើការតាមដានស្ថានភាព (Follow-up) ឬសហការជាមួយក្រុមគ្រួសារសិស្សធ្វើឡើងយ៉ាងដូចម្តេច?*

- **ការស្វែងយល់ពីបញ្ហាផ្លូវចិត្ត៖** សិស្សភាគច្រើនមិនដែលប្រាប់ផ្ទាល់ថាមានបញ្ហាផ្លូវចិត្តនោះទេ ដោយពួកគាត់តែងមកជួបជជែកពីអាការៈរាងកាយផ្សេងៗ មុនពេលរកឃើញថាមានវិបត្តិផ្លូវចិត្តនៅពីក្រោយ។
- **ករណីសិក្សាជាក់ស្តែង៖** ករណីសិស្សម្នាក់ ដែលឪពុកម្តាយទៅធ្វើការនៅប្រទេសថៃ ហើយរស់នៅជាមួយពូដែលបានបំពានផ្លូវភេទ និងផ្លូវអារម្មណ៍យ៉ាងធ្ងន់ធ្ងរ។

**សកម្មភាពសង្គ្រោះ និងការប្រឹក្សា៖** ក្រោយពេលពិនិត្យឃើញស្លាកស្នាមអារដៃចង់ធ្វើអត្តឃាត គិលានុបដ្ឋាយិកាបានបញ្ចុះបញ្ចូលឱ្យសិស្សមีความក្លាហានប្រាប់ឪពុកម្តាយ ដើម្បីជួយដោះស្រាយ និងចាត់វិធានការទាន់ពេលវេលា។

**សំណួរ:** *តើកន្លងមកការប្រាស្រ័យទាក់ទងរបស់អ្នកគ្រូ ជាមួយសិស្សមានសភាពបែបណា? តើអ្នកគ្រូមានធ្វើការជាមួយអាណាព្យាបាលសិស្សដែរឬទេ? តើក្នុងករណីបែបណាខ្លះ?*

ខ្ញុំធ្លាប់បានជួបជាមួយឪពុកម្តាយដែរកាលពីពេលកន្លងទៅនេះ។ ខ្ញុំរកឃើញថា៖

- **ផលប៉ះពាល់គ្រួសារលើការសិក្សា៖** សិស្សស្រីម្នាក់ដែលធ្លាប់ជាសិស្សរៀនពូកែ បានបាត់បង់ការផ្តោតអារម្មណ៍ និងធ្លាក់លទ្ធផលសិក្សាព្រោះតែបញ្ហាឪពុកម្តាយបែកបាក់គ្នាទៅមានគ្រួសារថ្មីរៀងៗខ្លួន។
- **កិច្ចអន្តរាគមន៍ និងការកោះហៅអាណាព្យាបាល៖** ក្រោយពេលសិស្សមករឹក្សា គិលានុបដ្ឋាយិកាបានរាយការណ៍ជូនគណៈគ្រប់គ្រង និងបានកោះហៅ អាណាព្យាបាលមកប្រជុំប្រឹក្សាយោបល់នៅទីចាត់ការរួមគ្នា។

**សំណួរ:** *ការយល់ឃើញរបស់គិលានុបដ្ឋាយិកាលើបញ្ហាប្រឈមក្នុងការថែទាំសុខភាព*

**១. បញ្ហាប្រឈមជាមួយសិស្ស និងអាណាព្យាបាល៖**

- ការយល់ច្រឡំពីសំណាក់សិស្ស និងអាណាព្យាបាល ដែលរំពឹងថាគ្រូពេទ្យប្រចាំសាលាត្រូវព្យាបាលជំងឺឱ្យជាដាច់ស្រឡះ ទោះបីជាជំងឺនោះកើតឡើងក្រៅម៉ោងសិក្សាក៏ដោយ។
- ការពន្យល់បកស្រាយគោលការណ៍សេវាថែទាំសុខភាព (ឧទាហរណ៍៖ ការផ្តល់ថ្នាំព្យាបាលត្រឹមពេលឈឺនៅសាលា ប៉ុន្តែមិនមានការបន្តផ្តល់ថ្នាំលេបសម្រាប់ព្យាបាលឱ្យជាដាច់នៅផ្ទះនោះឡើយ)។

**២. សម្ពាធផ្លូវចិត្តលើការងាររដ្ឋបាល៖**

- ការខ្វះជំនាញស្ទាត់ជំនាញលើការងាររដ្ឋបាល និងការធ្វើរបាយការណ៍កុំព្យូទ័រ ដោយសារការបណ្តុះបណ្តាលពីសាលា និងមហាវិទ្យាល័យគឺផ្តោតលើការអនុវត្តផ្ទាល់ផ្នែកវេជ្ជសាស្ត្រ (ការចាក់ថ្នាំ ផ្តល់ថ្នាំ និងជួយសង្គ្រោះ)។
- ការអសកម្មក្នុងការប្រើប្រាស់កុំព្យូទ័ររយៈពេល ៥ ទៅ ៦ឆ្នាំ បង្កើតឱ្យមានការលំបាកក្នុងការបំពេញកិច្ចការរដ្ឋបាលជូនសាលារៀននិងមន្ត្រីកម្មវិធី។

**សំណួរ:** *តើអ្នកគ្រូមានជាមតិផ្តាំផ្ញើអ្វីទេដល់គិលានុបដ្ឋាយិកានៅតាមសាលារៀនដទៃដែរឬទេ? បើមានសូមលើកជាចំណុចៗ។*

ក្នុងនាមយើងជាគ្រូពេទ្យ យើងគួរតែមាន៖

- **ការយល់ដឹងពីដែនកំណត់វិជ្ជាជីវៈ៖** គ្រូពេទ្យត្រូវស្គាល់ច្បាស់ពីតួនាទី និងដែនកំណត់នៃការងាររបស់ខ្លួន ដោយមិនត្រូវព្យាយាម ធ្វើអ្វីហួសពីសមត្ថភាពនោះឡើយ។
- **ការគោរពក្រមសីលធម៌ និងភាពអត់ធ្មត់៖** ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈជានិច្ច ទោះបីជាត្រូវប្រឈមមុខនឹងស្ថានភាពអ្នកជំងឺបែបណាក៏ដោយ។
- កុំផ្តល់ការព្យាបាលលើសពីសមត្ថភាពដែលអាចបង្កគ្រោះថ្នាក់ដល់អាយុជីវិតរបស់អ្នកជំងឺ ឬសិស្ស។

# ពីការបង្រៀនភាសាអង់គ្លេសបែបសប្បាយៗទៅជាការប្រើប្រាស់ភាសា៖ វិធីពីរយ៉ាងក្នុងការប្រើប្រាស់សម្ភារៈយថាភូតក្នុងថ្នាក់រៀន

ដោយ៖ **Juliette Sochacki** បកប្រែដោយ៖ **ស៊ី ហុង**

អ្នកទើបតែរកបានវីដេអូបង្រៀនដ៏ល្អមួយដែលប្រើប្រាស់ភាសាអង់គ្លេសបែបកំប្លុកកំប្លែង ធម្មជាតិ និងជាក់ស្តែង។ សិស្សអ្នកនឹងចូលចិត្តមើល ប៉ុន្តែគ្រូគ្រប់រូបនឹងមានសំណួរមួយក្នុងចិត្តថា "តើខ្ញុំនឹងត្រូវធ្វើដូចម្តេចជាមួយនឹងវីដេអូមួយនេះ"?

នៅក្នុងអត្ថបទមុន យើងក្រឡេកមើលពីសារៈសំខាន់របស់សម្ភារៈយថាភូត ក្នុងការជួយឱ្យចេះប្រើប្រាស់ភាសាអង់គ្លេស ដោយមិនមែនគ្រាន់តែរៀនត្រឹមតែភាសាអង់គ្លេសប៉ុណ្ណោះទេ។ យើងក៏បានស្រាវជ្រាវពីរបៀបស្វែងរក និងរៀបចំប្រភពសិក្សាផ្សេងៗផងដែរ។ ឥឡូវវាជាជំហានបន្ទាប់គឺនិយាយពីការការប្រើប្រាស់សម្ភារៈបង្រៀនទាំងនោះក្នុងថ្នាក់រៀនជាក់ស្តែង។ មានវិធីចម្បងពីរយ៉ាងក្នុងកាប្រើប្រាស់៖

- វិធីយល់ដឹងសើៗ (The light-touch approach) ជាវិធីដែលអ្នកគ្រាន់តែជម្រុញការចង់ចេះ ចង់ដឹង ភាពសប្បាយរីករាយពេញចិត្ត និង ការសិក្សាឈ្វេងយល់
- វិធីយល់ដឹងស៊ីជម្រៅ (The deep-dive approach) ជាវិធីដែលអ្នកបម្លែងសម្ភារៈបង្រៀនទៅជាឧបករណ៍រៀន ដើម្បីឈ្វេងយល់ស៊ីជម្រៅពីភាសាវប្បធម៌ និងជម្រុញការគិតស៊ីជម្រៅ។

ក្នុងអត្ថបទនេះ យើងនឹងក្រឡេកមើលទាំងពីរ ហើយមើលថាតើវីដេអូឬអត្ថបទតែមួយអាចបម្រើឱ្យគ្រប់គោលដៅផ្សេងៗគ្នាដោយពឹងផ្អែកលើអ្វីដែលគ្រូចង់ឱ្យសិស្សខ្លួនចេះពីវីដេអូនោះ។

តស់ចាប់ផ្តើមប្រើប្រាស់សម្ភារៈយថាភូត ភ្លាមៗតែម្តង ដោយនិយាយពីវិធីយល់ដឹងសើៗ ដែលជាវិធីមួយនិយាយពី ការធ្វើឱ្យការសិក្សាងាយស្រួល សប្បាយៗ និងបង្កើនទំនុកចិត្ត ជួយសិស្សឱ្យមានសប្បាយរីករាយជាមួយភាសាជាក់ស្តែងដោយមិនខ្វល់ច្រើនពីវេយ្យាករណ៍។

## វិធីយល់ដឹងសើៗ ធ្វើឱ្យការសិក្សាងាយស្រួលនិងគួរឱ្យចាប់អារម្មណ៍

### វត្ថុបំណងចម្បង

- ការបន្សាំភាសាដោយភាពសប្បាយរីករាយ៖ វិធីសាស្ត្រនេះជួយឱ្យសិស្សស្តាប់ អាន និងរីករាយជាមួយភាសាអង់គ្លេសជាក់ស្តែងដោយមិនចាំបាច់វិភាគវែកញែកគ្រប់ពាក្យ ដែលជំរុញចំណង់ចំណូលចិត្តរៀនសូត្រតាមធម្មជាតិ។
- **វិធីសាស្ត្រទាក់ទាញចំណាប់អារម្មណ៍៖** ជំនួសឱ្យការឱ្យកិច្ចការមើលវីដេអូទាំងស្រុងដែលធ្វើឱ្យសិស្សធុញ គ្រូបង្រៀនចាក់វីដេអូខ្លី និងសួរសំណួរដើម្បីបំផុសឱ្យពួកគេចង់តាមដានដោយខ្លួនឯង។

## សកម្មភាពសាមញ្ញ

គ្រូអាចប្រើសម្ភារៈយថាភូត តាមវិធីសាមញ្ញប្រកបដោយភាពសប្បាយរីករាយដើម្បីបង្កើនទំនុកចិត្តនិងភាពចង់ចេះចង់ដឹង។

- ការយល់ជាសកលៈ គ្រូសួរសំណួរសាមញ្ញដូចជា តើវីដេអូនេះនិយាយពីអ្វី? តើនរណាកំពុងនិយាយ? តើវាកើតឡើងនៅទីណា?
- ប្រតិកម្មផ្ទាល់ខ្លួនៈ គ្រូឱ្យសិស្សឱ្យបញ្ចេញមតិយោបល់ តើអ្នកចូលចិត្តវាទេ? តើអ្នកនឹងធ្វើបែបនោះឬទេ? តើមានអ្វីធ្វើឱ្យអ្នកភ្ញាក់ផ្អើលទេ?
- ល្បែងស្តាប់ចាប់ចំណុចពិសេសៈ គ្រូឱ្យសិស្សស្តាប់ ឬមើលដោយយកចិត្តទុកដាក់ដើម្បីកត់ចំណាំចំណុចកំប្លុកកំប្លែងឬសំនួនពាក្យដែលខ្លួនចេះ។ ល្បែងនេះអាចជួយបង្កើនការផ្តោតអារម្មណ៍សិស្សអំឡុងពេលមើលនិងស្តាប់។
- សកម្មភាព Mini-Debate ឬ Quick Polls ៖ ជាសកម្មភាពនិយាយខ្លីៗដែលអាចឱ្យសិស្សបញ្ចេញមតិភ្លាមៗដោយប្រើប្រាស់ភាសាដែលសិស្សចេះ មិនផ្តោតសំខាន់ខ្លាំងលើវេយ្យាករណ៍ល្អឥតខ្ចោះនោះទេ។

## អត្ថប្រយោជន៍

វិធីយល់ដឹងសើៗជួយជម្រុញសិស្សភ្លាមៗ ដោយមិនចាំបាច់គិតច្រើន។ គ្រូអាចប្រើសម្ភារៈយថាភូតដោយពុំបាច់រៀបចំច្រើនដែលល្អបំផុតសម្រាប់ថ្នាក់រៀនដែលសិស្សមានសមត្ថភាពចម្រុះ ឬសម្រាប់ពេលដែលគ្រូចង់ឱ្យបរិយាកាសថ្នាក់រៀនភាសាអង់គ្លេសរស់រវើក។

## ដែនកំណត់

- ការរៀនតាមបែបសប្បាយ (Fun & Exposure): ផ្តោតលើការកសាងទំនុកចិត្ត អារម្មណ៍វិជ្ជមាន និងការបន្សាំខ្លួនទៅនឹងភាសា ដោយមិនទាមទារឲ្យសិស្សប្រើប្រាស់ភាសានោះភ្លាមៗក្នុងការនិយាយ ឬសរសេរឡើយ។
- ការសិក្សាស៊ីជម្រៅ (Deep-dive Approach): ជាវិធីសាស្ត្របន្ថែមពីលើភាពសប្បាយរីករាយ ដោយយកសម្ភារៈសិក្សាជាក់ស្តែង (Authentic materials) មកប្រើជាឧបករណ៍ ដើម្បីធានាថា សិស្សពិតជាបានយល់ដឹង និងចេះអនុវត្តភាសានោះបានយ៉ាងពិតប្រាកដ។

# វិធីសាស្ត្រសិក្សាស៊ីជម្រៅៈ ការរៀនតាមការរុករក

## វត្ថុបំណងចម្បង

វិធីសាស្ត្រសិក្សាស៊ីជម្រៅ គឺប្រើប្រាស់សម្ភារៈយថាភូតដែលបម្លែងទៅជាឧបករណ៍សិក្សាដ៏មានប្រសិទ្ធភាព ដោយផ្តោតសំខាន់លើ ការវិភាគ ការយល់ដឹង និងការប្រើប្រាស់ភាសាយ៉ាងសកម្ម។ សិស្សមិនត្រឹមតែមើលឬអានប៉ុណ្ណោះទេ ពួកគេឈ្វេងយល់វាក្យសព្ទ វេយ្យាករណ៍ និងវប្បធម៌ ហើយបន្ទាប់មកប្រើប្រាស់ភាសាដោយផ្ទាល់ខ្លួនដើម្បីឆ្លើយតប។

## សកម្មភាពសាមញ្ញ

គ្រូអាចណែនាំសិស្សឱ្យធ្វើការជាមួយសម្ភារៈយថាភូតយ៉ាងទូលំទូលាយតាមរយៈសកម្មភាពខាងក្រោមៈ

- ការវិភាគភាសាគោលដៅៈ ឱ្យសិស្សកត់សម្គាល់សំនួនភាសាសំខាន់ៗ កិរិយាសព្ទ ឬល្បះ និងឈ្វេងយល់ពីការប្រើប្រាស់ចំណុចភាសាទាំងអស់នោះក្នុងបរិបទជាក់ស្តែង។
- ការរៀនដោយផ្អែកលើកិច្ចការៈ គ្រូឱ្យបង្កើតកិច្ចការចេញពីសម្ភារៈយថាភូត ដូចជា សរសេរឈុតឆាកសាច់រឿងឡើងវិញ ឆ្លើយតបទៅនឹងអត្ថបទ ឬបង្កើតបទសន្ទនាខ្លីៗ។
- ការជួយគាំទ្រការយល់ដឹងបន្ថែមៈ មើលឬអានឱ្យយល់គំនិតខ្លឹមសារទូទៅ និងផ្តោតលើសេចក្តីលម្អិត វាក្យសព្ទ ការលើកដាក់ សំឡេង ឬ លក្ខណៈវប្បធម៌ ព្រមអនុវត្តអ្វីដែលបានរៀនជាសកម្មភាពនិយាយ និងសរសេរ

## អត្ថប្រយោជន៍

វិធីសាស្ត្រសិក្សាស៊ីជម្រៅ ជួយពង្រឹងការយល់ដឹងភាសា និងវប្បធម៌ ដោយជម្រុញសិស្សឱ្យចេះប្រើប្រាស់និងទទួលយកភាសាថ្មីឡើងវិញ អភិវឌ្ឍការគិតស៊ីជម្រៅ និងបង្កើនផលិតភាពកិច្ចការតាមរយៈសម្ភារៈឧបទេសពិតជាក់ស្តែង។

## ដែនកំណត់

- ទាមទារពេលរៀបចំច្រើន ហើយបើខ្លាំងពេក អាចធ្វើឱ្យថ្នាក់រៀនបាត់បង់ភាពរីករាយ និងប្រែជាតឹងរ៉ឹងបែបបុរាណ។
- តម្លៃ/អត្ថប្រយោជន៍ៈ ជួយជំរុញសិស្សឱ្យផ្លាស់ប្តូរពី "ការយល់ដឹងអសកម្ម" ទៅជា "ភាពជំនាញសកម្ម" ក្នុងការប្រើប្រាស់ភាសាយ៉ាងមានប្រសិទ្ធភាព។

### ឧទាហរណ៍នៃវិធីសាស្ត្រ Light and Deep Touch

### រឿងអ្នកជិតខាងថ្មីរបស់ George







កម្រិត៖ A2-B1

តំណភ្ជាប់៖ [Curious George – George´s New Neighbours]

វិធីសាស្ត្រសិក្សាបែបសើៗនិងស៊ីជម្រៅ៖ សូមមើលនិងឆ្លើយតប វត្ថុបំណងសំខាន់នៃវិធីសាស្ត្រនេះគឺសិស្សសប្បាយរីករាយនឹងរឿងនិងបង្កើនការយល់ដឹងតាមរយៈការស្តាប់។ ងាយៗសម្រាប់សកម្មភាពនេះ សិស្សអាចមើលម្តង បន្ទាប់មកឆ្លើយសំណួរងាយៗ៖

“តើ George ទៅទិញអីវ៉ាន់នៅឯណា? តើមានបញ្ហាអ្វី? តើនរណាជួយ George ចុងក្រោយ?”

ឬចែករំលែកមតិជាដៃគូ “តើអ្នកធ្លាប់សាកអាហារថ្មីហើយមានអារម្មណ៍ថាច្របូកច្របល់ទេ? តើអ្នកសប្បាយរីករាយនឹងចុងបញ្ចប់រឿងដែរឬទេ? ឬចាប់អារម្មណ៍ពេលសប្បាយរីករាយនិងភ្ញាក់ផ្អើល (George ភ្លក្សម្ហូបវៀតណាមថ្មីនិងអារម្មណ៍ច្របូកច្របល់ជាមួយគ្រឿងផ្សំ) ដូចបានលើកឡើងពីមុន ពេលវេលាពិតជាសំខាន់ណាស់នៅត្រង់នេះ ព្រោះជាមួយនឹងការប្រើប្រាស់វិធីសាស្ត្រសិក្សាយល់ដឹងបែបសើៗ អ្នកត្រូវតែធ្វើវីដេអូឱ្យខ្លី ចាប់ពី១០ទៅ១៥នាទី ដូច្នេះទើបវាមិនគួរឱ្យធុញនិងមិនធ្វើឱ្យបាត់បង់ចំណាប់អារម្មណ៍។

# វិធីសាស្ត្រ Deep Dive៖ បង្កើនភាសានិងការគិតស៊ីជម្រៅ

អ្នកមានជម្រើសពីរ ក្នុងការប្រើប្រាស់វិធីសាស្ត្រសិក្សាបែបស៊ីជម្រៅ ដោយអ្នកអាចផ្តោតសំខាន់លើខ្លឹមសារ និង ផ្តោតសំខាន់លើភាសា។ មែនទែនទៅ អ្នកអាចផ្តោតទាំងពីរលើសម្ភារៈយថាភូតតែមួយ។

### ផ្តោតលើខ្លឹមសារ (Focus on content)

- សេចក្តីសង្ខេប/ការធ្វើបទបង្ហាញ (Summary / Presentation) ៖ សិស្សនិទានរឿងឡើងវិញដោយប្រើប្រាស់សម្តីផ្ទាល់ខ្លួន។
- ស្រមើស្រមៃផ្នែកបន្ទាប់នៃសាច់រឿង (Imagine the next part) ៖ ទស្សន៍ទាយនូវអ្វីដែលអាចនឹងកើតឡើងបន្ទាប់ ប្រសិនបើ George ត្រឡប់ទៅវិញនៅសប្តាហ៍ក្រោយ ឬហៅមិត្តភក្តិឱ្យសាកភ្លក្សម្ហូបវៀតណាម។
- ការជជែកពិភាក្សា/ការឆ្លុះបញ្ចាំង (Discussion / Reflection)៖ ឱ្យសិស្សចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនពីការសាកភ្លក្សអាហារដែលមិនធ្លាប់ហូបពីមុនមក

### ផ្តោតលើភាសា (Focus on language)

- វាក្យសព្ទ (Vocabulary) ៖ សិស្សគូសចំណាំសំនួនវាក្យសព្ទទាក់ទងនឹងការទិញអីវ៉ាន់ឬម្ហូបអាហារដូចជា រើសយក (Pick) ភ្លក្ស (Taste) លាយចូលគ្នា (Mix) វិធីធ្វើម្ហូប (Recipe) និង គ្រឿងផ្សំ (Ingredients)។
- វេយ្យាករណ៍/ការបំបែកកិរិយាសព្ទ៖ សិស្សអនុវត្តការប្រើប្រាស់ could/ couldn´t ឬ would/ wouldn´t ។ មើលពីចំណុចទាំងនេះពីវីដេអូហើយសាកប្រើប្រាស់វា។
- ការផលិតភាសា (Production) ៖ សិស្សបង្កើតបទសន្ទនាខ្លី ឬរឿងខ្លីៗ ដោយប្រើពាក្យថ្មីនិងកាលអតីតកាល (Past Tense) ដែលទាក់ទងនឹងការផ្សងព្រេងរបស់ George ជាគំរូ។

### ផ្តោតលើភាសា (Focus on language)

- វាក្យសព្ទ (Vocabulary) ៖ សិស្សគូសចំណាំសំនួនវាក្យសព្ទទាក់ទងនឹងការទិញអីវ៉ាន់ឬម្ហូបអាហារដូចជា រើសយក (Pick) ភ្លក្ស (Taste) លាយចូលគ្នា (Mix) វិធីធ្វើម្ហូប (Recipe) និង គ្រឿងផ្សំ (Ingredients)។
- វេយ្យាករណ៍/ការបំបែកកិរិយាសព្ទ៖ សិស្សអនុវត្តការប្រើប្រាស់ could/ couldn't ឬ would/ wouldn't ។ មើលពីចំណុចទាំងនេះពីវីដេអូហើយសាកប្រើប្រាស់វា។
- ការផលិតភាសា (Production) ៖ សិស្សបង្កើតបទសន្ទនាខ្លី ឬរឿងខ្លីៗ ដោយប្រើពាក្យថ្មីនិងកាលអតីតកាល (Past Tense) ដែលទាក់ទងនឹងការផ្សងព្រេងរបស់ George ជាគំរូ។

### សុខភាពឌីជីថល

កម្រិត៖ A2-B1

តំណភ្ជាប់៖ *News in Levels – Digital Health*

### ដៃនកំណត់

- ការរៀនតាមបែបសប្បាយ (Fun & Exposure): ផ្តោតលើការកសាងទំនុកចិត្ត អារម្មណ៍វិជ្ជមាន និងការបន្សាំខ្លួនទៅនឹងភាសា ដោយមិនទាមទារឲ្យសិស្សប្រើប្រាស់ភាសានោះភ្លាមៗក្នុងការនិយាយ ឬសរសេរឡើយ។
- ការសិក្សាស៊ីជម្រៅ (Deep-dive Approach): ជាវិធីសាស្ត្របន្ថែមពីលើភាពសប្បាយរីករាយ ដោយយកសម្ភារៈសិក្សាជាក់ស្តែង (Authentic materials) មកប្រើជាឧបករណ៍ ដើម្បីធានាថា សិស្សពិតជាបានយល់ដឹង និងចេះអនុវត្តភាសានោះបានយ៉ាងពិតប្រាកដ។

# វិធីសាស្ត្រ Deep-Dive៖ អភិវឌ្ឍភាសា និងការគិតស៊ីជម្រៅ

តាមរយៈវិធីសាស្ត្រ Deep-Dive គ្រូអាចផ្តោតលើខ្លឹមសារ (content) ឬភាសា (language) ឬបញ្ចូលទាំងពីរជាមួយគ្នាក៏បាន។

### ផ្តោតលើខ្លឹមសារ (Focus on content)

- ការសង្ខេប/ការបង្ហាញ (Summary / Presentation) ៖ សិស្សពន្យល់ខ្លឹមសារអត្ថបទទាក់ទងពេលវេលាប្រើអេក្រង់ទូរសព្ទ (screen time) និង ផលប៉ះពាល់របស់វាដោយប្រើពាក្យរបស់ខ្លួន។
- ស្រមៃបន្ត (Imagine the next part) ៖ សិស្សគិតថា អ្វីអាចកើតឡើងបន្តទៀត ប្រសិនបើមនុស្សបន្តប្រើអេក្រង់ទូរសព្ទច្រើនបែបនេះ? តើសាលារៀនឬឪពុកម្តាយអាចមានដំណោះស្រាយអ្វីខ្លះ?
- ការពិភាក្សា / ការឆ្លុះបញ្ចាំង (Discussion / Reflection) ៖ សិស្សពិភាក្សាជាក្រុមតូច ដើម្បីជជែកអំពីសំណួរដូចជា៖
  - "តើការប្រើអេក្រង់ទូរសព្ទតែងតែអាក្រក់មែនទេ?
  - "តើយើងអាចរក្សាតុល្យភាពរវាងបច្ចេកវិទ្យានិងសុខភាពបានយ៉ាងដូចម្តេច?"
  - "បន្ទាប់ពីអានអត្ថបទនេះ តើអ្នកនឹងផ្លាស់ប្តូរទម្លាប់អ្វីខ្លះរបស់អ្នក?"

  សកម្មភាពទាំងនេះ ជួយអភិវឌ្ឍការយល់ដឹងខ្លឹមសារ និងការគិតវិភាគរបស់សិស្ស។

### ផ្តោតលើភាសា (Focus on langage)

- វាក្យសព្ទ (Vocabulary) ៖ សិស្សគូសចំណាំនិងប្រើពាក្យសំខាន់ៗឡើងវិញដូចជា ពេលវេលាប្រើអេក្រង់ទូរសព្ទ (Screen time) ការផ្តោតអារម្មណ៍ (Focus) ស្រទាប់ខួរក្បាលខាងក្រៅ (Cortex) ដំណេក (Sleep) អរម៉ូនជំនួយការគេង ( Melatonin) ភាពតានតឹងភ្នែកដោយសារឧបករណ៍ឌីជីថល (Digital eye strain)។ សិស្សផ្គូផ្គងពាក្យជាមួយនឹងអត្ថន័យ ឬគូររូបតូចៗដើម្បីតំណាងឱ្យពាក្យនីមួយៗ។
- វេយ្យាករណ៍ (Grammar) ៖ ពិនិត្យ និងអនុវត្ត comparatives (ការប្រៀបធៀប) ដូចជា "more screen time → more tired" និង cause and effect (ហេតុ និងផល) ដូចជា "Too much screen time leads to..." ។
- ការផលិតភាសា (production) ៖
  - សំណេរ (Writing) ៖ សិស្សសរសេរកថាខណ្ឌខ្លីមួយក្រោមចំណងជើង "My Screen Habits" (ទម្លាប់ប្រើអេក្រង់ទូរសព្ទរបស់ខ្ញុំ) ឬ "Healthy Tech Rules for Students" (ច្បាប់ប្រើបច្ចេកវិទ្យាដែលមានសុខភាពល្អសម្រាប់សិស្ស)។

- ការនិយាយ (Speaking)៖ សិស្សសន្ទនាគ្នាជាដៃគូ ដើម្បីផ្តល់ដំបូន្មាន ឧទាហរណ៍៖ "Don't use your phone before bed!" "Try reading instead!"

## របៀបជ្រើសរើសរវាងវិធីសាស្ត្រទាំងពីរ

តាមរយៈឧទាហរណ៍ទាំងអស់នេះ វាសឱ្យឃើញថា សម្ភារៈយថាភូតតែមួយអាចប្រើសម្រាប់គោលបំណងផ្សេងៗគ្នា។ យើងអាចជ្រើសរើសរវាងវិធីសាស្ត្រ "light-touch" and "deep-dive" ដោយផ្អែកលើវត្ថុបំណង កម្រិតថ្នាក់ និងពេលវេលា។ ប៉ុន្តែគ្រូមិនចាំបាច់ត្រូវជ្រើសរើសតែវិធីសាស្ត្រមួយប៉ុណ្ណោះទេ។ អ្វីដែលសំខាន់គឺរក្សាតុល្យភាពរវាងវិធីសាស្ត្រទាំងពីរ។ ជួនកាលសិស្សគ្រាន់តែត្រូវការសើចប្រហែល១០នាទីពេលមើលវីដេអូជីវចល។ ពេលខ្លះទៀតវាគួរតែជាឱកាសក្នុងការសិក្សាស៊ីជម្រៅពីវីដេអូដោយធ្វើវីដេអូទៅជាឧបករណ៍សម្រាប់ការរៀនភាសាវិញ។

### ១. គោលដៅនៃកម្មវិធីសិក្សា (Your Course Objectives)

- វិធីសាស្ត្រ Light-Touch គឺសមស្របបំផុត ប្រសិនបើគ្រូមានគោលដៅដើម្បីជម្រុញទឹកចិត្តនិងធ្វើឱ្យសិស្សចាប់អារម្មណ៍។
- វិធីសាស្ត្រ Deep-Dive មានប្រសិទ្ធភាពជាងប្រសិនបើគ្រូមានគោលដៅដើម្បីអភិវឌ្ឍភាសាជាក់លាក់ដូចជា វេយ្យាករណ៍ វាក្យសព្ទ ឬ ជំនាញកម្រិតខ្ពស់។

### ២. កម្រិតសិស្ស (Student Level)

- សិស្សកម្រិតដំបូង (Beginners) នឹងទទួលបានអត្ថប្រយោជន៍ពីការផ្តោតលើការយល់អត្ថបទ និងការសប្បាយរីករាយ ដូច្នេះវិធីសាស្ត្រ Light-Touch ជួយបង្កើនទំនុកចិត្តរបស់ពួកគេ។
- សិស្សកម្រិតមធ្យម ឬខ្ពស់ (Intermediate or Advanced) អាចដោះស្រាយ វិភាគ និងប្រើភាសាឡើងវិញយ៉ាងសកម្ម ដូច្នេះវិធីសាស្ត្រ Deep-Dive សមស្របណាស់សម្រាប់ពួកគេ។

### ៣. ប្រភេទសម្ភារៈឧបទេសជាក់ស្តែង (Type of material)

- វីដេអូឬអត្ថបទកំប្លុកកំប្លែងខ្លីៗ សមស្របសម្រាប់វិធីសាស្ត្រ Light-Touch ។
- អត្ថបទ របាយការណ៍ ឬបទសម្ភាសន៍ផ្សេងៗ សមស្របសម្រាប់ការវិភាគស៊ីជម្រៅ និងការប្រើប្រាស់ភាសាដែលមានបែបបទត្រឹមត្រូវ។

### ៤. ពេលវេលានិងបរិបទថ្នាក់រៀន (Available time and classroom context)

- គិតពីរយៈពេលថ្នាក់រៀននីមួយៗមានស្រាប់សម្រាប់សកម្មភាពនិងតម្រូវការរបស់ស្ថាប័ន។
- សកម្មភាពខ្លីៗនិងសប្បាយៗអាចនឹងសមស្របបំផុតសម្រាប់កាលវិភាគសិក្សាដែលមមាញឹក ដោយឡែករយៈពេលថ្នាក់រៀនវែងឬយូរសមស្របសម្រាប់ការឈ្វេងយល់ស៊ីជម្រៅ។

តាមរយៈការឆ្លុះបញ្ចាំងពីកត្តាទាំងនេះ គ្រូអាចបត់បែនប្រើប្រាស់សម្ភារៈយថាភូតដូចគ្នា ឱ្យសមស្របនឹងតម្រូវការថ្នាក់ ដោយរក្សាតុល្យភាពរវាងការសប្បាយ និងការរៀនភាសាពិតប្រាកដ។

ពុំមានវិធីសាស្ត្រត្រឹមត្រូវតែមួយគត់ក្នុងការប្រើប្រាស់សម្ភារៈយថាភូតទេ វាអាស្រ័យទៅលើគោលដៅ ថ្នាក់រៀននិងតម្រូវការសិស្សរបស់អ្នកតែប៉ុណ្ណោះ។ ថ្ងៃខ្លះ ការសើចសប្បាយជាមួយនឹងរឿង Curious George ទំនងជាអ្វីដែលសិស្សត្រូវការ។ ថ្ងៃខ្លះទៀត អ្នកចង់សិក្សាស៊ីជម្រៅហើយបម្លែងសាច់រឿងដដែលទៅជាការរៀនពិតប្រាកដវិញ។

ការរក្សាលំនឹងរវាងការរៀនបែបសប្បាយនិងការប្រើប្រាស់ភាសាគឺជាចំណុចសំខាន់ ហើយធ្វើឱ្យសិស្សដឹងថា ភាសាអង់គ្លេសមិនមែនគ្រាន់តែមុខវិជ្ជានៅសាលាតែប៉ុណ្ណោះទេ តែវាជាភាសារស់ដែលរង់ចាំការសិក្សាឈ្វេងយល់។



# ការបង្កើនប្រសិទ្ធភាពនៃបណ្ណាល័យសាលារបស់អ្នក

ដោយៈ **សឿង វ៉ាន់** និង **ពាស ចិន្ដាដួង**

## សេចក្ដីផ្ដើម

បណ្ណាល័យសាលារៀន គឺជាការវិនិយោគមួយក្នុងចំណោមការវិនិយោគដែលមើលឃើញច្បាស់បំផុតរបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្នុងការសិក្សារបស់សិស្ស ដោយមានបំពាក់នូវធ្នើរសៀវភៅទំនើបៗ កុំព្យូទ័រសម្រាប់សិស្សធ្វើកិច្ចការ កន្លែងអង្គុយប្រកបដោយផាសុកភាព និងការប្រមូលផ្ដុំសៀវភៅដែលត្រូវបានជ្រើសរើសយ៉ាងយកចិត្តទុកដាក់។ ការរក្សាលំនឹងរវាងការរៀនបែបសប្បាយនិងការប្រើប្រាស់ភាសាគឺជាចំណុចសំខាន់ ហើយធ្វើឱ្យសិស្សដឹងថា ភាសាអង់គ្លេសមិនមែនគ្រាន់តែមុខវិជ្ជានៅសាលាតែប៉ុណ្ណោះទេ តែវាជាភាសារស់ដែលរង់ចាំការសិក្សាឈ្វេងយល់។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសាលារៀន ជាច្រើននៅកម្ពុជា ធនធានទាំងនេះត្រូវបានទុកចោលដោយមិនបានប្រើប្រាស់ក្នុងរយៈពេលយូរជារៀងរាល់ថ្ងៃ ដោយសារតែ បណ្ណាល័យត្រូវបិទទ្វារទាំងស្រុងនៅម៉ោងសម្រាកអាហារថ្ងៃត្រង់ ដែលធ្វើឲ្យ បណ្ណាល័យត្រូវបិទទ្វារជិតប្រហែល ២ ម៉ោងកន្លះនៅពេលថ្ងៃត្រង់។

អត្ថបទនេះបង្ហាញពីគំរូជាក់ស្ដែង និងចំណាយថវិកាតិច ដែលសាលារៀនឈានមុខមួយចំនួនបានអនុវត្ត ដើម្បីរក្សាការចូលប្រើប្រាស់ពេញមួយថ្ងៃដោយមិនមានការរំខាន ដែលធ្វើឱ្យស្តង់ដារប្រតិបត្តិការស្របតាមបណ្ដាប្រទេសដទៃទៀតក្នុងតំបន់អាស៊ាន។ តាមរយៈការផ្លាស់ប្ដូរចន្លោះប្រហោងនៃការគ្រប់គ្រងប្រចាំថ្ងៃ ទៅជាឱកាសរៀបចំភាពជាអ្នកដឹកនាំរបស់សិស្ស សាលារៀនអាចបង្កើនផលចំណេញលើការវិនិយោគលើវិស័យអប់រំបានយ៉ាងច្រើន។

## បញ្ហា

ក្រោមកាលវិភាគពេលសិក្សាតាមបែបប្រពៃណីរបស់សាលារៀននៅកម្ពុជា វគ្គសិក្សាពេលព្រឹកត្រូវបញ្ចប់នៅម៉ោងប្រហែល ១១:០០ ព្រឹក ដែលជំរុញឱ្យសិស្ស គ្រូបង្រៀន និងបណ្ណារក្សសាលាត្រឡប់ទៅផ្ទះវិញដើម្បីទទួលទានអាហារថ្ងៃត្រង់។ ដោយគ្មានបុគ្គលិកនៅសេសសល់ក្នុងបរិវេណសាលា សម្ភារបរិក្ខារបណ្ណាល័យត្រូវបានចាក់សោ និងទុកចោលជាប្រចាំ រហូតដល់ វេនសិក្សាពេលរសៀលចាប់ផ្ដើមឡើងវិញនៅម៉ោងប្រហែល ១:៣០ រសៀល។

ចន្លោះប្រហោងប្រចាំថ្ងៃជាច្រើនម៉ោងនេះ បង្កើតឱ្យមានការខាតបង់ផ្នែកប្រតិបត្តិការមួយចំនួនដូចជា៖

- **ការធ្លាក់ចុះតម្លៃទ្រព្យសម្បត្តិ៖** ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសម្ភារសិក្សាដែលមានតម្លៃថ្លៃ រួមមានសៀវភៅ គ្រឿងសង្ហារិមលំដាប់ខ្ពស់ កុំព្យូទ័រលើតុ និងទូរទស្សន៍ឆ្លាតវៃ (Smart TVs) ត្រូវធ្លាក់ចុះតម្លៃដោយអសកម្ម ដោយមិនបានបំពេញវដ្ដជីវិតដែលបានគ្រោងទុករបស់វា ។
- **ការបាត់បង់សមធម៌៖** វាលុបបំបាត់បរិយាកាសប្រកបដោយសុវត្ថិភាព និងផលិតភាពសម្រាប់ក្រុមសិស្សងាយរងគ្រោះ ដែលរស់នៅឆ្ងាយពីសាលារៀន មិនអាចធ្វើដំណើរទៅផ្ទះដើម្បីទទួលទានអាហារថ្ងៃត្រង់បាន ហើយត្រូវបានទុកចោលជាមួយនឹងពេលវេលាទំនេរដ៏ច្រើនដោយគ្មានការណែនាំ។
- ការបាត់បង់ឱកាសសិក្សា៖ វាបានកាត់បន្ថយយ៉ាងខ្លាំងនូវម៉ោងសំខាន់ៗដែលត្រូវបានបម្រុងទុកសម្រាប់ការស្វ័យសិក្សាការស្រាវជ្រាវបំពេញបន្ថែមម៉ោងអានសៀវភៅនិងការចូលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្រោមការត្រួតពិនិត្យ។

### គំរូជាក់ស្តែង៖ ឱ្យសិស្សជាអ្នកគ្រប់គ្រង និងការផ្តល់ជូនអាហារជំនួសថវិកា

ដើម្បីជៀសវាងកម្រិតកំណត់នៃកម្លាំងពលកម្មរបស់បុគ្គលិកស្ថាប័ន ដោយមិនបាច់ដាក់សម្ពាធដែលមិនអាចគ្រប់គ្រងបានលើបុគ្គលិកដែលមានប្រាក់បៀវត្សរ៍ ថ្នាក់ដឹកនាំសាលាបានអនុវត្តដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត៖ ផ្ដល់សិទ្ធិត្រួតពិនិត្យទៅឱ្យក្រុមសិស្សរៀនថ្នាក់ខ្ពស់ ដែលមានទំនួលខុសត្រូវ និងមានការរៀបចំច្បាស់លាស់មួយក្រុមតូច ដើម្បីគ្រប់គ្រងបរិក្ខារក្នុងអំឡុងពេលម៉ោងសម្រាកអាហារថ្ងៃត្រង់ដែលមានសិស្សចរាចរណ៍ច្រើន។

ធាតុសំខាន់ៗនៃគំរូនេះមានដូចជា៖

- ការជ្រើសរើស៖ ជ្រើសរើសសិស្សដែលមានភាពចាស់ទុំ និងគួរឱ្យទុកចិត្តពី ១ ទៅ ៣ នាក់ (ជាទូទៅមកពីថ្នាក់ខ្ពស់) ដែលមានប្រវត្តិអាកប្បកិរិយាល្អគំរូ និងមានចំណេះដឹងជាមូលដ្ឋាន ឬជំនាញកុំព្យូទ័រ។ ការចូលរួមពីគ្រូបង្រៀនក្នុងការតែងតាំង និងការប្រមូលអនុសាសន៍ពីមិត្តភក្តិ ធានាបាននូវដំណើរការជ្រើសរើសដែលគួរឱ្យទុកចិត្ត។ ត្រូវតែមានការយល់ព្រមពីមាតាបិតាអ្នកអាណាព្យាបាលសិស្សថែមទៀត។
- **តួនាទី និងវិសាលភាព៖** សិស្សអ្នកត្រួតពិនិត្យ បំពេញ ភារកិច្ចជាមូលដ្ឋាន រួមមានការបើក/បិទទ្វារ ការរក្សាសណ្តាប់ធ្នាប់ក្នុងបន្ទប់ ការណែនាំមិត្តភក្តិទៅកាន់ធ្នើរសៀវភៅ និងការដោះស្រាយបញ្ហាកុំព្យូទ័រជាមូលដ្ឋាន។ ពួកគេជាអ្នកត្រួតពិនិត្យយ៉ាងតឹងរ៉ឹង ហើយ តម្រូវឱ្យបំពេញភារកិច្ចបច្ចេកទេសជំនាញ ដូចជាការធ្វើកាតាឡុកសៀវភៅ ឬការគាំទ្រផ្នែកបង្រៀននោះទេ។
- **ការផ្តល់ជូនអាហារជំនួសថវិកា** (In-Kind Compensation)៖ ជាជាងការផ្តល់សាច់ប្រាក់ សាលារៀនផ្តល់ជូននូវអាហារថ្ងៃត្រង់ដោយឥតគិតថ្លៃ ឬទទួលបានការឧបត្ថម្ភធនធានយ៉ាងច្រើននៅថ្ងៃបំពេញភារកិច្ច។ វិធីនេះចំណាយតិចតួចសម្រាប់ អង្គភាពសាលារៀន មានន័យជ្រាលជ្រៅចំពោះសិស្ស និងលុបបំបាត់របាំងជាក់ស្តែងក្នុងការចាកចេញពីបរិវេណសាលាដើម្បីស្វែងរកអាហារ។
- រចនាសម្ព័ន្ធត្រួតពិនិត្យ៖ ដើម្បីជៀសវាងការប៉ះពាល់ដល់ការសិក្សា សិស្សគួរតែផ្លាស់ប្តូរវេនគ្នារៀងរាល់សប្តាហ៍ ឬរៀងរាល់ខែ។ ត្រូវតែរក្សាទំនាក់ទំនងឱ្យបានច្បាស់លាស់ដោយរក្សាទុកលេខទំនាក់ទំនងរបស់បណ្ណារក្សឱ្យមានជាស្រេច និងធានាថាមានគ្រូប្រចាំការនៅក្បែរនោះ ឬសន្តិសុខសាលាដែលអាចទាក់ទងបានក្នុងករណីមានអាសន្ន។

## ការសិក្សាករណី៖ ការបើកចំហសក្តានុពលនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម

នៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដែលមានទីតាំងនៅក្រុងកំពង់ចាម ការបើកបណ្ណាល័យនៅម៉ោងសម្រាកថ្ងៃត្រង់បានវិវត្តពីការសាកល្បងទៅជាសសរស្តម្ភស្នូលនៃសមធម៌របស់ស្ថាប័ន។

«សម្រាប់សិស្សដែលមានផ្ទះនៅឆ្ងាយពីសាលារៀន ការស្នាក់នៅក្នុងបរិវេណសាលាមានន័យថាត្រូវប្រឈមមុខនឹងពេលវេលាទំនេរដ៏ច្រើនរហូតដល់បីម៉ោងដោយគ្មានការណែនាំ។ ការរក្សាបណ្ណាល័យរបស់យើងឱ្យបើកទ្វារ អនុញ្ញាតឱ្យសិស្សទាំងនេះបំពេញកិច្ចការអាន និងគម្រោងស្រាវជ្រាវបានយ៉ាងរលូន ដែលជម្រុញលទ្ធផលសិក្សារបស់ពួកគេយ៉ាងខ្លាំង»។

— នាយកសាលា វិទ្យាល័យ ហ៊ុន សែន កំពង់ចាម

**ភាពស៊ីសង្វាក់គ្នានៃប្រតិបត្តិការ៖** បណ្ណារក្សសាលារាយការណ៍ថា ម៉ោងបើកទ្វារសម្រាកអាហារថ្ងៃត្រង់មិនបង្កឱ្យមានការរំខានដល់ការងារប្រចាំថ្ងៃស្តង់ដារនោះទេ ពីព្រោះសិស្សអ្នកត្រួតពិនិត្យត្រូវបានបណ្តុះបណ្តាលយ៉ាងល្អិតល្អន់ និងដាក់ឱ្យបំពេញការងារតាមកាលវិភាគប្តូរវេនយ៉ាងតឹងរ៉ឹង។ ដើម្បីគាំទ្រដល់អំណាចរបស់សិស្ស សាលាបានដាក់ពង្រាយការត្រួតពិនិត្យរចនាសម្ព័ន្ធ តាមរយៈប្រព័ន្ធកាមេរ៉ា និងរក្សាការគ្រប់គ្រងបណ្តាញយ៉ាងរឹងមាំ រួមទាំងការបិទគេហទំព័រកម្សាន្តនៅគ្រប់បណ្តាញសាលារៀនទាំងអស់ ដោយរក្សាបច្ចេកវិទ្យាឱ្យផ្តោតលើការសិក្សាយ៉ាងតឹងរ៉ឹងតែប៉ុណ្ណោះ។

## កញ្ចប់ឧបករណ៍ជាក់ស្តែងសម្រាប់សិស្សអ្នកត្រួតពិនិត្យ

ដើម្បីបង្ហាញពីភាពសាមញ្ញនៃប្រតិបត្តិការនៃគំរូនេះ និងធានាបាននូវការចម្លងតាមដោយរលូន សាលារៀនអាចដាក់ពង្រាយទម្រង់គំរូ បញ្ជីផ្ទៀងផ្ទាត់ និងម៉ាទ្រីសច្បាប់ស្តង់ដារដូចខាងក្រោម។

### ទម្រង់គំរូទី១៖ បទបញ្ជាផ្ទៃក្នុងបណ្ណាល័យក្នុងម៉ោងសម្រាកអាហារថ្ងៃត្រង់

- **សណ្តាប់ធ្នាប់ និង វិន័យ៖** សិស្សទាំងអស់ត្រូវដោះស្បែកជើងនៅមាត់ទ្វារទុកនៅធ្នើរខាងក្រៅ និងរក្សាជួរឱ្យមានសណ្តាប់ធ្នាប់។
- **ការគ្រប់គ្រងបរិយាកាស៖** ព្រំដែនបរិស្ថានត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹង។ សិស្សត្រូវនិយាយខ្សឹបៗ និងគោរពកន្លែងសិក្សាដ៏ស្ងប់ស្ងាត់របស់អ្នកដទៃ។
- **ការសម្របសម្រួលការអាន៖** សៀវភៅ និងសម្ភារបណ្ណាល័យគឺសម្រាប់ប្រើប្រាស់ក្នុងទីកន្លែងតែប៉ុណ្ណោះក្នុងអំឡុងពេលអាហារថ្ងៃត្រង់ ហើយមិនត្រូវយកចេញពីបន្ទប់ឡើយ។
- **ការគ្រប់គ្រងបច្ចេកវិទ្យា៖** ទ្រព្យសម្បត្តិមានតម្លៃខ្ពស់ (កុំព្យូទ័រលើតុ, ទូរទស្សន៍ឆ្លាតវៃ, ថេប្លេត) ត្រូវតែប្រើប្រាស់សម្រាប់តែគោលបំណងអប់រំ និងស្រាវជ្រាវដែលបានអនុម័តជាមុនប៉ុណ្ណោះ។
- **គោលការណ៍អាហារ៖** មិនអនុញ្ញាតឱ្យយកអាហារ ឬភេសជ្ជៈនៅក្នុងបណ្ណាល័យឡើយ ទោះក្នុងពេលណាក៏ដោយ។

### ទម្រង់គំរូទី២៖ បញ្ជីផ្ទៀងផ្ទាត់ប្រតិបត្តិការប្រចាំថ្ងៃសម្រាប់សិស្សអ្នកត្រួតពិនិត្យ

| ដំណាក់កាល | សកម្មភាពដែលត្រូវធ្វើ/ ព័ត៌មានលម្អិតនៃភារកិច្ច |
|---|---|
| ការបើក (១១:00) | មកដល់ទាន់ពេលវេលា; បញ្ចប់ការប្រគល់ទទួលការងារសង្ខេបជាមួយប្រធានបណ្ណារក្ស។ |
| | បើកសោទ្វារបណ្ណាល័យ និង ដាក់សន្លឹកបញ្ជីវត្តមាននៅតុខាងមុខច្រកចូល។ |
| | ផ្ទៀងផ្ទាត់ថា កុំព្យូទ័រលើតុត្រូវបានបើក និង ការគ្រប់គ្រងការប្រើប្រាស់បណ្តាញកំពុងដំណើរការ។ |
| ការត្រួតពិនិត្យ | ធានាថាមិត្តភក្តិ ដែលមកចូលរួមគោរពច្បាប់ដោះស្បែកជើងនៅច្រកចូលយ៉ាងតឹងរ៉ឹង។ |
| | ដើរពិនិត្យជាប្រចាំ ដើម្បីពង្រឹងបរិយាកាសសិក្សាស្ងប់ស្ងាត់ (និយាយខ្សឹបៗប៉ុណ្ណោះ)។ |
| | ត្រួតពិនិត្យឧបករណ៍បច្ចេកវិទ្យា ដើម្បីធានាបាននូវការប្រើប្រាស់ដែលបានអនុម័តជាមុន និង សម្រាប់តែការអប់រំប៉ុណ្ណោះ។ |
| | តាមដានដើម្បីធានាថា សៀវភៅដែលនៅក្នុងបណ្ណាល័យស្ថិតនៅក្នុងទីតាំងដោយសុវត្ថិភាព។ |
| ការបិទ (១៣:៣០) | ចាកចេញពីគណនីដែលអ្នកប្រើប្រាស់ភ្លាមៗ បិទកុំព្យូទ័រលើតុ និងបិទទូរទស្សន៍ឆ្លាតវៃ។ |
| | ផ្ទៀងផ្ទាត់ភាពស្អាតជម្រះនៃបន្ទប់ បិទបង្អួចឱ្យជិត ចាក់សោទ្វារ និងប្រគល់បញ្ជីវត្តមាន។ |

### ទម្រង់គំរូទី ៣៖ ការគ្រប់គ្រងហានិភ័យ និងផ្លូវកាត់បន្ថយផលប៉ះពាល់

សិស្សអ្នកត្រួតពិនិត្យដើរតួជាស្ពានទំនាក់ទំនងដ៏សំខាន់ ជាជាងអ្នកដាក់ពិន័យ។ ក្នុងករណីមានការប៉ះទង្គិចគ្នាក្នុងប្រតិបត្តិការ ពួកគេត្រូវបានបណ្តុះបណ្តាលឱ្យអនុវត្តតាមម៉ាទ្រីសនៃការបញ្ជូនបន្តជាលំដាប់ថ្នាក់យ៉ាងតឹងរ៉ឹង៖

- **កម្រិតទី១** – ភាពមិនប្រក្រតីនៃអាកប្បកិរិយា៖ សម្រាប់ការល្មើសច្បាប់តូចតាច (ឧទាហរណ៍៖ ការនិយាយខ្លាំងៗ ការញ៉ាំអាហារ) សិស្សអ្នកត្រួតពិនិត្យត្រូវរំលឹកដោយផ្ទាល់ និងគួរសម ដោយប្រើប្រាស់ផ្ទាំងរូបភាពច្បាប់ដែលមើលឃើញច្បាស់។
- **កម្រិតទី២** – ការមិនព្រមសហការជាបន្តបន្ទាប់៖ ប្រសិនបើសិស្សបដិសេធមិនសហការ អ្នកត្រួតពិនិត្យត្រូវកត់ត្រាឈ្មោះសិស្សនោះ ហើយទាក់ទងទៅគ្រូប្រចាំការ ឬសន្តិសុខដែលនៅជិតនោះភ្លាមៗដើម្បីជួយអន្តរាគមន៍។
- **កម្រិតទី៣** – ហានិភ័យរចនាសម្ព័ន្ធ បច្ចេកទេស ឬឧបករណ៍៖ រាល់ការខូចខាតផ្នែករឹង (Hardware) ការដាច់បណ្តាញអ៊ីនធឺណិត ឬបញ្ហាអគារ ត្រូវតែកត់ត្រាទុកក្នុងសៀវភៅកំណត់ហេតុភ្លាមៗ និងរាយការណ៍ផ្ទាល់ទៅប្រធានបណ្ណារក្សក្នុងអំឡុងពេលប្រគល់ទទួលការងារពេលរសៀល។

### បញ្ជីផ្ទៀងផ្ទាត់ការអនុវត្តតាមជំហានទីមួយៗ

សម្រាប់គណៈគ្រប់គ្រងសាលាដែលចង់ចម្លងតាមក្របខ័ណ្ឌជោគជ័យនេះ ផ្លូវប្រតិបត្តិការត្រូវបានបែងចែកជាប្រាំដំណាក់កាលច្បាស់លាស់៖

**១. អនុម័តគោលការណ៍៖** ថ្នាក់ដឹកនាំសាលាចុះហត្ថលេខាជាផ្លូវការលើការបើកបណ្ណាល័យក្នុងម៉ោងអាហារថ្ងៃត្រង់ និងបង្កើតកញ្ចប់ថវិកាសម្រាប់ការឧបត្ថម្ភធនអាហារជំនួសសាច់ប្រាក់។

**២. ជ្រើសរើសអ្នកត្រួតពិនិត្យ៖** តែងតាំងបេក្ខជនសិស្សថ្នាក់ខ្ពស់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ផ្ទៀងផ្ទាត់ប្រវត្តិអាកប្បកិរិយា សម្ភាសន៍ខ្លីៗ និងទទួលបានការយល់ព្រមជាផ្លូវការពីមាតាបិតាអ្នកអាណាព្យាបាល។

**៣. ផ្តល់ការបណ្តុះបណ្តាល៖** វគ្គតម្រង់ទិសរយៈពេល ៣០ ទៅ ៦០ នាទី គ្របដណ្តប់លើបញ្ជីផ្ទៀងផ្ទាត់ការបើក/បិទ ពិធីសារសុវត្ថិភាព និងម៉ាទ្រីសនៃការបញ្ជូនបន្ត។ បំពាក់ឱ្យពួកគេនូវកញ្ចប់ឧបករណ៍ត្រួតពិនិត្យដែលបានបោះពុម្ពរួចរាល់ (បញ្ជីវត្តមាន បញ្ជីទំនាក់ទំនង និងការណែនាំអំពីការសង្គ្រោះបឋមជាមូលដ្ឋាន)។

**៤. បើកដំណើរការជាការសាកល្បង៖** ដំណើរការដំណាក់កាលសាកល្បងដែលមានរចនាសម្ព័ន្ធពី ៤ ទៅ ៦ សប្តាហ៍។ ប្រមូលទិន្នន័យមូលដ្ឋានសាមញ្ញ រួមមានចំនួនអ្នកចូលទស្សនាប្រចាំថ្ងៃ ភាពញឹកញាប់នៃការខ្ចីសៀវភៅ និងវត្តប្រើប្រាស់កុំព្យូទ័រដែលបានកត់ត្រាទុក។

**៥. ពិនិត្យឡើងវិញ និងពង្រីកវិសាលភាព៖** វិភាគទិន្នន័យ និងមតិកែលម្អប្រកបដោយគុណភាពពីគ្រូ និងសិស្ស។ កែសម្រួលច្បាប់ កែតម្រូវតារាងប្តូរវេនអ្នកត្រួតពិនិត្យ និងពង្រឹងនីតិវិធីដើម្បីធានាថាកម្មវិធីនេះនៅតែបន្ត ទោះបីជាមានការផ្លាស់ប្តូរបុគ្គលិកនាពេលអនាគតក៏ដោយ។

### សេចក្តីសន្និដ្ឋាន

ការរក្សាបណ្ណាល័យសាលាឱ្យនៅបើកដំណើរក្នុងអំឡុងពេលអាហារថ្ងៃត្រង់ គឺជាការអនុវត្តដែលមានតម្លៃថវិកាតិច ប៉ុន្តែមានផលវិជ្ជមានខ្ពស់ដែលបង្កើនការប្រើប្រាស់ធនធានគាំទ្រសិស្សដែលមានការខ្វះខាត និងបង្កើតជំនាញដឹកនាំសំខាន់ៗ។ ជាមួយនឹងការរៀបចំផែនការកម្រិតមធ្យម ដែលកំណត់ដោយការជ្រើសរើសជាយុទ្ធសាស្ត្រ វគ្គតម្រង់ទិសខ្លីៗ ច្បាប់ដែលមើលឃើញច្បាស់ និងរង្វាន់ជាអាហារបន្តិចបន្តួច សាលារៀននានានៅទូទាំងប្រទេសកម្ពុជា អាចបំប្លែងម៉ោងសម្រាកថ្ងៃត្រង់ដែលធ្លាប់ខ្ជះខ្ជាយពីមុន ឱ្យទៅជាពេលវេលារៀនសូត្រប្រកបដោយភាពរស់រវើក និងផលិតភាពខ្ពស់។



# ជំនឿមិនពិតដែលពេញនិយមបំផុត អំពីការរៀនសូត្រ និងការអប់រំ

## Urban Myths about Learning and Education

ដោយ៖ **Stanislas Kowalski**

បកប្រែដោយ៖ **ឆាយទី ចានិត**




នៅក្នុងសៀវភៅនេះ លោក de Bruyckere, Kirschner និង Hulshof បានខិតខំប្រឹងប្រែងរៀបរៀងគម្រោងដ៏មានប្រយោជន៍មួយជាមួយគ្នា។ ពួកគាត់បានពិនិត្យមើលគំនិតជាច្រើននៅក្នុងវិស័យអប់រំ។ វាជាជំនឿមិនពិតដ៏លំបាកមួយក្នុងការកត់សម្គាល់ថា តើអ្វីដែលបានរៀបចំគឺជាគំនិតដ៏ពេញនិយមបំផុតមួយចំនួនដែលកំពុងផ្សព្វផ្សាយ ដោយមិនមែនគ្រាន់តែជា ការរៀបរៀងចៃដន្យដែលដកស្រង់ចេញពីក្នុងចំណោមអ្នកប្រើប្រាស់ហ្វេសប៊ុកនោះទេ។ អ្នកនឹងយល់នូវគំនិតជាច្រើនដែលត្រូវបានផ្សព្វផ្សាយដោយគ្រូបង្រៀន ឬក៏ជាអ្នកដែលត្រូវបានបង្រៀននៅមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀននៅជុំវិញពិភពលោក។ គំនិតទាំងនោះមានផលវិបាកយ៉ាងធំធេង។ ពួកវាបង្កើតគោលនយោបាយរបស់ប្រទេសទាំងមូលដែលមានមោទនភាពចំពោះការអនុវត្តដែលមានមូលដ្ឋានលើភស្តុតាង។

នៅក្នុងជំពូកចំនួនប្រាំមួយ អ្នកនិពន្ធបានរៀបរាប់លើប្រធានបទជាច្រើនដូចជា៖

១. ការបោសសម្អាតដ៏ធំ

២. ជំនឿមិនពិតអំពីការរៀនសូត្រ

៣. ជំនឿមិនពិតអំពីដំណើរការសរសៃប្រសាទ

៤. ជំនឿមិនពិតអំពីបច្ចេកវិទ្យាក្នុងការអប់រំ

៥. ជំនឿមិនពិតក្នុងគោលនយោបាយអប់រំ

៦. ការបន្ត និងការបំបែកនៃជំនឿមិនពិត

អ្នកនិពន្ធបានទាញការសន្និដ្ឋានផ្សេងៗគ្នាអំពីជំនឿមិនពិតដែលពួកគេពិនិត្យ។ ក្នុងករណីខ្លះ ពួកគេគ្រាន់តែសង្កេតឃើញថាយើងខ្វះភស្តុតាងគ្រប់គ្រាន់ ទោះបីជាទ្រឹស្តីមានភាពជាក់លាក់ខ្លះក៏ដោយ។ ក្នុងករណីផ្សេងទៀត ពួកគេអាចបដិសេធជំនឿមិនពិតទាំងស្រុង។ ចូរយើងសរសើរដល់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្ហាញភាពខុសប្លែកគ្នា និងជៀសវាងជម្រើសមិនពិត។ នៅក្នុងជំពូក "អ្នកនឹងរៀនបានប្រសើរជាងប្រសិនបើអ្នករកឃើញអ្វីមួយដោយខ្លួនឯង ជាជាងការឱ្យអ្នកដទៃពន្យល់អ្នក" ដោយជំទាស់នឹងការប្រឆាំងយ៉ាងតឹងតែងរវាងការណែនាំដោយផ្ទាល់ និងការរៀនសូត្រសកម្ម ហើយរំលឹកយើងថាវិធីសាស្រ្តបង្រៀនគឺជាការបំពេញបន្ថែម។

តាមជំពូកនីមួយៗ បញ្ចប់ដោយការព្យាយាមធ្វើឱ្យមានភាពវិជ្ជមានជាងមុនដោយការចែករំលែកគំនិតល្អមួយចំនួនដើម្បីបង្កើតទ្រឹស្តីគរុកោសល្យ។ យើងគួរតែស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងនេះ ហើយចងចាំថាបើគ្រាន់តែការបំផ្លាញជំនឿមិនពិតប្រឌិតគឺវាមិនគ្រប់គ្រាន់ទេ។ ប៉ុន្តែការប្រាប់យើងពីរបៀបបង្រៀន មិនមែនជាគោលបំណងសំខាន់នៃសៀវភៅនោះទេ។ សៀវភៅនេះ មិនគួរអាចត្រឹមតែជាសៀវភៅណែនាំអំពីគរុកោសល្យទេ ប៉ុន្តែគួរតែអាចជាសៀវភៅណែនាំពីការគិតបែបស៊ីជម្រៅ។

## ជំនឿមិនពិតដ៏ល្ងង់ខ្លៅបំផុត

ទេវកថាមួយចំនួនដែលបានពិនិត្យនៅទីនេះ វាដូចគ្រាន់តែជាជំនឿមិនពិតចម្លែកៗគួរឱ្យអស់សំណើចប៉ុណ្ណោះ។ ឧទាហរណ៍ "ការចងចាំរបស់យើងដែលបានកត់ត្រានូវអ្វីដែលយើងបានជួបប្រទះ" "យើងប្រើខួរក្បាលរបស់យើងត្រឹមតែ ១០% ប៉ុណ្ណោះ" ឬ "ទារកកាន់តែឆ្លាតប្រសិនបើពួកគេស្តាប់តន្ត្រីបុរាណ"។ ទេវកថាទាំងនេះមិនមានសារៈសំខាន់ខ្លាំងនោះទេ ហើយការគិតស៊ីជម្រៅក៏មានតិចតួចបំផុត ដែលគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ប៉ុន្តែ យើងអាចនឹងប្រឈមមុខនឹងជំនឿមិនពិតទាំងនោះដូចដែលអ្នកបានដឹងហើយថា វាត្រូវការពេលវេលាច្រើនដើម្បីបដិសេធគំនិតទាំងនោះជាជាងការនិយាយវា។ បាតុភូតនោះថែមទាំងមានឈ្មោះមួយ គឺច្បាប់របស់លោក Brandolini ។ យើងដឹងគុណដែលអ្នកនិពន្ធនៃ Urban Myths បានធ្វើការងារដ៏គួរឱ្យធុញទ្រាន់សម្រាប់យើង។ ប្រហែលជាវានឹងជួយសន្សំសំចៃពេលវេលារបស់យើងក្នុងការសន្ទនាជាមួយឪពុកម្តាយ និងអ្នកអប់រំផ្សេងទៀត។

យើងនឹងឃើញនៅពេលក្រោយទៀតថា ជំនឿមិនពិតផ្សេងទៀតគឺធ្ងន់ធ្ងរជាង។

## ការត្រឡប់ទៅរកមើលប្រភពដើមវិញ

អ្នកនិពន្ធបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការតាមដានប្រភពដើមនៃជំនឿមិនពិតមួយចំនួន។ ឧទាហរណ៍៖ ពីរ៉ាមីតដ៏ល្បីល្បាញនៃការរៀនសូត្រ។ តាមពិតទៅ ការខិតខំប្រឹងប្រែងនោះមិនចាំបាច់ទាល់តែសោះ។ វាងាយស្រួលក្នុងការបដិសេធកំណែទូទៅដែលផ្សព្វផ្សាយនៅលើអ៊ីនធឺណិត ដោយគ្រាន់តែកត់សម្គាល់ពីភាពមិនស៊ីសង្វាក់គ្នា និង ការអនុវត្តគណិតវិទ្យាដែលទាក់ទងនឹងវិធីសាស្ត្របង្រៀននីមួយៗ។ ទោះជាយ៉ាងណាក៏ដោយ ការត្រឡប់ទៅប្រភពដើមវិញអនុញ្ញាតឱ្យយើងយល់ពីរបៀបដែលគំនិតខុសអាចត្រូវបានបង្កើតឡើង។ លោក Edgar Dale ត្រូវបានគេសរសើរចំពោះជំនឿមិនពិតនេះ ដោយគាត់បានស្នើឡើងនូវកំណែដំបូងមួយ ហើយប្រហែលជាកំណែដ៏ល្អបំផុត ឬអាក្រក់បំផុត។ យើងរកឃើញថា កោណរបស់លោក Dale គ្រាន់តែជាការចាត់ថ្នាក់ងាយស្រួលនៃការគាំទ្រពីអរូបីយបំផុតទៅជាក់ស្តែងបំផុត។ យោងតាមលោក Dale ផ្ទាល់ "ឧបករណ៍កោណគឺជាពាក្យប្រៀបធៀបដែលមើលឃើញនៃបទពិសោធន៍សិក្សាដែលសម្ភារៈ audio-visual ប្រភេទផ្សេងៗត្រូវបានរៀបចំតាមលំដាប់លំដោយនៃការកើនឡើងនៃអរូបីនៅពេលដែលមនុស្សម្នាក់បន្តពីបទពិសោធន៍ផ្ទាល់"។ វាមិនបានផ្តល់ភស្តុតាងណាមួយទាក់ទងនឹងប្រសិទ្ធភាពដែលទាក់ទងគ្នានៃសម្ភារៈនីមួយៗ ឬសូម្បីតែការលំបាករៀងៗខ្លួនរបស់វានោះទេ។ ប៉ុន្តែយ៉ាងហោចណាស់វាមានភាពស៊ីសង្វាក់គ្នា។

កំណែជាបន្តបន្ទាប់នៃកោណអាចត្រូវបានពិពណ៌នាថាជាការក្លែងបន្លំ ជាមួយនឹងស្ថិតិដែលបង្កើតឡើងរបស់វា។

## ជំនឿមិនពិតដែលត្រូវបានបដិសេធដោយអ្នកបង្កើតរបស់ពួកវា (យ៉ាងហោចណាស់មួយផ្នែក)

អ្វីដែលគួរឱ្យព្រួយបារម្ភបំផុតនោះគឺករណីមួយចំនួនដែលជំនឿមិនពិតត្រូវបានបដិសេធដោយអ្នកនិពន្ធដែលបានផ្តួចផ្តើមវា។ លោក Maslow មិនបានបង្កើតទ្រឹស្តីរបស់គាត់ក្នុងទម្រង់ជាពីរ៉ាមីតទេ។ ខ្ញុំផ្ទាល់បានអានអត្ថបទរបស់គាត់ព្រោះខ្ញុំមានការជំទាស់មួយចំនួនប្រឆាំងនឹងពីរ៉ាមីត ដោយគ្រាន់តែរកឃើញក្របខណ្ឌគំនិតសមហេតុផលជាងជាមួយនឹងភាពខុសប្លែកគ្នា និងសំណួរ។

នេះជាអ្វីដែលលោក Maslow ផ្ទាល់បាននិយាយនៅឆ្នាំ ១៩៦២ (ដូចដែលបានដកស្រង់នៅក្នុង Urban Myths): ទ្រឹស្តីលើកទឹកចិត្តរបស់ខ្ញុំត្រូវបានបោះពុម្ពផ្សាយកាលពី ២០ ឆ្នាំមុន ហើយក្នុងអំឡុងពេលនោះគ្មាននរណាម្នាក់ធ្វើវាឡើងវិញ ឬសាកល្បងវា ឬវិភាគ ឬរិះគន់វាពិតប្រាកដនោះទេ។ ពួកគេគ្រាន់តែប្រើវាទាំងស្រុង ដោយមានការកែប្រែតិចតួចបំផុត។ មានការផ្លាស់ប្តូរតិចតួចណាស់ចាប់តាំងពីពេលនោះមក។

លោក Albert Mehrabian គឺជាប្រភពដើមនៃជំនឿមិនពិតថាដែលបញ្ជាក់ថា ៩៣% នៃទំនាក់ទំនងរបស់យើងគឺមិនមែនជាពាក្យសំដី។

លើកលែងតែគាត់មិនដែលនិយាយបែបនោះទេ។ នៅក្នុងបទសម្ភាសជាមួយ BBC ថា "មិនមែនជាការពិតទេ។ ហើយរាល់ពេលដែលខ្ញុំឮលទ្ធផលរបស់ខ្ញុំត្រូវបានដកស្រង់មិនត្រឹមត្រូវតាមរបៀបនេះ ខ្ញុំមានអារម្មណ៍ខ្មាសអៀនជាខ្លាំង។ វាច្បាស់ណាស់ចំពោះអ្នកដែលមានសុភវិនិច្ឆ័យបន្តិចថាជំនឿមិនពិតនេះមិនអាចត្រឹមត្រូវបានទេ"។

អ្វីដែលលោក Mehrabian បានធ្វើគឺរាយការណ៍ពីលទ្ធផលនៃការពិសោធន៍ជាក់លាក់មួយរបស់គាត់។ នៅក្នុងការពិសោធមួយក្នុងចំណោមការពិសោធន៍ទាំងនោះ អ្នកចូលរួមត្រូវបានសួរថាតើពាក្យមួយមានលក្ខណៈវិជ្ជមាន អព្យាក្រឹត ឬអវិជ្ជមាន។ ជាការពិតណាស់ ចម្លើយគឺខុសគ្នាអាស្រ័យលើសំឡេង និងរូបថតរបស់អ្នកនិយាយ។ សរុបមក នៅពេលដែលទាក់ទងនឹងអារម្មណ៍ ទំនាក់ទំនងមិនមែនពាក្យសំដីអាចផ្លាស់ប្តូរអត្ថន័យនៃពាក្យ ហើយថែមទាំងសំខាន់ជាងពាក្យខ្លួនឯងទៀតផង។ ប៉ុន្តែមានស្ថានភាពជាច្រើនដែលទំនាក់ទំនងមិនមែនពាក្យសំដីមិនមាន ឬមិនពាក់ព័ន្ធ។

## ជំនឿមិនពិតដែលមកជាមួយនឹងផលជះតាមក្រោយ

ការបំបាត់ជំនឿមិនពិតមិនមែនគ្រាន់តែជាបញ្ហានៃភាពត្រឹមត្រូវខាងវិទ្យាសាស្ត្រនោះទេ។ ពួកវាមានផលជះសំខាន់ៗក្នុងជីវិតពិត។

ទ្រឹស្តីនៃពហុបញ្ញា ដែលត្រូវបានលើកឡើងដោយលោក Howard Gardner មិនត្រូវបានចាត់ទុកថាជាជំនឿមិនពិតព្រេងនិទានទេ ប៉ុន្តែយោងទៅតាមលោក de Bruyckere, Kirschner និង លោក Hulshof វាមានសក្តានុពលក្លាយជាជំនឿមិនពិតដែលអាចទៅរួចបានដែរ។ លោក Gardner ផ្ទាល់បានបដិសេធការប្រើប្រាស់មិនល្អមួយចំនួនដែលត្រូវបានធ្វើឡើងពីវា ជាពិសេសការចាត់ទុកភាពវៃឆ្លាតច្រើនរបស់គាត់ថាជារចនាបទនៃការរៀនសូត្រ ដោយដាក់ស្លាកសិស្សជាមួយនឹងភាពវៃឆ្លាតប្រភេទជាក់លាក់មួយ និងផ្តល់ឱ្យពួកគេនូវមេរៀនជាក់លាក់ដែលសមនឹងស្លាកបែបនេះ។ ការអនុវត្តទាំងនេះអាចបង្កគ្រោះថ្នាក់យ៉ាងខ្លាំងដល់ការអភិវឌ្ឍរបស់កុមារ ដោយការបង្រួមចក្ខុវិស័យរបស់ពួកគេ។ យើងអាចត្រលប់ទៅ លោក Gardner វិញនៅក្នុងទស្សនាវដ្តីនាពេលអនាគត។ ជំនឿមិនពិតអំពីបច្ចេកវិទ្យាក្នុងការអប់រំពាក់ព័ន្ធនឹងការចំណាយសាធារណៈយ៉ាងច្រើន។ ចំណាយមួយភាគធំត្រូវបានខ្ជះខ្ជាយលើកម្មវិធីដែលគ្មានប្រសិទ្ធភាព។ ជំពូកទាំងមូលនៃជំនឿមិនពិតអំពីគោលនយោបាយអប់រំមានសំណួរជាច្រើនដែលមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើប្រាក់របស់អ្នកជាប់ពន្ធ៖ ទំហំថ្នាក់រៀន ទំហំសាលារៀន និងអ្វីៗផ្សេងទៀត។ នៅក្នុងជំពូកនោះ *ជំនឿមិនពិតទី ៧ ចំណាយកាន់តែច្រើនមានន័យថា ការអប់រំកាន់តែប្រសើរសមនឹងទទួលបានការយកចិត្តទុកដាក់ជាពិសេស*។

## ដែនកំណត់

ជំនឿមិនពិតដែលពេញនិយមបំផុតអំពីការរៀនសូត្រ និងការអប់រំមានប្រយោជន៍ ព្រោះវាផ្ទុកព័ត៌មានជាច្រើនក្នុងទម្រង់ច្បាស់លាស់។ វាងាយស្រួលអាន និងគ្របដណ្តប់លើប្រធានបទជាច្រើន៖ ជំនឿមិនពិតធំៗចំនួន ៣៥ ក្នុងចំនួនត្រឹមតែ ២០៩ ទំព័រប៉ុណ្ណោះ! ប៉ុន្តែនៅទីនោះមានដែនកំណត់របស់វា។ អ្នកនិពន្ធត្រូវប្រើផ្លូវកាត់មួយចំនួនដោយខ្លួនឯង។

ជាឧទាហរណ៍ យើងអាចសោកស្តាយដែលពួកគេឱ្យតម្លៃច្រើនពេកដល់ការវិភាគរបស់លោក John Hattie។ សៀវភៅរបស់គាត់ Visible Learning គឺជាការវិភាគចំនួន ៨០០។ នោះជាភាពស្មុគស្មាញច្រើនពេកដើម្បីធានាទិន្នន័យរឹងមាំ។ នៅកម្រិតនោះ អ្នកមិនអាចធានាភាពត្រឹមត្រូវនៃនិយមន័យបានទេ។ ក្នុងន័យមួយរបស់លោក Bruyckere, Kirschner និង Hulshof ធ្វើកំហុសដូចគ្នាដោយរៀបរាប់ខ្លឹមសារច្រើនពេក ប៉ុន្តែក្នុងកម្រិតតិចជាង។ ដូចដែលយើងបានឃើញខាងលើ សំណួរមួយចំនួនគឺសាមញ្ញល្មមសមស្របដើម្បីដោះស្រាយក្នុងរយៈពេលពីរបីទំព័រ។ ហើយយើងអាចដឹងគុណដែលពួកគេបានបដិសេធជំនឿមិនពិតទាំងនោះ។ ប៉ុន្តែក្នុងករណីខ្លះ យើងអាចសោកស្តាយដែលពួកគេមិនបានឈ្វេងយល់កាន់តែស៊ីជម្រៅ អំពីសំណួរនោះទេ។ យើងពិតជាត្រូវទទួលយកសេចក្តីសន្និដ្ឋានរបស់ពួកគេដោយយកចិត្តទុកដាក់។ ជាឧទាហរណ៍៖ សំណួរនៃការរក្សាទុក និងប្រសិទ្ធភាពរបស់វាគឺស្មុគស្មាញពេកដើម្បីដោះស្រាយក្នុងរយៈពេលពីរបីទំព័រ។ ការសង្កេតថាការរក្សាទុកផ្តល់អត្ថប្រយោជន៍រយៈពេលខ្លី សមនឹងទទួលបានការត្រួតពិនិត្យបន្ថែមទៀត។ ទោះបីជាផលប៉ះពាល់ហាក់ដូចជារសាត់បាត់ទៅតាមពេលវេលាក៏ដោយ ក៏វាមិនអាចត្រូវបានច្រានចោលថាមិនសំខាន់ដែរ។ ការឆ្លុះបញ្ចាំងកាន់តែស៊ីជម្រៅអំពីភាពជោគជ័យ ការរំពឹងទុក និងសមត្ថភាពដែលមានពីកំណើត គឺចាំបាច់ណាស់ ដើម្បីធ្វើការសន្និដ្ឋានច្បាស់លាស់លើសំណួរសំខាន់នោះ។

ជំពូកជំនឿមិនពិតអំពីបច្ចេកវិទ្យាក្នុងវិស័យអប់រំគួរតែត្រូវបានធ្វើបច្ចុប្បន្នភាពយ៉ាងពិតប្រាកដ។ បច្ចេកវិទ្យាមួយចំនួនមានភាពជឿនលឿនជាងពេលដែលសៀវភៅនេះ ត្រូវបានបោះពុម្ពផ្សាយកាលពី 11 ឆ្នាំមុន។ វាគឺមុនពេលមានបញ្ញាសិប្បនិម្មិត (AI) ស្មាតហ្វូននៅតែថ្មីស្រឡាង ហើយជំងឺរាតត្បាតកូវីដ-១៩ មិនបានបង្ខំយើងឲ្យវាយតម្លៃឡើងវិញអំពីប្រសិទ្ធភាពនៃឧបករណ៍អេឡិចត្រូនិករបស់យើងទេ។ យើងលែងស្ថិតក្នុងដំណើរការសាកល្បងនិងកំហុសនៃសម័យត្រួសត្រាយផ្លូវទៀតហើយ។ យើងលែងរំពឹងថាការផ្តល់ឧបករណ៍ដល់មនុស្សនឹងនាំមកនូវលទ្ធផលដោយស្វ័យប្រវត្តិទៀតហើយ។ យើង (ភាគច្រើន) បានឆ្លងផុតដំណាក់កាលផ្សព្វផ្សាយដែលសៀវភៅពិពណ៌នា។ ឥឡូវនេះ វាដល់ពេលដែលត្រូវពន្យល់លម្អិតអំពី គោលការណ៍សំខាន់នៃការប្រើប្រាស់សម្រាប់កុំព្យូទ័រ និង ស្មាតហ្វូនរបស់យើង។

ជាទូទៅ ទ្រឹស្តីជំនួសដែល លោកde Bruyckere, Kirschner និង Hulshof បានលើកឡើងនៅទីនេះ និងទីនោះ គួរតែត្រូវបានគិតដោយភាពស៊ីជម្រៅដូចគ្នានឹងទ្រឹស្តីដែលពួកគេបដិសេធ។ មិនប្រាកដថាគំរូនៃភាពវៃឆ្លាតដែលស្នើឡើងដោយ J. P. Guilford ក្នុងឆ្នាំ ១៩៩៥ គឺត្រឹមត្រូវជាងគំរូរបស់ Gardner នោះទេ។ វាគ្រាន់តែជាការចូលរួមចំណែកគួរឱ្យចាប់អារម្មណ៍មួយចំពោះការជជែកវែកញែកអំពីអ្វីដែលជាភាពវៃឆ្លាត។

## សេចក្តីសន្និដ្ឋាន

ដែនកំណត់ទាំងនោះមិនគួររារាំង គ្រូបង្រៀនពីការអានសៀវភៅ Urban Myths នោះទេ។ សៀវភៅនេះជម្រុញការគិត ហើយនោះជាចំណុចពិត។ វាធ្វើឱ្យយើងពិចារណាឡើងវិញនូវការសន្មតរបស់យើង និងនិយាយឡើងវិញអំពីបញ្ហាឱ្យកាន់តែច្បាស់។ សូម្បីតែនៅក្នុងជំពូកដែលអាចខ្សោយជាងនេះក៏ដោយ អ្នកនិពន្ធមានគុណសម្បត្តិដើម្បីបង្ហាញពីអ្វីដែលជាហានិភ័យ ហើយយើងមិនអាចទុកចិត្តអ្នកស្រាវជ្រាវណាម្នាក់ដោយងងឹតងងល់បានទេ។ ខ្ញុំប្រាកដថាអ្នកនិពន្ធនឹងរីករាយនៅពេលដែលឃើញថា យើងមិនយកគំនិតរបស់ពួកគេទាំងមិនត្រឹមត្រូវនោះទេ។ សៀវភៅ Urban Myths អំពីការរៀនសូត្រ និងការអប់រំគឺជាមធ្យោបាយដ៏ល្អមួយដើម្បីធ្វើឱ្យចិត្តគំនិតរិះគន់របស់មនុស្សម្នាក់កាន់តែមុតស្រួច។ ខ្ញុំថែមទាំងចង់និយាយថា គ្រូបង្វឹកគ្រូបង្រៀនគ្រប់រូប អ្នកធ្វើគោលនយោបាយគ្រប់រូប និងអ្នករចនាកម្មវិធីសិក្សាគ្រប់រូប គួរតែអានវា ក្នុងនាមជាអ្នកបំផុសគំនិត និងជាចំណុចចាប់ផ្តើមសម្រាប់ការឆ្លុះបញ្ចាំងកាន់តែស៊ីជម្រៅ។

# កំណត់សម្គាល់អំណាន ការបោះពុម្ពលើកទី២

ដោយ៖ **Stanislas Kowalski**
បកប្រែដោយ៖ **ស៊ី ហុង**




**Cesare Beccaria - On Crimes and Punishments and Other Writings (1995, Cambridge University Press)**

## សម្រាប់គ្រូបង្រៀនកម្រិតខ្ពស់
**(FAT: For Advanced Teachers)**

ជាស្នាដៃបុរាណដ៏សំខាន់មួយក្នុងទស្សនវិជ្ជាស្តីពីច្បាប់។ វាមិនមែនជាសៀវភៅស្តីពីវិន័យនៅសាលារៀនទេ ប៉ុន្តែជាសៀវភៅដ៏ល្អសម្រាប់ឈ្វេងយល់អំពី យុត្តិធម៌ និងវិធីអនុវត្តឱ្យបានត្រឹមត្រូវ។ វាមានប្រយោជន៍សម្រាប់មនុស្សគ្រប់គ្នា ជាពិសេសអ្នកដែលមានតួនាទីក្នុងការដាក់ទណ្ឌកម្មអ្នកដទៃ ឬមានតួនាទីក្នុងការកាត់សេចក្តី។

**Machiavelli – The Prince:**




## សម្រាប់គ្រូបង្រៀនកម្រិតខ្ពស់
**(FAT: For Advanced Teachers)**

ជាស្នាដៃបុរាណនៃទស្សនវិជ្ជានយោបាយ។ ទស្សនៈដែលមើលទៅដូចជាអសីលធម៌របស់អ្នកនិពន្ធ បានជំរុញឲ្យអ្នកអានមានការគិតវិភាគ និងពិចារណាដោយស៊ីជម្រៅ។ ទោះយ៉ាងណាក៏ដោយ សៀវភៅនេះមានការសង្កេតបែបទុក្ខសោកជាច្រើន ប៉ុន្តែសំខាន់ណាស់។ វាជាផ្នែកមួយដ៏សំខាន់នៃការជជែកវែកញែកដេញដោលអំពីការអនុវត្តច្បាប់ ការបង្ការឧក្រិដ្ឋកម្ម និងការរក្សាសណ្តាប់ធ្នាប់ ជាពិសេសសម្រាប់ឈ្វេងយល់អំពីអ្នកដែលជឿថា ភាពភ័យខ្លាច គឺជារឿងចាំបាច់។

**Bruce R. Joyce, Beverly Showers - Student Achievement Through Staff Development (បោះពុម្ពលើកទី ៣) (2002)**




## សម្រាប់អ្នកជំនាញ
**(FE: For Experts)**

ជាសៀវភៅដែលមានលក្ខណៈវិទ្យាសាស្ត្រយ៉ាងម៉ត់ចត់ និងផ្តល់ទស្សនៈល្អៗអំពីការបណ្តុះបណ្តាលគ្រូ និងការអនុវត្តបច្ចេកទេសថ្មីៗ។ សៀវភៅនេះនិយាយត្រង់ៗ និងមិនព្យាយាមលាក់បាំងភាពលំបាក ឬផលប៉ះពាល់ផ្សេងៗឡើយ។ វាជួយឲ្យមានការយល់ដឹងជ្រាលជ្រៅអំពីបញ្ហានេះ។ មានការសិក្សាករណីមួយចំនួន ប៉ុន្តែមិនត្រូវបានតាក់តែងសម្រាប់ការប្រើប្រាស់ក្នុងការអនុវត្តដោយផ្ទាល់ទេ។

**Douglas Fisher, Nancy Frey - Better Learning Through Structured Teaching: A Framework for the Gradual Release of Responsibility (2008, ASCD)**




### សម្រាប់គ្រូបង្រៀនកម្រិតខ្ពស់
**(FAT: For Advanced Teachers)**

សៀវភៅនេះពន្យល់អំពីរបៀបរៀបចំមេរៀនឲ្យមានប្រសិទ្ធភាព ដោយប្រើរចនាសម្ព័ន្ធបង្រៀនច្បាស់លាស់។ វាថែមទាំងជួយគ្រូបង្រៀនដោះស្រាយបញ្ហាជាច្រើនដែលទាក់ទងនឹងការបង្រៀនបែបស្ថាបនានិយម (constructivist activities) និងការបង្រៀនឆ្លើយតបទៅនឹងសមត្ថភាពសិស្ស (differentiated instruction)។ អ្នកនិពន្ធបង្ហាញថាការបង្រៀនដោយផ្ទាល់ (direct instruction) និងការបង្រៀនដោយផ្អែកលើការចងចាំនៅតែមានសារៈសំខាន់ក្នុងការរៀន។

សៀវភៅនេះក៏ផ្តល់គន្លឹះបង្រៀនដែលមានប្រយោជន៍ផងដែរ ដូចជា ការវាយតម្លៃសិស្សម្នាក់ៗក្នុងពេលធ្វើការងារជាក្រុម ដើម្បីឲ្យសិស្សគ្រប់រូបចូលរួម។ វាពិភាក្សាអំពីភាពលំបាកក្នុងការបង្រៀនដោយបើកចំហ និងផ្តល់ឧទាហរណ៍ច្បាស់ៗ ដើម្បីជួយគ្រូដឹងថាគួរចាប់ផ្តើមពីណា។ សូមណែនាំឲ្យអានជាពិសេស ព្រោះសៀវភៅនេះរួមបញ្ចូលទាំងគោលការណ៍បង្រៀន រចនាសម្ព័ន្ធច្បាស់លាស់ និងដំបូន្មានអនុវត្តជាក់ស្តែងល្អៗសម្រាប់ថ្នាក់រៀន។

**Philip Zimbardo, Nikita Duncan - The Demise of Guys: Why Boys Are Struggling and What We Can Do About It (2012)**




### សម្រាប់អ្នកជំនាញ
**(FE: For Experts)**

សៀវភៅនេះ មានអត្ថប្រយោជន៍ក្នុងទាញចំណាប់អារម្មណ៍ទៅលើបញ្ហាមួយដែលមនុស្សជាច្រើនមើលរំលង។ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ គោលនយោបាយសាធារណៈបានផ្តោតខ្លាំងលើការកែលម្អការអប់រំសម្រាប់ក្មេងស្រី ដោយមិនសូវកត់សម្គាល់ថា ក្មេងស្រីមានលទ្ធផលសិក្សាល្អជាងក្មេងប្រុស ហើយក្មេងប្រុសជាច្រើនបានបោះបង់ការសិក្សា។ ក្នុងន័យនេះ វាជារឿងសំខាន់ក្នុងការអានសៀវភៅដែលសិក្សាអំពីបញ្ហារបស់ក្មេងប្រុស ដូចដែល Zimbardo និង Duncan បានសរសេរក្នុងសៀវភៅខ្លីនេះ។ យើងអាចបារម្ភថា សៀវភៅនេះផ្តោតខ្លាំងពេកលើកត្តាពីរគឺរូបអាសអាភាស និងវីដេអូហ្គេមតែប៉ុណ្ណោះ។សូមកុំយល់ច្រឡំ។ ពិតណាស់ បញ្ហាទាំងនេះមានសារៈសំខាន់។ ប៉ុន្តែវាគួរឲ្យបារម្ភដែលបញ្ហាផ្សេងៗទៀត ដូចជា ការលើកឡើងតែបន្តិចបន្តួចពីកង្វះវត្តមានរបស់ឪពុកក្នុងគ្រួសារ។ បើទោះបីជាដូច្នោះ វានៅតែជាសៀវភៅល្អមួយសម្រាប់ចាប់ផ្តើមឈ្វេងយល់អំពីបញ្ហានេះ។

# ភាពជាអ្នកដឹកនាំក្នុងបរិបទនៃភាពចម្រូងចម្រាស៖



# យុទ្ធសាស្ត្រឈ្នះ-ឈ្នះ ដើម្បីគ្រប់គ្រងឥទ្ធិពលអវិជ្ជមានក្នុងសាលារៀន

ដោយ៖ **បណ្ឌិត ស៊ុន សុម៉ារ៉ា**

នៅក្នុងអាជីពជាអ្នកដឹកនាំសាលារៀន វាមិនមែនជារឿងចម្លែកទេដែលលោកនាយក ឬលោកស្រីនាយិកាត្រូវប្រឈមមុខនឹង **«ព្យុះអវិជ្ជមាន»** ក្នុងអង្គភាព។ បញ្ហាប្រឈមដ៏ធំបំផុតនោះ គឺវត្តមានរបស់ក្រុមគ្រូបង្រៀនមួយក្រុមតូច ដែលតែងតែជំទាស់នឹងផែនការអភិវឌ្ឍសាលារៀន និងមានមេខ្លោងដែលប្រៀបដូចជា **«នាយកស្រមោល»**[១] ដែលចាំតែញុះញង់ ឬបញ្ចុះបញ្ចូលគ្រូបង្រៀនដទៃទៀតឱ្យបះបោរ។ ស្ថានភាពនេះ កាន់តែស្មុគស្មាញដោយសារយន្តការ «បណ្ដឹងអនាមិក» ដែលអនុញ្ញាតឱ្យគ្រូបង្រៀនប្ដឹងនាយកសាលាដោយមិនចាំបាច់បញ្ចេញអត្តសញ្ញាណ ទោះបីជាការស៊ើបអង្កេតមិនរកឃើញកំហុសក៏គ្មានការដាក់ទណ្ឌកម្មលើអ្នកប្ដឹងគ្មានមូលដ្ឋាននោះដែរ។ ដើម្បីដោះស្រាយវិបត្តិនេះ នាយកសាលាត្រូវប្រើប្រាស់យុទ្ធសាស្ត្រចម្រុះដែលប្រកបដោយវិជ្ជាជីវៈ និងតម្លាភាព ។

ក្នុងបរិបទកម្ពុជា នាយកសាលាមិនមែននៅតែម្នាក់ឯងនោះទេ គណៈកម្មការគ្រប់គ្រងសាលារៀន (ដែលមានសហគមន៍ និងអាជ្ញាធរមូលដ្ឋានចូលរួម) គឺជាអំណាចទី២។ ជំហានដំបូងប្រសិនបើមានការបះបោរ ឬបណ្ដឹងហួសហេតុ នាយកសាលាគួរលើកបញ្ហានេះដាក់ក្នុងអង្គប្រជុំគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីឱ្យសហគមន៍ជាអ្នកជួយសម្របសម្រួល។ គ្រូបង្រៀនអាចនឹងមិនខ្លាចនាយកសាលា តែពួកគេនឹងរារែកក្នុងការប្រឆាំងជាមួយឆន្ទៈរបស់សហគមន៍ និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស។ បន្ទាប់មក នាយកសាលាគួរប្រើយុទ្ធសាស្ត្រ **«រុញទូកឱ្យខ្ទប់ច្រាំង»** តាមរយៈការបង្កើតគណៈកម្មការអភិវឌ្ឍចម្រុះ គឺជាវិធីសាស្ត្រដ៏ឈ្លាសវៃបំផុត។

ប្រសិនបើ «នាយកស្រមោល» រិះគន់លើគម្រោងណាមួយ អ្នកដឹកនាំគួរតែងតាំងរូបគាត់ឱ្យធ្វើជាប្រធាន ឬ អនុប្រធានទទួលបន្ទុកផ្នែកនោះផ្ទាល់ ជាឧទាហរណ៍៖ ប្រសិនបើ «នាយកស្រមោល» នោះរិះគន់រឿងការសាងសង់ ឬការទិញសម្ភារៈ សូមតែងតាំងគាត់ឱ្យធ្វើជា ប្រធានគណៈកម្មការលទ្ធកម្ម ឬ អនុប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ។ នៅពេលគាត់មានចំណែកខុសត្រូវ គាត់នឹងកាត់បន្ថយការរិះគន់ ហើយងាកមកការពារសមិទ្ធផលនោះវិញ។ ប្រសិនបើគាត់ព្រមធ្វើ បញ្ហាទាំងអស់នឹងត្រូវបានដោះស្រាយ ប៉ុន្តែប្រសិនបើគាត់មិនព្រមធ្វើវិញ គាត់នឹងលែងមានសិទ្ធិរិះគន់តទៅទៀតហើយ។

លើសពីនេះ នាយកសាលាត្រូវកសាង «ប្រព័ន្ធការពារខ្លួន» តាមរយៈយុទ្ធសាស្ត្ររដ្ឋបាល និងច្បាប់។ ក្នុងប្រព័ន្ធរដ្ឋបាល បើអ្នកមិនមានភស្តុតាង អ្នកគឺជាអ្នកខុសឬអ្នកចាញ់ ដូច្នេះ រាល់សកម្មភាពទាំងអស់ត្រូវតែមាន «ឯកសារជាភស្តុតាង»។ ដូច្នេះ រាល់ការប្រជុំត្រូវមានកំណត់ហេតុច្បាស់លាស់ ដែលមានហត្ថលេខាចូលរួមពីគ្រូបង្រៀនគ្រប់រូបផងដែរ ដើម្បីបញ្ជាក់ថាប្រសិនបើពួកគេមិនអនុវត្តតាមផែនការ វានឹងក្លាយជា «កំហុសរដ្ឋបាល» មិនមែនជាបញ្ហាបុគ្គលឡើយ។
ទន្ទឹមនឹងការអនុវត្តច្បាប់រដ្ឋបាល យុទ្ធសាស្ត្រ «ផ្លូវចិត្តសង្គម» ដើម្បីបំបែកអំណាចក្រុមប្រឆាំងក៏ជារឿងចាំបាច់ផងដែរ។ ក្រុមប្រឆាំងអាចរឹងមាំទៅបាន ក៏ព្រោះតែមានអ្នកដើរតាមដែលយល់ច្រឡំ ឬខ្លាចអំណាចមេក្រុម ឬមេខ្យល់។ នាយកសាលាគួរប្រើប្រាស់យុទ្ធសាស្ត្រ «ចុះសួរសុខទុក្ខដល់កន្លែង» (Desk-side Chat) ដោយការដើរទៅជួប ឬសំណេះសំណាលជាមួយគ្រូបង្រៀននៅបន្ទប់សម្រាក ឬកន្លែងហូបបាយជុំគ្នា ដើម្បីកាត់បន្ថយរបាំងអំណាចឬឋានៈតួនាទី និងបង្ហាញពីការយកចិត្តទុកដាក់។ បន្ថែមលើនេះ នាយកសាលាគួរឆ្លៀតពេលពិភាក្សាជាមួយបុគ្គលដែលជា

១ **«នាយកស្រមោល»** គឺជាគ្រូបង្រៀន ឬបុគ្គលិកដែលគ្មានតួនាទីជានាយកសាលាផ្លូវការ តែមានឥទ្ធិពលជាមេខ្លោងក្នុងការញុះញង់ និងបញ្ចុះបញ្ចូលគ្រូបង្រៀនដទៃឱ្យបះបោរប្រឆាំងនឹងនាយកសាលា និងរារាំងរាល់ផែនការអភិវឌ្ឍសាលាស្ទើរតែទាំងអស់។

«នាយកស្រមោល» នោះ ក្រៅផ្លូវការ (ដូចជាការហូបកាហ្វេ) ដើម្បីសួរពីមតិយោបល់ និងផ្តល់តម្លៃដល់បទពិសោធរបស់គាត់។ មនុស្សភាគច្រើនប្រឆាំងដោយសារពួកគេមានអារម្មណ៍ថា «មិនត្រូវបានគេផ្តល់តម្លៃ»។ ក្រៅពីនេះ ការប្រើប្រាស់ «ឥទ្ធិពលមជ្ឈដ្ឋានខាងក្រៅ» តាមរយៈការអញ្ជើញមាតាបិតាសិស្ស ឬសហគមន៍ឱ្យចូលរួមដឹងឮពីសកម្មភាពសាលារៀន នឹងបង្កើតជាសម្ពាធសង្គមទៅលើក្រុមបង្កបញ្ហា ដែលសម្ពាធនេះមានឥទ្ធិពលខ្លាំងជាងវិន័យរដ្ឋបាលទៅទៀត។ អំណាច»វិញ។ ទោះបីច្បាប់ការពារអ្នកប្តឹងក្តី ប៉ុន្តែវាមិនបានហាមឃាត់ការវាយតម្លៃពីប្រសិទ្ធភាពនៃការបំពេញការងារឡើយ។ នាយកសាលាត្រូវប្រើប្រាស់សូចនាករវាយតម្លៃសមិទ្ធផលការងារ(KPIs)ឱ្យបានម៉ឺងម៉ាត់ ដោយផ្តោតលើកិច្ចសហការ ការអនុវត្តផែនការ និងក្រមសីលធម៌វិជ្ជាជីវៈ។ រាល់សកម្មភាពមិនសហការ ឬការបង្កជម្លោះនៅក្នុងអង្គភាព ត្រូវតែមានការកត់ត្រាទុកក្នុង «សំណុំរឿងបុគ្គលិក» ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃឡើងកាំប្រាក់ ឬការផ្តល់បណ្ណសរសើរ។ បន្ថែមលើសពីនេះ ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា (ICT Tools) ដូចជា ក្រុមតេឡេក្រាមផ្លូវការ និងតារាងព័ត៌មានឌីជីថល (Digital Dashboard) ដើម្បីបង្ហាញតម្លាភាពនៃចាត់ចែង ថវិកាសាលារៀន នឹងជួយកាត់បន្ថយការនិយាយដើម និងការបង្កើតព័ត៌មានក្លែងក្លាយ។




*រូបភាពនេះ រចនាដោយ Google Genini*

### តារាងប្រៀបធៀប៖

**ដំណោះស្រាយបែបចាស់ (ចាញ់-ចាញ់) និងដំណោះស្រាយបែបអ្នកដឹកនាំ (ឈ្នះ-ឈ្នះ)**

| បញ្ហា | ដំណោះស្រាយបែបចាស់ (ចាញ់-ចាញ់) | ដំណោះស្រាយបែបអ្នកដឹកនាំ (ឈ្នះ-ឈ្នះ) |
|---|---|---|
| គ្រូបង្រៀនបង្កបញ្ហា | ស្តីបន្ទោស ឬដេញចេញ (បង្កសង្គ្រាម) | ផ្តល់តួនាទីឱ្យទទួលខុសត្រូវលើផ្នែកដែលគាត់រិះគន់។ |
| បណ្តឹងអនាមិក | ខឹងសម្បារ និងព្យាយាមស៊ើបរកមុខ | បើកចំហរព័ត៌មាន និងពង្រឹងការវាយតម្លៃតាមសូចនាករវាយតម្លៃសមិទ្ធផលការងារ (KPI)។ |
| ការញុះញង់ | បង្កើតក្រុមស៊ើបការណ៍សម្ងាត់ | កសាងវប្បធម៌សរសើរអ្នកធ្វើការល្អឱ្យបានច្រើន។ |

ជាសេចក្តីសន្និដ្ឋាន **យុទ្ធសាស្ត្រ «ឈ្នះ-ឈ្នះ»** គឺជាកូនសោរដ៏សំខាន់សម្រាប់អ្នកដឹកនាំសាលារៀន ។ ជំនួសឱ្យការស្តីបន្ទោស ឬការព្យាយាមស៊ើបអង្កេតរកមុខអ្នកប្តឹង ដែលនាំឱ្យកើតសង្គ្រាមរ៉ាំរ៉ៃនៅក្នុងអង្គភាព អ្នកដឹកនាំគួរផ្តល់តួនាទីឱ្យពួកគេទទួលខុសត្រូវ បើកចំហព័ត៌មាន និងកសាងវប្បធម៌សរសើរអ្នកបំពេញការងារបានល្អ ។ ចូរ **«កុំព្យាយាមពន្លត់ភ្លើងដោយប្រើភ្លើង»** ប៉ុន្តែត្រូវប្រើប្រាស់«ភាពស្ងប់ស្ងាត់ដែលពោរពេញដោយភស្តុតាង» ។ នៅពេលសិស្សទទួលបានលទ្ធផលល្អ ហើយមាតាបិតាគាំទ្រនាយកសាលា នោះក្រុមប្រឆាំងនឹងរលាយបាត់ទៅដោយខ្លួនឯង ព្រោះពួកគេគ្មាន«ទីផ្សារ»សម្រាប់លក់ការញុះញង់ទៀតឡើយ។

# ការកសាងសហគមន៍សិក្សាសម្រាប់គ្រូបង្រៀននៅក្នុងសាលា៖ ជំហានងាយៗ ដើម្បីឱ្យសហគមន៍សិក្សាដំណើរការ

ដោយ៖ **Juliette Sochacki** បកប្រែដោយ៖ **ឆាយទី ចានិត**

នៅក្នុងសាលារៀនជាច្រើននៅប្រទេសកម្ពុជា គ្រូបង្រៀនខិតខំធ្វើការ ប៉ុន្តែភាគច្រើនពួកគាត់ធ្វើការតែម្នាក់ឯង។ លោកគ្រូ អ្នកគ្រូអាចមានអារម្មណ៍ថាពួកគាត់កំពុងជួបបញ្ហាប្រឈមតែម្នាក់ឯង ដូចជា ការរៀបចំមេរៀន ការជួបបញ្ហាប្រឈមក្នុងថ្នាក់រៀន និងការចូលរួមរបស់សិស្ស។ល។ ប៉ុន្តែតាមរយៈការជួបពិភាក្សាជាមួយគ្រូបង្រៀនមួយចំនួន ខ្ញុំបានរកឃើញវិធីផ្សេងដែលក្នុងនោះមានវិ ធីសាស្ត្រមួយដែលពួកគាត់បានលើកឡើងគឺ ការចូលរួមជាមួយសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន ឬ PLC។ លោកគ្រូ-អ្នកគ្រូ ជួបគ្នាជាប្រចាំជាមួយក្រុមសហការីតាមក្រុម ដើម្បីចែករំលែកគំនិតសាកល្បងយុទ្ធសាស្ត្រថ្មីៗ និងគាំទ្រគ្នាទៅវិញទៅមក។ សម្រាប់គ្រូបង្រៀន សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន (PLC) មិនមែននិយាយអំពីការផ្តល់មូលនិធិបន្ថែម ឬការបណ្តុះបណ្តាលពិសេសនោះទេ ប៉ុន្តែ ពួកគាត់ពិភាក្សាគ្នាអំពីការស្វែងរកវិធីថ្មីៗ ដើម្បីធ្វើឱ្យការបង្រៀនកាន់តែងាយស្រួល និងផ្តល់ផលចំណេញកាន់តែច្រើន។

## ហេតុអ្វីបានជាបង្កើតសហគមន៍សិក្សា?

សាកស្រមៃមើលមានក្រុមគ្រូបង្រៀនមួយក្រុមបានប្រមូលផ្តុំគ្នានៅតុមួយនៅចុងម៉ោងនៃថ្ងៃសិក្សា ហើយវាមិនមែនជាកិច្ចប្រជុំផ្លូវការទេ និងមិនមែនជាសិក្ខាសាលាដែលមានរបៀបវារៈតឹងរ៉ឹងនោះទេ តែគ្រាន់តែជាការជួបជុំមិត្តរួមការងារ ហើយនិយាយអំពីអ្វីដែលបានកើតឡើងនៅក្នុងថ្នាក់រៀនរបស់ពួកគាត់។ នេះជារបៀបដែលគ្រូបង្រៀនជាច្រើនពិពណ៌នាអំពីសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) របស់ពួកគាត់។ វាជាពេលវេលាធម្មតាមួយ ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលមានដំណើរការល្អ អ្វីដែលមិនដំណើរការ និង អ្វីដែលពួកគាត់បានរៀនសូត្រ។ មានគ្រូបង្រៀនម្នាក់បានពន្យល់ថាក្រុមរបស់គាត់ជួបគ្នាពីរដងក្នុងមួយខែ "ដើម្បីចែករំលែកវិធីសាស្ត្របង្រៀន ដោះស្រាយបញ្ហា ឬរៀនអ្វីថ្មីពីសមាជិកដ៏ទៃទៀត" ។ នៅពេលដែលមានវិធីសាស្ត្របង្រៀនថ្មីកើតឡើង ការជួបគ្នាក្នុងក្រុមបានក្លាយជាកន្លែងសម្រាប់ការសួរសំណួរ និងមើលពីរបៀបដែលអ្នកដទៃអនុវត្តវិធីសាស្ត្របង្រៀនថ្មី នៅក្នុងថ្នាក់រៀន។ អ្វីដែលលេចធ្លោនៅក្នុងបទសម្ភាសន៍គឺថាតើគ្រូបង្រៀនមានអារម្មណ៍ធូរស្រាលប៉ុណ្ណានៅពេលដែលពួកគាត់មិនបានធ្វើអ្វីៗគ្រប់យ៉ាងតែម្នាក់ឯង។

គ្រូបង្រៀនម្នាក់ក្នុងចំណោមពួកគាត់បានប្រាប់យើងថា ការចូលរួមជាមួយ សហគមន៍សិក្សាវិជ្ជាជីវៈ (PLC) បានជួយពួកគាត់ឱ្យទទួលបានទំនុកចិត្តក្នុងការនិយាយនៅចំពោះមុខអ្នកដទៃ ដែលជាអ្វីដែលពួកគាត់មិននឹកស្មានដល់ទាល់តែសោះ។ មានគ្រូបង្រៀនម្នាក់ទៀតបានដឹងពីមិត្តរួមការងាររបស់ពួកគាត់ដែលមានចិត្តល្អដោយបានលើកឡើងថា «គ្រូបង្រៀនដទៃទៀតមានចិត្តល្អ ហើយពួកគាត់ពិតជាចូលចិត្តចែករំលែកអ្វីថ្មីជាមួយអ្នកដទៃ»។ វាក្លាយជាវប្បធម៌ដ៏រឹងមាំមួយក្នុងការចែករំលែកចំណេះដឹង។ នៅពេលដែលមាននរណាម្នាក់ចូលរួមសិក្ខាសាលា ឬសាកល្បងអ្វីដែលថ្មី ហើយពេលដែលពួកគាត់ត្រលប់មកវិញ ពួកគាត់អាចមានវគ្គចែករំលែកខ្លីមួយ។ វាមិនមានអ្វីចម្លែកទេ គ្រាន់តែជាបទបង្ហាញតូចមួយ ដើម្បីឱ្យមនុស្សគ្រប់គ្នាអាចទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍ថ្មីៗ។

គ្រូបង្រៀនម្នាក់បាននិយាយថា "យើងតែងតែប្តូរវេនគ្នា" "ប្រសិនបើខ្ញុំចូលរួមកម្មវិធីមួយ ខ្ញុំចែករំលែក។ ប្រសិនបើអ្នកផ្សេងទៅ ពួកគេចែករំលែក"។ យូរៗទៅ ការធ្វើបែបនេះក្លាយជាផ្នែកមួយនៃទម្លាប់សិក្សារបស់សាលា។គ្រូបង្រៀនក៏ត្រូវឱ្យតម្លៃដល់ការអនុវត្តជាក់ស្តែងផងដែរ។ មនុស្សជាច្រើន

បានលើកឡើងពីប្រយោជន៍នៃការនិយាយអំពី បញ្ហាដែលយើងបានជួបប្រទះកាលពីសប្តាហ៍មុន និង រកដំណោះស្រាយជាមួយគ្នា។ ជំនួសឱ្យការរង់ចាំការបណ្តុះបណ្តាលជាផ្លូវការ ឬតស៊ូធ្វើការតែម្នាក់ឯង ពួកគាត់ប្រើ PLC ដើម្បីឆ្លើយតបយ៉ាងឆាប់រហ័សចំពោះបញ្ហាប្រឈមក្នុងថ្នាក់រៀន។ ហើយទោះបីជាគ្មានគ្រូបង្រៀនណាម្នាក់ និយាយអំពីភាពដ៏អស្ចារ្យក៏ដូចជាសារៈសំខាន់គឺច្បាស់លាស់នៃការចែករំលែកគ្នាក៏ដោយ តែនៅពេលដែលគ្រូបង្រៀនចំណាយពេលរៀនសូត្រពីគ្នាទៅវិញទៅមក ការបង្រៀនរបស់ពួកគាត់នឹងប្រសើរឡើង។ សិស្សនឹងមានអារម្មណ៍ខុសប្លែកគ្នា មិនមែនដោយសារតែគ្រូបង្រៀនធ្វើការច្រើនជាងមុននោះទេ ប៉ុន្តែដោយសារតែពួកគេបានធ្វើការចែករំលែកជាមួយគ្នា។ សរុបមក សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន គឺគ្រាន់តែជាកន្លែងដែលគ្រូបង្រៀនអាចគិត និយាយ និងរីកចម្រើនជាមួយមនុស្សដែលយល់ពីការពិតប្រចាំថ្ងៃនៃថ្នាក់រៀន។ ទាំងនេះគឺគ្រប់គ្រាន់ហើយសម្រាប់គ្រូបង្រៀន។

## ចាប់ផ្តើមពីរឿងតូចៗ

សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន មិនចាំបាច់ចាប់ផ្តើមជាមួយនឹងការប្រកាសធំដុំ ឬកិច្ចប្រជុំបុគ្គលិកពេញលេញនោះទេ។ យើងអាចធ្វើឡើងដោយគ្មានសម្ពាធ និងគ្មានតួនាទីផ្លូវការណាមួយក៏បាន។ អ្វីដែលត្រូវការគឺគ្រាន់តែអ្នកស្ម័គ្រចិត្តដែលមានចិត្តបើកចំហរវិជ្ជមាន និងចង់ដឹងចង់ចេះប៉ុណ្ណោះ។ ចំណុចសំខាន់គឺត្រូវធ្វើវាងាយៗ ដូចជា ជួបគ្នារៀងរាល់ពីរសប្តាហ៍ម្តង សិក្សាវគ្គខ្លីៗចន្លោះពី20 ទៅ 30 នាទីគឺគ្រប់គ្រាន់ហើយ។ ហើយស្វែងរកពេលវេលាដែលសមស្របជាមួយមនុស្សគ្រប់គ្នា (បន្ទាប់ពីចេញពីសាលារៀន ក្នុងអំឡុងពេលទំនេរ ឬមុនពេលត្រឡប់ទៅផ្ទះវិញ)។ អ្នកអាចចាប់ផ្តើមជាមួយក្រុមតូចមួយអាចគ្រូពីរ ឬបីនាក់ដែលចុះសម្រុងជាមួយ ហើយគ្រាន់តែជួបជុំគ្នាផឹកកាហ្វេ និងចែករំលែកអំពីអ្វីដែលអ្នកកំពុងឆ្លងកាត់។ វាពិតជាសំខាន់ខ្លាំងណាស់ក្នុងការកំណត់ពេលវេលាជាប្រចាំ សម្រាប់កិច្ចប្រជុំដូចជាត្រូវជួបគ្នាម្តងក្នុងមួយសប្តាហ៍ ឬម្តងក្នុងមួយខែ។ គ្រូបង្រៀនជីវវិទ្យាម្នាក់មកពីខេត្តសៀមរាប បាននិយាយ «យើងធ្វើវាម្តងក្នុងមួយសប្តាហ៍ គឺនៅថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៣ ដល់ ៤» ខណៈពេលដែលគ្រូបង្រៀនភាសាអង់គ្លេសម្នាក់មកពីខេត្តមួយផ្សេងទៀត បញ្ជាក់ថា នៅក្នុងសាលារបស់គាត់ ពួកគេធ្វើវាពីរដងក្នុងមួយខែ។ ការមានកាលវិភាគកំណត់ពេលវេលាជាក់លាក់ វានឹងធ្វើឱ្យវាកាន់តែងាយស្រួល ស្រួលក្នុងការរក្សាភាពស៊ីសង្វាក់គ្នា ជំនួសឱ្យការឈប់បន្ទាប់ពី ពីរ ឬបីវគ្គ។ វាក៏ធ្វើឱ្យក្រុមកាន់តែបើកចំហផងដែរ នៅពេលដែលមិត្តរួមការងារដែលទំនេរនៅពេលនោះដឹងថា ពួកគេអាចចូលមកនៅពេលណាដែលពួកគេចង់បាន។ ការសហការនឹងមិនបញ្ចប់ នៅពេលដែលមនុស្សបញ្ចប់ការប្រជុំនោះទេ។ ដូចដែលគ្រូបង្រៀនភាសាអង់គ្លេសម្នាក់បាននិយាយទាំងញញឹមថា "ពេលខ្លះយើងនិយាយគ្នានៅក្រៅម៉ោង PLC ផ្លូវការ ដូចជាយើងអាចពិភាក្សាគ្នានៅក្នុងក្រុម Telegram របស់យើង នៅពេលដែលយើងជួបគ្នាតាមថ្នាក់រៀន ឬពេលសម្រាប់អាហារថ្ងៃត្រង់"។ យ៉ាងណាក៏ដោយ ការមានកន្លែងទំនេរដាច់ដោយឡែកមួយ អនុញ្ញាតឱ្យក្រុម (PLC) នេះស្វែងយល់កាន់តែស៊ីជម្រៅ ដើម្បីស្វែងយល់សំណួរស្មុគស្មាញ និងឆ្លុះបញ្ចាំងជាមួយគ្នាដោយមិនចាំបាច់ប្រញាប់ប្រញាល់។ ការកំណត់ពេលវេលាជាក់លាក់មួយក៏ចាត់ទុកថាជារឿងនេះសំខាន់មួយផងដែរ។ វាបង្កើតពេលវេលារួមមួយដែលមនុស្សគ្រប់គ្នា អាចចូលរួមបានទាំងអស់គ្នា ហើយការប្តេជ្ញាចិត្តតិចតួចនោះច្រើនតែធ្វើឱ្យមានភាពខុសគ្នាយ៉ាងខ្លាំង។ ការចាប់ផ្តើមជាមួយអ្នកស្ម័គ្រចិត្តមួយចំនួនតូច ជារឿយៗជាវិធីល្អបំផុតដើម្បីចាប់ផ្តើម។ ក្រុមតូចមួយផ្តល់កន្លែងឱ្យមនុស្សគ្រប់គ្នាសាកល្បងគំនិត ស្វែងរកនូវគន្លឹះ និងកសាងទំនុកចិត្តដោយមិនមានអារម្មណ៍ថាត្រូវបានគេមើលរំលង ឬត្រូវបានគ្របសង្កត់។ យូរៗទៅ ទម្លាប់ធម្មតានេះនឹងបង្កើតការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់។ គ្រូបង្រៀនផ្សេងទៀតនឹងចាប់ផ្តើមរៀនវា ពីការផ្លាស់ប្តូរដោយការកសាងមិត្តភាពនៅក្នុងក្រុមមួយ ការសន្ទនាដោះស្រាយបញ្ហាយ៉ាងរហ័ស ភាពជោគជ័យតិចតួចដែលបានចែករំលែកបន្ទាប់ពីថ្នាក់រៀន។ មិនយូរប៉ុន្មាន ការចង់ដឹងចង់ឃើញនឹងធ្វើឱ្យមានការចូលរូមកាន់តែច្រើន។ នៅពេលដែលមិត្តរួមការងារដឹងថា PLC មានលក្ខណៈក្រៅផ្លូវការពិតជាក់ស្តែង និងមានមូលដ្ឋានលើបទពិសោធន៍ក្នុងថ្នាក់រៀនពិតប្រាកដ មិនមែនជាឯកសារបន្ថែម ឬការវាយតម្លៃជាផ្លូវការនោះទេ ។ ពួកគេទំនងជាចូលរួមដោយខ្លួនឯង។ ហើយនៅពេលដែលពួកគេឃើញឥទ្ធិពលល្អ ដូចជាទំនុកចិត្តក្នុងការបង្រៀន និងការចូលរួមរបស់សិស្ស ធ្វើឱ្យពួកគាត់មានចំណាប់អារម្មណ៍កើនឡើងបន្ថែមទៀត។ នៅក្នុងសាលាមួយចំនួន សូម្បីតែនាយក ឬអ្នកប្រឹក្សាក៏មានការចូលរួមវគ្គណាមួយផងដែរ ដោយសារតែពួកគាត់បានកត់សម្គាល់ឃើញថាបរិយាកាសកំពុងតែមានការផ្លាស់ប្តូរ។

សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន មួយពង្រីកមិនមែនតាមរយៈការអញ្ជើញ ឬសម្ពាធនោះទេ ប៉ុន្តែដោយសារតែមនុស្សយល់ថាវាមានសារៈសំខាន់ ហើយចង់ក្លាយជាផ្នែកមួយនៃវា។

## ធ្វើឱ្យសាមញ្ញ

សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀនមិនត្រូវការប្រើ PowerPoint សុន្ទរកថាវែងៗ ឬការធ្វើផែនការស្មុគស្មាញនោះទេ។ អ្វីដែលគ្រូបង្រៀនពេញចិត្តបំផុតគឺទម្រង់ខ្លីៗ ជាក់ស្តែង ដែលសាកសមនឹងថ្ងៃបំពេញការងារដ៏មមាញឹក។ ខាងក្រោមនេះគឺជារចនាសម្ព័ន្ធបីដែលអ្នកអាចប្រើបាន ពីព្រោះវាសាមញ្ញ អាចបត់បែនបាន និងមានប្រយោជន៍ពិតប្រាកដ។

## ការចែករំលែករហ័ស

នេះជាវិធីងាយស្រួលបំផុតដើម្បីចាប់ផ្តើម។ គ្រូបង្រៀនម្នាក់ៗចំណាយពេលពីរបីនាទីដើម្បីចែករំលែករឿងពីរយ៉ាង៖

- សកម្មភាពមួយដែលដំណើរការបានល្អនៅក្នុងថ្នាក់របស់ពួកគាត់
- បញ្ហាប្រឈមតូចមួយដែលពួកគាត់កំពុងជួបប្រទះនៅពេលនេះ។

ប៉ុណ្ណឹងហើយ។ អ្នកផ្សេងទៀតអាចសួរសំណួរ ផ្តល់គំនិត ឬគ្រាន់តែស្តាប់។ ក្នុងរយៈពេលត្រឹមតែ 10 ឬ 15 នាទីប៉ុណ្ណោះ មនុស្សគ្រប់គ្នានឹងបានរៀនអ្វីថ្មី ហើយគ្មាននរណាម្នាក់មានអារម្មណ៍ថាត្រូវបានគេបដណ្តប់ឡើយ។ វាជាទម្លាប់តូចមួយដែលបង្កើតអារម្មណ៍គាំទ្រពិតប្រាកដ។

## ការសង្កេតក្នុងថ្នាក់រៀនវិជ្ជមាន

ប្រសិនបើក្រុមមានអារម្មណ៍ថាមានទំនុកចិត្ត អ្នកអាចបន្ថែមការសង្កេតខ្លីៗជាដៃគូ។ គ្រូម្នាក់ទៅមើលថ្នាក់រៀនរបស់គ្រូដទៃរយៈពេល ១០-១៥ នាទី ហើយយកចិត្តទុកដាក់លើចំណុចតូចៗប្រចាំថ្ងៃដែលធ្វើឱ្យមេរៀនដំណើរការរលូន។ ជាឧទាហរណ៍៖ នៅវិទ្យាល័យមួយក្នុងទីក្រុងភ្នំពេញ គ្រូបង្រៀនភាសាអង់គ្លេសម្នាក់បានពន្យល់ថា អ្នកសង្កេតការបង្រៀនបានពិនិត្យមើលទាំងអ្វីដែលគ្រូបានបង្រៀន និងរបៀបដែលគ្រូបង្រៀន។ ឧទាហរណ៍៖ តើវេយ្យាករណ៍ដែលគ្រូបានបង្ហាញមានភាពត្រឹមត្រូវឬអត់ និង តើវិធីដែលគ្រូបង្រៀនវាពិតជាដំណើរការឬអត់។ បន្ទាប់ពីបង្រៀនរួច ពួកគាត់ជាធម្មតាផ្លាស់ប្តូរមតិយោបល់ភ្លាមៗពីការកែលម្អចំណុចជាក់លាក់ណាមួយនោះ។ វាជារឿងគួរឱ្យចាប់អារម្មណ៍ក្នុងការធ្វើឱ្យមានតុល្យភាពនៃមតិកែលម្អដូចជាគូសបញ្ជាក់ពីអ្វីដែលដំណើរការបានល្អកត់សម្គាល់ផ្នែកមួយដែលអាចត្រូវបានកែលម្អ ហើយនៅពេលដែលមិនប្រាកដប្រជា សូមដាក់ស្នើជាសំណួរជាជាងការកែតម្រូវ។ នេះធ្វើឱ្យមានការផ្លាស់ប្តូរគាំទ្រ ជៀសវាងការបំបាក់ទឹកចិត្ត ហើយត្រូវលើកទឹកចិត្តក្នុងការឆ្លុះបញ្ចាំងជាជាងការវិនិច្ឆ័យ។ គោលដៅមិនមែនជាការវាយតម្លៃ ឬការរិះគន់នោះទេ។ វាជាឱកាសមួយដើម្បីមើលឃើញការបង្រៀនល្អក្នុងការអនុវត្តខ្ញុំគំនិត និងរៀនពីថ្នាក់រៀនពិតប្រាកដ មិនមែនទ្រឹស្តីទេ។ គ្រូបង្រៀនជាច្រើននិយាយថា វិធីសាស្ត្រនេះជួយពួកគេច្រើនជាងសិក្ខាសាលា ពីព្រោះវាមានអារម្មណ៍ថាពិតប្រាកដ និងឆ្លើយតបទៅនឹងស្ថានភាពពិត។

## បញ្ហាប្រឈមក្នុងការបង្រៀនប្រចាំខែ

សាលារៀនល្អៗមួយចំនួនប្រើប្រាស់ទម្រង់សាមញ្ញ និងគាំទ្រ ដែលជួយក្រុម(PLC)ឱ្យរីកចម្រើនជាមួយគ្នាដោយគ្មានសម្ពាធ។ នៅដើមខែនីមួយៗ មនុស្សគ្រប់គ្នាជ្រើសរើសគោលដៅតូចមួយ និងប្រាកដនិយម ជាមួយនឹងសូចនាករច្បាស់លាស់ ដូចជា៖

- «បង្កើនពេលវេលានិយាយរបស់សិស្ស»។
- «សាកល្បងសកម្មភាពការងារជាគូមួយក្នុងមួយសប្តាហ៍»។
- «ប្រើល្បិចបង្រៀនសំបុត្រចាកចេញដើម្បីពិនិត្យមើលការយល់ដឹង យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍»។

គ្រូបង្រៀនម្នាក់មកពីខេត្តកំពង់ចាម បានសម្រេចចិត្តផ្តោតលើការគ្រប់គ្រងពេលវេលាបង្រៀន ពីព្រោះគាត់កម្រនឹងបញ្ចប់មេរៀនតាមផែនការណាស់។ សកម្មភាពបង្រៀននានាបានដំណើរការយូរ ការពិភាក្សាចំណាយពេលច្រើនជាងការរំពឹងទុក ហើយកិច្ចការចុងក្រោយដែលត្រូវឱ្យសិស្សធ្វើត្រូវបានរំលងជាញឹកញាប់។ គាត់បានកំណត់គោលដៅប្រចាំខែតូចមួយគឺ បញ្ចប់មេរៀនទាន់ពេលវេលាយ៉ាងហោចណាស់ពីរដងក្នុងមួយសប្តាហ៍។ ដោយបំបែកវាជាជំហានសាមញ្ញៗ គាត់បានរកឃើញថា បន្ទាប់ពីពីរបីសប្តាហ៍ គាត់អាចបញ្ចប់មេរៀនតាមកាលវិភាគ និងមានអារម្មណ៍ថាមិនសូវប្រញាប់ប្រញាល់។ ការផ្លាស់ប្តូរតិចតួច និងផ្តោតអារម្មណ៍ ប៉ុន្តែវាធ្វើឱ្យមេរៀនទាំងមូលដំណើរការទៅដោយរលូនជាងមុន។ គ្រូបង្រៀនម្នាក់ទៀតចង់ប្រើសំណួរសាកល្បង (quizzes) ក្នុងថ្នាក់រៀន ដើម្បីពិនិត្យមើលការយល់ដឹងរបស់សិស្សឱ្យកាន់តែមានប្រសិទ្ធភាព។ គាត់បានកត់សម្គាល់ឃើញថា បើគ្មានការត្រួតពិនិត្យជាប្រចាំទេ សិស្សមួយចំនួនបានជួបបញ្ហាដោយស្ងៀមស្ងាត់ ហើយពួកគេក៏មិនត្រូវបានកត់សម្គាល់ផងដែរ។ គាត់បានកំណត់គោលដៅ

ប្រចាំខែតូចមួយដោយ ផ្តល់សំណួរសាកល្បងខ្លីៗចំនួន ៣-៥ សំណួរយ៉ាងហោចណាស់ពីរដងក្នុងមួយសប្តាហ៍។ ដោយបំបែកវាជាជំហានសាមញ្ញៗ ដំបូងគាត់បានរៀបចំសំណួរសាកល្បងរហ័សមួយសម្រាប់មេរៀននីមួយៗ បន្ទាប់មកពិសោធន៍ជាមួយទម្រង់សំណួរផ្សេងៗគ្នា ហើយចុងក្រោយបានលើកទឹកចិត្តសិស្ស ឱ្យពិនិត្យចម្លើយរបស់ពួកគេដោយខ្លួនឯង។ បន្ទាប់ពីពីរបីសប្តាហ៍ គាត់បានឃើញថាសិស្សចូលរួមកាន់តែច្រើន ការយល់ខុសត្រង់ចំណុចមួយចំនួនត្រូវបានចាប់បានតាំងពីដំបូង ហើយគាត់អាចកែសម្រួលការបង្រៀនរបស់គាត់នៅនឹងកន្លែង។ ការផ្លាស់ប្តូរតូចមួយនៃការផ្តោតអារម្មណ៍ ប៉ុន្តែវាធ្វើឱ្យមេរៀនរបស់គាត់កាន់តែមានអន្តរកម្ម និងឆ្លើយតបបានល្អ។ វាគ្មានអ្វីធំដុំទេ គ្រាន់តែជាការកែលម្អតិចតួចប៉ុណ្ណោះដើម្បីធ្វើពិសោធន៍។ នៅក្នុងកិច្ចប្រជុំបន្ទាប់ មនុស្សគ្រប់គ្នាចែករំលែកអ្វីដែលពួកគេបានព្យាយាម និងអ្វីដែលពួកគេបានកត់សម្គាល់។ ភាពជោគជ័យ ការភ្ញាក់ផ្អើល សូម្បីតែការបរាជ័យ ទាំងអស់សុទ្ធតែមានតម្លៃ។ នៅពេលដែលគ្រូបង្រៀននិយាយដោយបើកចំហអំពីការពិសោធន៍របស់ពួកគាត់ ពួកគាត់រៀនលឿនជាងមុន និងមានអារម្មណ៍ថាមិនសូវឯកា។ វាជាវិធីសាស្រ្តសាមញ្ញមួយ ប៉ុន្តែសូមមើលថាតើវាអាចមានប្រសិទ្ធភាពប៉ុណ្ណា!

## រក្សាកំណត់ត្រាសាមញ្ញនៃគំនិត

សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន កាន់តែមានប្រយោជន៍ថែមទៀត នៅពេលដែលអ្នករក្សាគំនិតល្អៗដែលបានមក។ មិនចាំបាច់មានឧបករណ៍ទំនើបៗទេ។ ក្រុមភាគច្រើនប្រើអ្វីដែលសាមញ្ញបំផុត៖

- សៀវភៅកត់ត្រាដែលបានចែករំលែក ដែលគ្រូបង្រៀនកត់ត្រាសកម្មភាពជោគជ័យ ឬគន្លឹះឆ្លាតវៃ។
- ក្តារព័ត៌មាននៅក្នុងបន្ទប់គ្រូបង្រៀ នដែលមានចំណងជើងថា "ការអនុវត្តល្អបំផុតរបស់យើង" ដែលអ្នកណាម្នាក់អាចដាក់យុទ្ធសាស្រ្តដែលដំណើរការបានល្អ។
- ប្រើប្រាស់ Google Drive ប្រសិនបើសាលារៀនមានអ៊ីនធឺណិត ជាមួយនឹងកំណត់ចំណាំខ្លីៗ ឬរូបថតសកម្មភាព។

យូរៗទៅ ស្លាកស្នាមតូចៗទាំងនេះក្លាយជាកំណប់ទ្រព្យពិតប្រាកដ។ គ្រូបង្រៀនថ្មីអាចបើកសៀវភៅកត់ត្រា ឬក្តារខៀន ហើយរៀនភ្លាមៗពីបទពិសោធន៍រួមជាច្រើនឆ្នាំ។ ហើយសម្រាប់ក្រុម វាជាការរំលឹកថាការសន្ទនារបស់ពួកគាត់ដែលបានកំពុងកសាងអ្វីមួយដែលស្ថិតស្ថេរ។

ការចាប់ផ្តើមសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀនមិនចាំបាច់ស្មុគស្មាញនោះទេ។ ចាប់ផ្តើមតូច រក្សាវាឱ្យមានលក្ខណៈក្រៅផ្លូវការ ហើយផ្តោតលើការចែករំលែកគំនិតជាក់ស្តែង។ យូរៗទៅ ក្រុមនេះនឹងរីកចម្រើនដោយខ្លួនឯង នៅពេលដែលអ្នកដទៃកត់សម្គាល់ឃើញពីបរិយាកាសវិជ្ជមាន នៃគ្រូបង្រៀនគាំទ្រគ្នាទៅវិញទៅមក ផ្លាស់ប្តូរគន្លឹះ និងការអបអរសាទរភាពជោគជ័យក្នុងថ្នាក់រៀនតូចៗ។ ការចង់ដឹងចង់ឃើញ និងការជឿទុកចិត្តទាក់ទាញអ្នកចូលរួមថ្មី ជួនកាលសូម្បីតែអ្នកដឹកនាំសាលា ឬគ្រូប្រឹក្សាគរុកោសល្យ។ ជាការពិតណាស់ បញ្ហាប្រឈមអាចកើតឡើង។ គ្រូបង្រៀនច្រើនតែព្រួយបារម្ភថាពួកគាត់មិនមានពេលវេលា ឬមិត្តរួមការងារមានភាពខ្មាសអៀន ឬខ្លាចការរិះគន់ ឬថាពួកគេខ្វះសម្ភារៈ។ ប៉ុន្តែឧបសគ្គទាំងនេះងាយស្រួលយកឈ្នះជាងអ្វីដែលយើងគិត៖ រក្សាកិច្ចប្រជុំឱ្យខ្លី (២០ នាទីគឺគ្រប់គ្រាន់) ចាប់ផ្តើមជាមួយក្រុមដែលគួរឱ្យទុកចិត្ត ហើយផ្តោតលើការចែករំលែកវិជ្ជមាន ហើយចងចាំថាអ្វីដែលអ្នកពិតជាត្រូវការគឺការសន្ទនា និងគំនិត ដោយមិនត្រូវការឧបករណ៍ពិសេសទេ។ នៅក្នុងខ្លឹមសាររបស់វា សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀនមួយរីកចម្រើន ពីព្រោះមនុស្សមានអារម្មណ៍ថាត្រូវបានស្វាគមន៍ គាំទ្រ និងបំផុសគំនិតដោយអ្វីដែលពួកគេបានឃើញ។ ហើយនៅពេលដែលរឿងនោះកើតឡើង ទាំងគ្រូ និងសិស្សទទួលបានអត្ថប្រយោជន៍។ ដូចដែលគ្រូបង្រៀនភាសាអង់គ្លេសម្នាក់មកពីទីក្រុងភ្នំពេញបានឆ្លុះបញ្ចាំងថា "ខ្ញុំនឹងមានអារម្មណ៍ថាវង្វេងផ្លូវ ប្រសិនបើយើងមិនមាន PLC ក្នុងរយៈពេលមួយសប្តាហ៍។ ខ្ញុំនឹងគិតថា តើយើងធ្វើអ្វី? ដូចជាផែនការអ្វី? PLC ពិតជាសំខាន់ណាស់" ។

# ការជួយក្មេងស្រីខ្វះភាពកក់ក្តៅក្នុងគ្រួសារ

ដោយៈ **អ៊ូ សុខលី**



បើយើងនិយាយពាក្យកុមារនរណាក៏ដឹង នរណាក៏ស្គាល់ ហើយរឹតតែអាចនិយាយបានទៀតថាកុមារជាទំពាំងស្នងឫស្សី និងជាធនធានមនុស្សដ៏សំខាន់បំផុតសម្រាប់អភិវឌ្ឍប្រទេសជាតិទាំងមូលនាថ្ងៃអនាគត។ ទំពាំងដ៏ខ្ចីទាំងនេះងាយរងគ្រោះពីកត្តាជាច្រើនទាំង កត្តាដី កត្តាពូជ ពន្លឺ អាកាសធាតុ និង កត្តាការថែទាំ។ទំពាំងរីកលូតលាស់ក្លាយជាឫស្សីខ្លឹមក្រៅដ៏រឹងមាំបើធៀបទៅនឹងកុមារពួកគេមិនត្រឹមតែត្រូវការអាហារូបត្ថម្ភ និងការអប់រំតែប៉ុណ្ណោះទេ! តែអាចនិយាយបានថាការផ្តល់ភាពកក់ក្តៅ មិនរើសអើងក៏ជាកត្តាសំខាន់បំផុតដែលកុមារត្រូវការខានពុំបាន។ គ្រប់គ្នាដឹងហើយថាកុមារត្រូវការភាពកក់ក្តៅ មិនរើសអើងតើហេតុអ្វីបានជាកុមារក្រីក្រនៅតាមជនបទមួយចំនួនធំ នៅតែទទួលការរើសអើងពីមនុស្សជុំវិញខ្លួន ពុំទទួលបានភាពកក់ក្តៅពីមនុស្សធំទាំងឡាយ?

ជាការពិតណាស់ការផ្តល់ភាពកក់ក្តៅ និងមិនរើសអើងជាភាពចាំបាច់ដែរដែរមនុស្សធំទាំងឡាយត្រូវធ្វើចំពោះកុមារឬអាចនិយាយបានឡើងងាយស្រួលតែចំពោះការស្តែងចេញជាទង្វើជារឿងមនុស្សធំឬអ្នកពាក់ពន្ធ័ជាមួយកុមារពុំសូវឬមិនស្តែងចេញតែម្តង។ វាជារឿងជាក់ស្តែងមួយបានកើតឡើងក្នុងសាលាបឋមសិក្សាមេម៉ៃក្នុងឆ្នាំសិក្សា២០២១-២០២២ មានកុមារីម្នាក់ គ្រួសាររបស់នាងមានកូនស្រីពីរនាក់ បងស្រីរបស់នាងនិងនាងពុំបានទទួលភាពកក់ក្តៅពីគ្រួសារថែមទាំងទទួលបានការរើសអើងពីមិត្តរួមថ្នាក់ទៀតផង។

ជាស្ថានភាពដ៏លំបាកខ្លាំងបំផុតចំពោះកុមារីម្នាក់នេះមិនបានទទួលភាពកក់ក្តៅ និង ការរើសអើងក្លាយជាទម្លាប់រហូតដល់កុមារីមានសភាពភ័យខ្លាចចំពោះវត្តមានគ្រូ វត្តមានមិត្តរួមថ្នាក់។ ប៉ុន្តែចំពោះស្ថានភាពដ៏លំបាកមួយនេះក្នុងនាមជាមនុស្សធំ ឬអ្នកពាក់ពន្ធ័ជាមួយកុមារយើងត្រូវជួយឱ្យអស់ពីលទ្ធភាពទោះលទ្ធផលទទួលបែបណាក៏ទទួល។ សញ្ញាណដំបូងដែលខ្ញុំសង្កេតឃើញថា គឺឈរអោបកាតាបនៅកៀនជញ្ជាំងខាងក្រោយតុរបស់សិស្សក្នុង ថ្នាក់រៀនអោនមុខចុះស្របពេលកុមារផ្សេងៗមានកន្លែងអង្គុយរៀងៗខ្លួន។ មានពេលមួយ ខ្ញុំដើរទៅជិតសួរគាត់ហេតុអ្វីបានកូនមិនចូលអង្គុយនៅតុជាមួយមិត្តភក្តិ? តែនាងមិនឆ្លើយតបបែរជាយកកាតាបមកបាំងមុខយំហើយក្មេងផ្សេងប្រាប់ថាខ្ញុំមិនឱ្យអង្គុយជាមួយទេអ្នកគ្រូពីព្រោះមានក្លិនស្អុយ ហើយឆ្អេះទៀត។



ជាការពិតខ្ញុំក៏ទទួលក្លិនបែបនោះពិតមែននៅពេលខ្ញុំឈរជិតនាង សង្កេតមើលសម្លៀកបំពាក់ឃើញថាកង្វក់នាងពិតជាកង្វះអនាម័យខ្លួនប្រាណពិតប្រាកដមែន។ នាងមានសភាពភ័យជាខ្លាំងពេលខ្ញុំទៅជិតនាង។ ពេលខ្ញុំរៀបចំកន្លែងអង្គុយឱ្យនាងអង្គុយជាមួយមិត្ត នាងមិននិយាយជាមិត្តរួមតុ ហើយអង្គុយនៅចុងតុ។ ចំពោះដំណោះស្រាយក្នុងករណីកុមារម្នាក់នេះមិនមានលក្ខណៈស្តង់ដា ឬភាពល្អឥតខ្ចោះនោះទេតី លក្ខណៈធម្មតាៗអាចធ្វើទៅបាន ដោយមិនមានសម្ពាធផ្លូវកាយ ផ្លូវចិត្ត ហើយរីករាយដែរបានធ្វើគឺ៖

១. បើកបេះដូងទទួលយកគ្រប់យ៉ាង៖ ទទួលស្គាល់ថាគ្រប់យ៉ាងជាឧបនិស្ស័យមិនមែនកើតឡើងដោយចៃដន្យនោះទេ ព្យាយាមជួយកុមារដែលជួបបញ្ហាបែបនេះជារឿងត្រូវធ្វើ ជាតួនាទីត្រូវចែករំលែក ផ្តល់ក្តីស្រឡាញ់។ លើកទឹកចិត្តខ្លួនឯងជានិច្ចថា ការជួយកុមារមិនដើម្បីផលប្រយោជន៍ណាមួយសម្រាប់ខ្លួនឯង មិនមែនដើម្បីឱ្យនណាម្នាក់ទទួលស្គាល់ថាខ្លួនជាមនុស្ស មិនដើម្បីផ្គាប់ចិត្តនណាម្នាក់ ឬដើម្បីការសរសើរពីនរណានោះទេ តែជាតួនាទីត្រូវជួយ ត្រូវចែករំលែកក្នុងនាមជាអ្នកពាក់ព័ន្ធជាមួយកុមារ។

២. យកអារម្មណ៍ក្មេងមកដាក់លើខ្លួន៖ សាកស្រមៃមើលបើក្មេងម្នាក់នោះជាខ្លួនយើង តើយើងអាចទទួលយកគ្រប់បានដែរឬទេ ប្រាកដណាស់ថាមិនបាន។ ពេលយើងបានសាកស្រម៉ៃរួចហើយយើងសំលឹងឃើញផែនការ សកម្មភាពដែលត្រូវធ្វើដើម្បីជួយកុមារ។

៣. មានភាពអត់ធ្មត់៖ វាពិតហើយសាមញ្ញបំផុតដែរគ្រប់គ្នាធ្វើអ្វីមួយតែងតែចង់បានលទ្ធផលភ្លាមៗ តែការជួយកុមារដែលមានសភាពបែបនេះមិនជារឿងធ្វើហើយទទួលបានលទ្ធផលត្រឹមរយៈពេលមួយថ្ងៃឬពីរថ្ងៃនោះទេ។

៤. ត្រូវការពេលវេលា៖ ចំណាយពេលវេលាបង្ហាញក្តីស្រឡាញ់ក្នុងនាមជាម្តាយឬជាឪពុកទី២ជារឿងពិបាកពីព្រោះកុមារពុំបានស្គាល់ក្តីស្រឡាញ់ពីឪពុកម្តាយ ការចំណាយពេលធ្វើជាមិត្តយល់ចិត្តជាមួយគាត់ ការចំណាយពេលស្វែងយល់ពីសេចក្តីត្រូវការរបស់គាត់។

ជារឿងពិតជាក់ស្តែងចំពោះកុមារម្នាក់នេះខ្ញុំបានប្រើពេលវេលាបង្ហាញក្តីស្រឡាញ់ក្នុងជាម្តាយ ជាគ្រូបង្រៀនរយៈពេលមួយខែដំបូងគឺមិនទទួលបានលទ្ធផលអ្វីទាំងអស់គឺនាងនៅសភាពដដែល។ ប៉ុន្តែចាប់ពីខែទីពីរដែលគាត់មករៀនខ្ញុំ ប្រើរូបភាពជាមិត្តដោយនៅពេលរៀនក្នុងថ្នាក់ខ្ញុំឱ្យគាត់មកអង្គុយនៅតុរបស់ខ្ញុំ នៅពេលសិស្សដទៃទៀតធ្វើលំហាត់ លើកទឹកចិត្តគាត់តាមរយៈចាប់ដៃគាត់ធ្វើកិច្ចការសមល្មម និងសមត្ថភាពគាត់ដូចជានាំគាត់សរសេរអក្សរកបានមួយទំព័រ រួចសរសើរថា៖យី!កូនពូកែមែស! ទះដៃឱ្យគាត់។ រយៈពេលបីខែខ្ញុំទទួលបានស្នាមញញឹមដំបូងបំផុតដែរគាត់ញញឹមមកកាន់ខ្ញុំ ស្នាមញញឹមដំបូងនេះហើយបង្ហាញឱ្យឃើញថាគាត់ទទួលអារម្មណ៍សុវត្ថិភាព ទំនុកចិត្ត និងក្តីស្រឡាញ់ចំពោះគ្រូ អាចនិយាយឱ្យខ្លីជាសញ្ញាបង្ហាញថាយកបេះដូងកុមារម្នាក់នេះបាន ។ គាត់ចាប់ផ្តើមហ៊ានលេងជាមួយមិត្តរួមថ្នាក់ម្នាក់ដែរខ្ញុំរៀបចំឱ្យអង្គុយជាមួយបែបរៀនៗ។ ចំពោះករណីនេះរយៈពេល៧ខែនៃការសិក្សារបស់ទើបគាត់ទើបគាត់អាចចូលរួមធ្វើកិច្ចការក្រុមក្នុងម៉ោងសិក្សាបានតែក្នុងសភាពពុំសូវមានទំនុកចិត្ត ក្នុងរយៈពេលនេះគាត់ចាប់ផ្តើម មានមិត្តស្និតស្នាលម្នាក់ដើរកាន់ដៃគ្នាចូល បណ្ណាល័យ លេងជាមួយគ្នា ទិញនំញាំជាមួយគ្នា។

៥. ធ្វើសកម្មភាពដដែលៗ៖ ទទួលស្គាល់ថាខ្ញុំធ្វើសកម្មភាពក្រោមរូបភាពជាមិត្តនិងត្រូវប្រើពាក្យពិរោះដដែលៗ ដូចពាក្យថាកូនឬហៅថាកូនស្រី ញញឹមដាក់គាត់គ្រប់ពេលប្រសិនបើគាត់សំលឹងមើលមកយើង។ ពេលចេញលេងខ្ញុំនាំសិស្សផ្សេងទៀតលេងល្បែងសិក្សាជាមួយគាត់ ហើយតែងតែសួរគាត់ថាតើកូនបានញាំបាយនៅ? បានម្ហូបអ្វី? តើកូនញាំឆ្ងាញ់ទេ? ញាំជាមួយនរណា? ហើយកូនមកសាលារៀនដោយខ្លួនឯងឬនរណាជូនមក? ទាំងនេះជាសំនួរសួរជាប្រចាំថ្ងៃនៅពេលជួបគាត់?

៦. មើលកែវភ្នែក៖ ការមើលកែវភ្នែកគឺជារឿងសំខាន់មួយដោយខានពុំបាន នៅក្នុងកែវភ្នែកបានបង្ហាញការឈឺចាប់សេចក្តីត្រូវការដោយពុំបាននិយាយ ឬបង្ហាញសកម្មភាព។ ជាក់ស្តែងកុមារម្នាក់នេះ កែវភ្នែកពោរពេញដោយភាពភ័យខ្លាច មិនហ៊ាននិយាយ មិនហ៊ានឆ្លើយនៅពេលគ្រូសួរ ខ្លាចការស្តីបន្ទោស ខ្លាចការវាយបើនិយាយខុស ឆ្លើយខុស។

៧.ការណាត់ជួបអាណាព្យាបាល៖ ជារឿងមួយចំបាច់ត្រូវតែមានការចូលសហការពីអាណាព្យាបាល តែចំពោះករណីនេះវាកាន់តែស្មុគស្មាញពីព្រោះអាណាព្យាបាលមិនខ្វល់មិនផ្តល់ភាពកក់ក្តៅហើយជាឫសនៃបញ្ហា។ តើធ្វើយ៉ាងណាដើម្បីទទួលការណាត់ជួបដ៏ល្អប្រសើរ? តាមរយៈការផ្តាំតាមកូនសុំឱ្យម៉ាក់ឬប៉ាមកជួបក្នុងពេលម៉ោងគាត់ទំនេរ ទោះដឹងថាមិនទទួលជោគជ័យក៏ដោយ។ មួយវិញទៀត គឺផ្តាំតាម

មិនមែនជារឿងលំបាកទេប្រសិន បើប្រើគ្រប់មធ្យោបាយក្នុងការណាត់ជួបអាណាព្យាបាលហើយពួកគាត់មិនបានមកតាមការណាត់ យើងអាចស្នើរសុំការជួយសម្របសម្រួលតាមរយៈមេភូមិដែរស្ថិតនៅភូមិពួកគាត់រស់នៅ។ ចំពោះម្តាយកុមារម្នាក់នេះខ្ញុំបានណាត់ជួបរយៈពេលពីរខែទើបគាត់ហ៊ានចំណាយពេលវេលារបស់គាត់មកជួបគ្រូម្តង។ ដោយលែងរយៈពេលពីរខែ ខ្ញុំបានទៅផ្ទះគាត់ពីរដងដើម្បីជួបអាណាព្យាបាលតែមិនបានជួបគាត់នោះទេ។

៧. អំឡុងពេលជួបអាព្យាបាល

អត់ធ្មត់ឱ្យបានខ្ពស់បំផុត ពីព្រោះអាណាព្យាបាលកុមារដែរស្ថិតក្នុងស្ថានភាពបែបនេះ ពួកគាត់មានសម្ពាធច្រើនរហូតអាចខឹងសម្បាពេលមកជួបយើងដែរ។ តែក្នុងនាមជាឪពុកម្តាយតែស្រឡាញ់កូន។

- ផ្តល់ឱកាសឱ្យគាត់និយាយមុនប្រសិនបើគាត់មានកំហឹងតាមរយៈការសង្កេតទឹកមុខឬអាចសួរទៅកាន់គាត់ថាតើម៉ាក់មានអ្វីចង់និយាយមកកាន់ខ្ញុំទេ?
- ត្រៀមស្តាប់គាត់យ៉ាងយកចិត្តទុកដាក់បំផុត
- បង្ហាញក្តីស្រឡាញ់ចំពោះកូនគាត់ថាយើងបារម្ភណ៏កូនគាត់ មិនចាញ់ក្តីស្រឡាញ់របស់គាត់ចំពោះកូន

ករណីក្មេងស្រីនេះ គឺក្នុងថ្ងៃដែលម្តាយក្មេងស្រីម្នាក់នោះមកជួបខ្ញុំលើកដំបូង នៅព្រឹកថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០២២នៅវេលាម៉ោង៨និង០២នាទី។ នៅពេលដែរគាត់មកជួបដំបូងទឹកមុខរបស់គាត់ពោពេញដោយការខឹង ខ្ញុំសង្កេតឃើញមុខគាត់មាំ មិនរីករាយ ហើយគាត់សួរខ្ញុំតាំងពីមាត់ទ្វារក្នុងថ្នាក់ថា៖ អ្នកគ្រូឱ្យខ្ញុំមកជួបមានការអី?ខ្ញុំរវល់ណាស់គ្មានពេលទំនេរទេ!។ ខ្ញុំទាញកៅអីរបស់ខ្ញុំឱ្យគាត់អង្គុយសិនតែគាត់ប្រកែកមិនអង្គុយទេ គាត់ឈរក៏បានពីព្រោះគាត់ប្រញ៉ាប់ខ្លាំងណាស់។ ខ្ញុំបានឱ្យសិស្សចូលបណ្ណាល័យហើយក៏ស្នើសុំឱ្យគាត់អង្គុយម្តងទៀត។ ខ្ញុំសួរទៅគាត់ថា៖តើម៉ាក់មានអ្វីនិយាយជាមួយខ្ញុំទេ? គាត់ឆ្លើយថា៖កូនខ្ញុំដឹងតែរៀនមិនចេះហើយ អ្នកគ្រូវាយវាចុះខ្ញុំមិនថាអ្វីទេ!។ខ្ញុំញញឹមហើយសួរគាត់ថា៖ម៉ាក់ស្រឡាញ់កូនទេ? គាត់ប្រែទឹកមុខពីមុខមាំមកជាស្លូតវិញហើយឆ្លើយថាស្រឡាញ់! ស្រឡាញ់ខ្លាំងណាស់!។ ស្របពេលនោះគាត់បានយំចេញមកហើយរៀបរាប់រឿងដែរគាត់យកគ្រួសារថ្មីដែរមិនមែនឪពុកបង្កើតរបស់កូនទាំងពីរ។ រឿងដែរក្មេងស្រីនេះបានជួបតាមរយៈម្តាយនិយាយធ្វើឱ្យខ្ញុំជាអ្នកស្តាប់ក៏ឈឺលអារម្មណ៍ទប់ទឹកភ្នែកមិនជាប់ គាត់និយាយចេញអស់ តែទឹកភ្នែកគាត់នៅតែហូរដដែល គាត់សម្រួលអារម្មណ៍រួចហើយខ្ញុំបាននិយាយពីក្តីស្រឡាញ់ម្តាយគ្រប់រូបមានចំពោះកូនគឺដូចគ្នាតែអ្វីខុសគ្នាគឺសកម្មភាពប្រចាំថ្ងៃ ខ្ញុំបង្ហាញក្តីអាណិតនិងចង់ជួយកូនគាត់តាមរយៈការសង្កេតឃើញកូនគាត់ ស្នើសុំឱ្យគាត់ជួយកូនដោយខ្លួនឯង ព្យាយាមជួយកូនដើម្បីកុំឱ្យមានពាក្យស្តាយក្រោយ ផ្តើមចេញពីសកម្មភាពប្រចាំថ្ងៃផ្តោតលើអនាម័យ សម្ភារៈសិក្សា ផ្តល់ភាពកក់ក្តៅឱ្យកូនតាមរយៈការនិយាយស្តី ពេលវេលានៅជាមួយកូន។

៦. សកម្មភាពត្រូវធ្វើជាប្រចាំ

ក. ស្វែងរកការជួយពីសង្គម

- បរិយាកាសថ្នាក់រៀន

ត្រង់ចំណុចនេះយើងដឹងស្ទើរតែគ្រប់គ្នាហើយថាកុមារងាយចុះសម្រុងគ្នា កុមាររៀនពីគ្នាបានយ៉ាងងាយ ក្នុងថ្នាក់រៀនជាឱកាសមួយដែរត្រូវរៀបចំមិត្តដើម្បីលេងជាមួយគ្នា រៀនពីគ្នាចំពោះកុមារកង្វះភាពកក់ក្តៅយើងអាចរើសយកកុមារដែរមានចរឹកទន់ភ្លន់ មិនឆាប់ខឹងអាចត្រឹមបីនាក់ល្មម លេងជាមួយមិត្តអាចបង្កើត ទំនាក់ទំនងល្អ ទំនុកចិត្ត រហូតពួកគេអាចនិយាយរឿងក្នុងចិត្តប្រាប់គ្នាក៏មាន។

ខ. ការផ្តល់ជាសម្ភារៈ

ចំពោះការជួយជាសម្ភារៈគាំទ្រ លើការសិក្សាក៏ជាកត្តាលីករសម្រាប់កុមារឱ្យមានភាពសប្បាយរីករាយ ចង់សិក្សា ហើយមានអារម្មណ៍ថាខ្លួនមិនឯកោ ហើយក៏ជាកម្លាំងចិត្តដែលផ្តល់ដល់អាណាព្យាបាលដោយប្រយោលក្នុងការ ជួយកូនផងដែរ។ សម្ភារៈផ្តល់ឱ្យកុមារយើងអាចទទួលពីសប្បុរសជនក្នុងមូលដ្ឋាន និងក្រៅមូលដ្ឋាន។ចំពោះកុមារម្នាក់នេះគឺខ្ញុំបានផ្តល់សម្ភារៈសិក្សារយៈពេលពីរឆ្នាំ នៃការសិក្សារបស់គាត់តាមរយៈការជួយរបស់សប្បុរសជនខាងក្រៅ។

នៅក្នុងសង្គមកុមារ ដែលខ្វះភាពកក់ក្តៅក្នុងគ្រួសារតែងតែទទួលបានការរើសអើងពីមិត្តភក្តិ និងអ្នកជុំវិញខ្លួន ប្រឈមជាមួយការបោះបង់ការសិក្សា កុមារមានចរឹករឹងរូស ជាក្មេងពាលឬអាចនិយាយបានថាជាចៃក្នុងសង្គមនៅថ្ងៃខាងមុខ។ គ្រប់គ្នាដឹងហើយថាកុមារទាំងនេះត្រូវការ ជួយពីគ្រប់អ្នកពាក់ពន្ធ័ តើហេតុផលអ្វីបានកុមារទាំងនោះស្ទើរតែពុំបានទទួលបានការជួយពីអ្នកពាក់ពន្ធ័?

១. ភាពអាត្មានិយម

មិនមែនជាបងប្អូន សាច់ញាតិខ្លួនទោះជួយក៏ពុំទទួលបាលផលប្រយោជ៏នអ្វី ខ្លាចត្រូវចំណាយថវិកាផ្ទាល់ខ្លួន។

ផ្ទត់គំនិតប្រកាន់ភ្ជាប់ថារឿងអ្នកដទៃកុំចេះដឹង បើជួយអាចគ្មាននណាមើលឃើញអំពើល្អដែរខ្លួនខំជួយខ្លាចក្លាយជាជនរងគ្រោះក្នុងការជួយ។

២.បេះដូងតូចចង្អៀត

មិនបើកចិត្តសាកស្រមៃថាបើខ្លួនជាកុមារដែរស្ថិតក្នុងស្ថានភាពបែបនោះតើខ្លួនទទួលការឈឺចាប់បានដែរឬទេ?។ មិនមានភាពក្លាហានក្នុងការជួយ គិតថាខ្លួនមិនអាចជួយបាន។

៣.ភាពអំណត់

មានភាពអន្ទះសារចង់ឃើញលទ្ធផលភ្លាមៗ ពេលលទ្ធផលមិនដូចអ្វីដែរចង់បានមានអារម្មណ៍ហត់នឿយ ហើយក៏បោះបង់ងាយរំលាយក្តីសង្ឃឹមដែលចង់ជួយ អារម្មណ៍ផ្តេកផ្តួលលើគំនិតអវិជ្ជមានដូចជាគ្មាននណាអាចជួយបានទេ គ្រប់យ៉ាងជារឿងកម្មផលដែលម្នាក់ៗ បានសាងមករៀងៗខ្លួនៗនរណាសាងអីអ្នកនោះទទួលផលនោះហើយ។ ការជួយកុមារត្រូវការពេលវេលា ឆ្លងតាមបទពិសោធន៍កុមារខ្លះអាចប្រើរយៈពេលបីខែ ប្រាំមួយខែ មួយឆ្នាំ កុមារខ្លះប្រើ រយៈរហូតដល់ពីរឆ្នាំនៃរយៈពេលនៃការសិក្សា។

៤.កង្វះការជួយគាំទ្រពីសង្គម

ពេលខ្លះចង់ជួយតែមិនដឹងថាគួរជួយតាមរបៀបណាវិធីសាស្រ្តណា ចាប់ផ្តើមពីចំណុចណាមុន។ ពេលជួយកុមារបែរជារងការរិះគន់ ពីមនុស្សមួយចំនួនតូចដែលមិនយល់បែរជាគិតបែបអាត្មានិយមថាធ្វើដើម្បីផលប្រយោជន៍ ធ្វើដើម្បីផ្គាប់ចិត្តនណាម្នាក់ ធ្វើដើម្បីទទួលបានការសរសើរពីអ្នកជុំវិញខ្លួន និងការលាបពណ៌ផ្សេងៗទៀត សង្គមមិនសាទរសង្គមមិនលើកទឹកចិត្ត។

សរុបមកចំពោះករណីក្មេងស្រីម្នាក់នេះដែលកង្វះភាពកក់ក្តៅក្នុងគ្រួសារដែរជា ឬសគល់នៃការរើសអើងពីមិត្តរួមថ្នាក់ក្នុងឆ្នាំសិក្សា ២០២១-២០២២ ចំពោះការជួយគឺទទួលបានជោគជ័យឬទទួលផលវិជ្ជមានរួមមានៈ

- កុមារមានភាពក្លាហានមិនភ័យខ្លាច
- មានអនាម័យខ្លួនប្រាណ
- មានមិត្តស្និតស្នាល សម្របខ្លួននិងមានទំនាក់ទំនងល្អជាមួយមិត្តរួមថ្នាក់បាន ហ៊ាននិយាយស្តី លេងជាមួយមិត្តផ្សេងៗ
- អាណាព្យាបាលរីករាយក្នុងការសហការ(គាត់មានពេលមកជួបគ្រូទាំងមិនបានណាត់ជួបឬអញ្ជើញ)
- អាណាព្យាបាលរីករាយនៅពេលកូនមានសភាពដូចក្មេងដទៃ(គាត់មកជួបគ្រូហើយនិយាយពាក្យអរគុណនិងផ្ញើក្តីសង្ឃឹមលើកូននៅថ្ងៃខាងមុខ)។





# ល្បែងសិក្សារបស់គីម

ដោយ Stanislas Kowalski បកប្រែដោយ គង់ សុគន្ធា

| | | | |
|---|---|---|---|
| **ប្រភេទនៃល្បែង៖** | បែបស្ងប់ស្ងាត់ | **រយៈពេល៖** | ប្រហែល 5 នាទី |
| **គោលបំណង៖** | ពង្រឹងការចងចាំរយៈពេលខ្លី | **អាយុ៖** | គ្រប់វ័យ |
| **មុខវិជ្ជា៖** | មិនកំណត់មុខវិជ្ជាជាក់លាក់ទេ | **ចំនួនអ្នកចូលរួមលេង៖** | 1 ដល់ 20 នាក់ |
| **លក្ខណៈពិសេស** | ងាយស្រួលលេង & ពន្យល់ | **សម្ភារៈ៖** វត្ថុតូចៗចម្រុះគ្នាពី 20 ទៅ 30 មុខ, កន្សែង ឬក្រណាត់ធំមួយ, នាឡិកាកំណត់ពេល, ក្រដាស និងប៊ិច | |

## លក្ខខណ្ឌក្នុងការលេង

អាជ្ញាកណ្ដាលលាក់វត្ថុចន្លោះពី 20 ទៅ 30 មុខ នៅក្នុងកន្សែង ហើយឱ្យអ្នកលេងមកឈរជុំវិញគាត់ ។គាត់លាកន្សែងបង្ហាញវត្ថុទាំងនោះក្នុងរយៈពេល 60 ឬ 90 វិនាទី អាស្រ័យលើសមត្ថភាពរបស់អ្នកលេង។ ក្នុងអំឡុងពេលនោះ អ្នកលេងត្រូវសង្កេតដោយស្ងប់ស្ងាត់ និងព្យាយាមចងចាំវត្ថុទាំងនោះ។ បន្ទាប់មក អាជ្ញាកណ្ដាលគ្របវត្ថុទាំងនោះវិញ ហើយអ្នកលេងត្រូវប្រាប់ឈ្មោះវត្ថុដែលខ្លួនចាំ។ ប្រសិនបើមានអ្នកលេងច្រើន គួរតែឱ្យពួកគេសរសេរឈ្មោះវត្ថុទាំងនោះលើក្រដាស។ ជាចុងក្រោយ អាជ្ញាកណ្ដាលបើកបង្ហាញវត្ថុម្ដងទៀតដើម្បីផ្ទៀងផ្ទាត់ចម្លើយ។

## ទម្រង់ប្លែកៗនៃល្បែងសិក្សានេះ

មានវិធីលេងប្លែកៗជាច្រើនដើម្បីលេងល្បែងនេះ ហើយនេះគឺជាចំណុចដែលគួរឱ្យចាប់អារម្មណ៍បំផុត ៖

### នៅតាមដងផ្លូវ

អ្នកលេងដើរកាត់មុខហាង ហើយព្យាយាមចងចាំវត្ថុដែលដាក់តាំងនៅក្នុងទូកញ្ចក់មុខហាង។ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យកត់ត្រាឡើយ ហើយត្រូវទៅរាយការណ៍ប្រាប់អាជ្ញាកណ្ដាលដែលអង្គុយនៅចម្ងាយឆ្ងាយបន្តិចពីទីនោះ ។

### តាមរយៈរសជាតិ និងក្លិន

អ្នកលេងត្រូវចងភ្នែក ហើយត្រូវបានគេដាក់ឱ្យសាកល្បងភ្លក់រសជាតិអាហារ ឬហិតក្លិនវត្ថុផ្សេងៗដើម្បីទាយឱ្យដឹងថាវាជាអ្វី។ អាជ្ញាកណ្ដាលត្រូវប្រាកដថាសម្ភារៈទាំងនោះមានសុវត្ថិភាព (គ្មានជាតិគីមីគ្រោះថ្នាក់) និងមិនប្រើល្បែងនេះដើម្បីលេងសើចបែបមិនសមរម្យ (គ្មានវត្ថុកខ្វក់ ឬក្លិនស្អុយខ្លាំង) ។

## តម្លៃអប់រំ

ល្បែងសិក្សានេះមានតម្លៃអប់រំខ្ពស់ សូម្បីតែនៅក្នុងសាលារៀន។ វាជាការហ្វឹកហាត់ដ៏ល្អសម្រាប់ការចងចាំ។ ចំពោះអ្នកអប់រំដែលមានបទពិសោធន៍ អត្ថប្រយោជន៍របស់វាគឺលើសពីនេះទៅទៀត។ អ្នកលេងដែលពូកែនឹងប្រើប្រាស់ជំនាញនៃការគិតរបស់ខ្លួនឯង ដើម្បីជាយុទ្ធសាស្ត្រដើម្បីឈ្នះ។ គ្រូបង្រៀនអាចបង្រៀនយុទ្ធសាស្ត្រទាំងនេះ ដើម្បីឱ្យសិស្សយកទៅប្រើប្រាស់ក្នុងស្ថានភាពផ្សេងៗទៀត ដូចជាការទន្ទេញមេរៀនជាដើម។ ឧទាហរណ៍៖ អ្នកលេងខ្លះព្យាយាមចងចាំរូបភាពសរុបនៃវត្ថុទាំងអស់ ដូចជាការថតរូបទុកក្នុងខួរក្បាល។ អ្នកខ្លះទៀតហៅឈ្មោះវត្ថុក្នុងចិត្ត ហើយបែងចែកវាជាក្រុមៗ (ដូចជា សម្ភារៈសិក្សា, ឧបករណ៍ផ្ទះបាយ ជាដើម) ឬព្យាយាមភ្ជាប់ទំនាក់ទំនងរវាងវត្ថុ និងទីតាំងរបស់វានៅលើតុ ។

# ល្បែងសម្លឹងកែវភ្នែក

ដោយ Stanislas Kowalski បកប្រែដោយ គង់ សុគន្ធា

| | | | |
|---|---|---|---|
| ប្រភេទនៃល្បែង៖ | ស្មៀមស្ងាត់ក្នុងផ្ទះ/ក្នុងម្លប់ | រយៈពេល៖ | ៣ វិនាទីឡើងទៅ |
| គោលបំណង៖ | ការគ្រប់គ្រងចិត្ត បង្អើតសំណើច | អាយុ៖<br>លេងបានគ្រប់វ័យ | មិនកំណត់<br>អាយុឡើយ |
| មុខវិជ្ជា៖ | សិល្បៈ/ការសម្តែង | ចំនួនអ្នកចូលរួមលេង៖<br>២ នាក់ | មិនត្រូវការសម្ភារៈអ្វីទាំងអស់ |
| លក្ខណៈពិសេស | ងាយស្រួលក្នុងការអនុវត្ត<br>ងាយស្រួលក្នុងការពន្យល់ | អាជ្ញាកណ្តាល៖<br>អ្នកលេងកាត់សេចក្តីដោយខ្លួនឯង | |

## លក្ខខណ្ឌក្នុងការលេង

អ្នកលេងទាំង ២ នាក់ត្រូវអង្គុយទល់មុខគ្នា។ល្បែងនេះគឺងាយស្រួលបំផុតដោយពួកគេត្រូវសម្លឹងមើលទៅក្នុងភ្នែករបស់គូប្រកួតចំៗ ដោយមិនងាកចេញ មិនបិទភ្នែក (មិនព្រិចភ្នែក) និងមិនសើច។ អ្នកលេងណាដែលធ្វើខុសពីលក្ខខណ្ឌទាំងនេះមុននឹងត្រូវចាញ់ការប្រកួត។

អ្នកលេងអាចនិយាយរឿងកំប្លែងដាក់គ្នាបាន។ចំណែកឯអ្នកមើលជុំវិញក៏អាចសើច និយាយរឿងកំប្លែង ឬធ្វើមុខប្លែកៗដើម្បីធ្វើឱ្យអ្នកលេងទាំងពីរទប់សំណើចមិនបានផងដែរ។

## តម្លៃអប់រំ

ល្បែងនេះគឺជាលំហាត់ប្រាណដ៏ល្អមួយក្នុងការហ្វឹកហាត់គ្រប់គ្រងចិត្ត និងអារម្មណ៍របស់ខ្លួនឯង។

លោកគ្រូអ្នកគ្រូមួយចំនួនតែងតែយកល្បែងនេះមកលេងដើម្បីកំដៅសាច់ដុំមុនពេលចាប់ផ្តើមម៉ោងរៀនសម្តែង។ ព្រោះថានៅក្នុងអំឡុងពេលសម្តែងល្ខោន/រឿង វាពិតជាសំខាន់ណាស់ដែលតួសម្តែងត្រូវធ្វើឱ្យទស្សនិកជនសើច ប៉ុន្តែខ្លួនឯងត្រូវតែទប់មិនឱ្យសើចដាច់ខាត។

ល្បែងនេះក៏ជាវិធីដ៏ល្អមួយដើម្បីជួយឱ្យក្មេងៗស្ងប់ចិត្តឡើងវិញ បន្ទាប់ពីពួកគេបានលេងសកម្មភាពអ្វីមួយដែល មានការរំភើបខ្លាំង។ ក្នុងការលេងនោះ គ្រូដឹកនាំត្រូវបានណែនាំឱ្យហាមក្មេងៗក្នុងធ្វើមុខប្លែកៗ/បែបកំប្លែងដាក់គ្នាផងដែរ។

ត្រូវដឹងថា ល្បែងនេះអាចនឹងក្លាយទៅជាគួរឱ្យធុញទ្រាន់នៅពេលដែលក្មេងៗពូកែទប់អារម្មណ៍ខ្លាំង។ ទោះជាយ៉ាងណាប្រសិនបើវាឈានដល់ចំណុចនោះ វាមានន័យថាគោលបំណងនៃការអប់រំគឺទទួលបានជោគជ័យហើយ។

# ខ្សឹបជាភាសាចិន

ដោយ Stanislas Kowalski បកប្រែដោយ ហេង ធារី

| | | | |
|---|---|---|---|
| ប្រភេទនៃល្បែង៖ | ហ្គេមស្ងប់ស្ងាត់ | រយៈពេល៖ | 3 នាទី |
| គោលបំណង៖ | ភាពត្រឹមត្រូវ, ការស្តាប់ | អាយុ៖<br>លេងបានគ្រប់វ័យ | សម្ភារៈ៖<br>គ្មាន |
| មុខវិជ្ជា៖ | ភាសាបរទេស | ចំនួនអ្នកចូលរួមលេង៖<br>5-50 នាក់ | |
| លក្ខណៈពិសេស | ងាយស្រួលក្នុងការអនុវត្ត<br>ងាយស្រួលក្នុងការពន្យល់ | អាជ្ញាកណ្តាល៖<br>គ្រប់គ្រងដោយខ្លួនឯង | |

## លក្ខខណ្ឌក្នុងការលេង

ហេតុអ្វីបានជាវាត្រូវបានគេហៅថាខ្សឹបជាភាសាចិន? យើងមិនដឹងច្បាស់ទេ។ ជាភាសាបារាំង វាគឺ "le telephone arabe" ដែលសន្មតដោយមនុស្សខុសគ្នាទាំងស្រុង។

អ្នកលេងទីមួយខ្សឹបប្រយោគមួយនៅក្នុងត្រចៀករបស់អ្នកលេងទីពីរ ដែលនិយាយវាម្តងទៀតនៅក្នុងត្រចៀករបស់អ្នកលេងទីបី និងបន្តបន្ទាប់។ អ្នកលេងចុងក្រោយនៅជួរនិយាយវាឮៗ ទោះបីជាវាទំនងជាថាប្រយោគត្រូវបានផ្លាស់ប្តូរនៅក្នុងដំណើរការក៏ដោយ។ ជាចុងក្រោយ អ្នកលេងទីមួយនិយាយប្រយោគដើមឮៗសម្រាប់ការប្រៀបធៀប។

## ការកែសម្រួល

ល្បែងនេះអាចលេងបានកាន់តែមានលក្ខណៈផ្លូវការបន្តិច ដើម្បីបង្កើនតម្លៃគរុកោសល្យរបស់វានៅក្នុងបរិបទសាលារៀន។ អ្នកលេងត្រូវបានដាក់ជាក្រុមតូចៗដែលមានសមាជិក ៥ ឬ ៦ នាក់។ ប្រសិនបើខ្សែសង្វាក់វែងពេក សារចុងក្រោយច្បាស់ណាស់មិនត្រឹមត្រូវទេ។ គ្រូសរសេរប្រយោគនៅលើក្រដាសមួយសន្លឹក ហើយបង្ហាញវាទៅអ្នកលេងដំបូងនៃក្រុមនីមួយៗ។ បន្ទាប់មកក្រុមនីមួយៗបន្តដូចខាងលើ ប៉ុន្តែអ្នកលេងចុងក្រោយសរសេរប្រយោគរបស់គាត់នៅលើក្តារខៀន។ ក្រុមជាច្រើនអាចលេងក្នុងពេលតែមួយ។ ទោះបីជាវាគួរឱ្យចាប់អារម្មណ៍ក្នុងការស្តាប់ធ្វើឱ្យប្រយោគខុសក៏ដោយ ក្នុងករណីនេះ អ្នកលេងគួរតែព្យាយាមធ្វើវាឡើងវិញឱ្យបានត្រឹមត្រូវ។

## តម្លៃអប់រំ

លំហាត់នេះមានតម្លៃដ៏អស្ចារ្យនៅក្នុងភាសាបរទេស។ វាមិនតម្រូវឱ្យមានភាពច្នៃប្រឌិតទេ ប៉ុន្តែវាជាការបណ្តុះបណ្តាលដ៏ល្អនៅក្នុងជំនាញភាសាសំខាន់ៗទាំង ៤៖ ការអាន ការនិយាយ ការស្តាប់ និងការសរសេរ។

ដើម្បីទទួលបានជោគជ័យ អ្នកលេងត្រូវតែយល់ប្រយោគ និងបញ្ចេញសំឡេងវាឱ្យបានត្រឹមត្រូវ។ ល្បែងនេះក៏អាចត្រូវបានប្រើជាមួយនឹងគោលបំណងសីលធម៌ផងដែរ នៅពេលដែលអ្នកអប់រំរកឃើញតម្រូវការក្នុងការអប់រំកុមារអំពីគ្រោះថ្នាក់នៃការនិយាយដើមគេ។

# ល្បែងសិក្សាគណិតវិទ្យា

ដោយ៖ ចេង ភារី

| ប្រភេទនៃល្បែង៖ | ល្បែងសិក្សាគណិតវិទ្យា | រយៈពេល៖ | 5-12 នាទី |
|---|---|---|---|
| គោលបំណង៖ | ចងចាំរូបមន្ត និងចេះគណនាលំហាត់ | អាយុ៖<br>11-15 ឆ្នាំ | សម្ភារៈ៖<br>គ្មាន |
| មុខវិជ្ជា៖ | គណិតវិទ្យា (ថ្នាក់ទី៧ ដល់១២) | ចំនួនអ្នកចូលរួមលេង៖២ នាក់ | |
| លក្ខណៈពិសេស | ងាយស្រួលក្នុងការអនុវត្ត<br>ងាយស្រួលក្នុងការពន្យល់ | សម្ភារៈ៖ គ្រាប់ឡុកឡាក់ Board game ក្រដាស់សំណួរ ក្តារឆ្នួនសម្រាប់គិតលេខ។ | |

## ដំណើរការលេង

- ដំបូងអ្នកលេងពីរនាក់ ជ្រើសយកកូនសម្រាប់ដើរ
- បន្ទាប់មកអ្នកលេងម្នាក់ត្រូវទំលាក់គ្រាប់ឡុកឡាក់ ហើយចាប់ឆ្នោតជ្រើសយកសំណួរដើម្បីឆ្លើយ បើសិនគាត់ឆ្លើយសំណួរត្រូវគាត់អាចដើរតាមលេខដែលពួកគាត់ទទួលបាន ឧទាហរណ៍៖ (បានលេខ៩ ត្រូវដើរ៩ជំហាន) ។ បើគាត់ឆ្លើយមិនត្រូវគាត់ត្រូវស្ថិតនៅទីតាំង ដដែល។ បន្ទាប់មកទៀតប្តូរវេនទៅកាន់អ្នកលេងម្ខាងទៀត ដោយបោះគ្រាប់ឡុកឡាក់ និងឆ្លើយសំណួរ ដូចអ្នកដំបូង។
- អ្នកលេងត្រូវប្តូរវេនគ្នាលេងជាបន្តបន្ទាប់រហូតរកបានអ្នក







## លក្ខខណ្ឌនៃការឈ្នះ

- អ្នកដែលទៅដល់ទី មុនគេ ជាអ្នកឈ្នះ។
- កំឡុងពេលលេង ប្រសិនបើភាគីខាងណាមួយ ឆ្លើយខុសត្រូវប្តូរវេនឲ្យដៃគូបោះឡុកឡាក់ម្តង(មិនមានសិទ្ធដើរ) ។

**ចំណាំ៖** ដើម្បីឈ្នះលឿនត្រូវប្រើសំណាង និងឆ្លើយសំណួរឲ្យបានត្រូវទាំងអស់ ។

## តម្លៃអប់រំក្នុងល្បែង

ល្បែងនេះ ជាប្រភេទល្បែងសិក្សាគណិតវិទ្យាដែលអាច ជួយអោយសិស្សចងចាំមេរៀន ដែលធ្លាប់បានរៀន និង គិតលំហាត់លឿនជាងមុន តាមរយៈសំណួរដែលពួកគេចាប់បាន។





# គុណរហ័ស

ដោយ៖ ចេង ភារី

| | | | |
|---|---|---|---|
| ប្រភេទនៃល្បែង៖ | ល្បែងសិក្សាគណិតវិទ្យា | រយៈពេល៖ | 15-20 នាទី |
| គោលបំណង៖ | ការគណនាផលគុណ ចងចាំមេលេខ | អាយុ៖<br>9-15 ឆ្នាំ | សម្ភារៈ៖<br>គ្មាន |
| មុខវិជ្ជា៖ | គណិតវិទ្យា ថ្នាក់ទី៤ | ចំនួនអ្នកចូលរួមលេង ៖២ នាក់ | |
| លក្ខណៈពិសេស | ងាយស្រួលក្នុងការអនុវត្ត<br>ងាយស្រួលក្នុងការពន្យល់ | សម្ភារៈ៖ សន្លឹកបៀរ (ពីលេខមួយដល់លេខដប់ រួមទាំងសន្លឹករូប បីសន្លឹកតំណាងអោយលេខ 11, 12 និង 13)។ | |

## ដំណើរការលេង

អ្នកលេងទាំងពីរអង្គុយក្បែរគ្នានិងត្រៀមខ្លួនសម្រាប់ការលេង គ្រូយកសន្លឹកបៀមួយហ៊ូដែលសាប់រួច ដាក់នៅចំពីរមុខពួកគេ បន្ទាប់មកគ្រូបើកសន្លឹកបៀពីរសន្លឹកដែលនៅខាងលើគេ ដើម្បីអោយពួកគេគណនាផលគុណរវាងលេងទាំងពីរ ។ ឧទាហរណ៍៖ សន្លឹកទាំងពីរ ជាសន្លឹក៦ និង សន្លឹក៥ នោះលទ្ធផលនៃប្រមាណវិធីគុណស្មើនឹង៣០ ដូច្នេះសិស្សដែលឆ្លើយចម្លើយបានត្រឹមត្រូវមុនគេត្រូវ ទទួលបានសន្លឹកបៀនោះ។ បើសិនជាពួកគេឆ្លើយត្រូវតំណាលគ្នាសន្លឹកបៀនោះត្រូវទុកសិន ហើយពួកគេត្រូវឆ្លើយសន្លឹកបៀបន្ទាប់បើអ្នកណាឆ្លើយត្រូវ ត្រូវបានសន្លឹកបៀទាំងបួនសន្លឹក។ គ្រូបន្តបើកសន្លឹកបៀបន្តទៀតដើម្បីអោយអ្នកលេង ទាំងពីរប្រណាំងគ្នាក្នុងការគិត និងឆ្លើយ រហូតដល់អស់សន្លឹកបៀពីរហ៊ូ។ បន្ទាប់មកទៀតអ្នកលេងចាប់ផ្តើមសរុបសន្លឹកបៀដែលពួកគេទទួលបាន ដើម្បីដឹងថាពួកគេឈ្នះទៅលើដៃគូរបស់ពួកគេឬចាញ់ និងចំនួនប៉ុន្មាន។

## តម្លៃអប់រំក្នុងល្បែង

ល្បែងនោះជាប្រភេទល្បែងសិក្សាដែល អាចអោយសិស្សអនុវត្តការគុណលេខ ដើម្បីអោយពួកគេចេះស្ទាត់ទៅលើមេលេខដោយមិនចាំបាច់ត្រូវសូត្រតាមលំដាប់។វាជួយអោយសិស្សមានភាពរេផ្លិចក្នុងការឆ្លើយ ដែលអាចជួយឱ្យពួកធ្វើប្រមាណវិធីគុណ និងប្រមាណវិធីចែកបានរហ័សជាងមុន។






# ការធ្វើបរិវត្តកម្មការអប់រំមធ្យមសិក្សានៅកម្ពុជាតាមរយៈបញ្ញាសិប្បនិម្មិត៖ បញ្ហាប្រឈម និងកាលានុវត្តភាព

ដោយ៖ **ផាន់ ប៊ុនណាត**

## ១. សេចក្ដីផ្ដើម និងបរិបទនៃការស្រាវជ្រាវ

ការកើនឡើងនៃលទ្ធភាពទទួលបានឧបករណ៍អប់រំ ដែលដំណើរការដោយបញ្ញាសិប្បនិម្មិត (AI) មានសក្ដានុពលក្នុងការកែទម្រង់ការអនុវត្តការបង្រៀន និងការរៀនសូត្រយ៉ាងខ្លាំង។ ប្រព័ន្ធបញ្ញាសិប្បនិម្មិត អាចវិភាគលំនាំនៃការសិក្សារបស់សិស្ស ផ្ដល់មតិកែលម្អដែលអាចសម្របខ្លួនបាន និងជួយគ្រូបង្រៀនក្នុ ងការរចនាសម្ភារៈបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព។ សមត្ថភាពទាំងនេះបង្ហាញថា បញ្ញាសិប្បនិម្មិត (AI) អាចគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនគុណភាពអប់រំពិសេសនៅក្នុងបរិបទ ដែលគ្រូបង្រៀនប្រឈមមុខនឹងបន្ទុកការងារខ្ពស់ និង ធនធានមានកំណត់។ ទោះបីជាមានការចាប់អារម្មណ៍ជាសកល លើបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) សម្រាប់ការអប់រំក៏ដោយ ក៏ការស្រាវជ្រាវ និងការអនុវត្តភាគច្រើនត្រូវបានផ្ដោតលើប្រទេសដែលមានបច្ចេកវិទ្យាជឿនលឿន។ ផ្ទុយទៅវិញ ការស្រាវជ្រាវជាក់ស្ដែងតិចតួចបានពិនិត្យមើលពី របៀបដែលបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត(AI) អាចត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកំពុងអភិវឌ្ឍ។ បរិបទទាំងនេះច្រើនតែប្រឈមមុខ និងបញ្ហាបន្ថែមរួមទាំង ហេដ្ឋារចនាសម្ព័ន្ធឌីជីថលមានកម្រិត ការបណ្ដុះបណ្ដាលគ្រូមិនគ្រប់គ្រាន់ និងឧបសគ្គធនធាន។

ប្រទេសកម្ពុជាបង្ហាញករណីដ៏គួរឱ្យចាប់អារម្មណ៍មួយសម្រាប់ការពិនិត្យមើលសក្ដានុពលនៃបញ្ញាសិប្បនិម្មិត (AI) ក្នុងវិស័យអប់រំ។ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ ប្រទេសនេះមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានការអប់រំ និងការកែលម្អអភិបាលកិច្ចអប់រំ។ គំនិតផ្ដួចផ្ដើម កំណែទម្រង់ជាតិបានសង្កត់ធ្ងន់កាន់តែខ្លាំងឡើងលើការកែលម្អគុណភាព ការច្នៃប្រឌិត និងការរួមបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងការបង្រៀននិងរៀន។ គោលនយោបាយ ដែលមានគោលបំណងពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការកែលម្អគុណភាពជាអ្នកដឹកនាំរបស់សាលារៀន និងការលើកកម្ពស់គរុកោសល្យដែលផ្ដោតលើសិស្ស ឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់រដ្ឋាភិបាលក្នុងការធ្វើទំនើបកម្មប្រព័ន្ធអប់រំ។

ទោះជាយ៉ាងនេះក្ដី សាលារៀននៅកម្ពុជានៅតែបន្តជួបប្រទះនឹងបញ្ហាប្រឈមជាបន្តបន្ទាប់មួយចំនួន។ ការបង្រៀនបែបប្រពៃណីដែលផ្ដោតលើគ្រូនៅតែមានជាទូទៅនៅក្នុងថ្នាក់រៀនជាច្រើន ហើយឱកាសសម្រាប់ការសិក្សាបែបបុគ្គលនៅមានកម្រិត។ គ្រូបង្រៀនជារឿយៗ ជួបប្រទះនឹងការងារធ្ងន់ៗ រួមទាំងការរៀបចំកិច្ចតែងការមេរៀន ការកែកិច្ចការសិស្ស និងកិច្ចការរដ្ឋបាល។ លើសពីនេះទៀត ភាពខុសគ្នានៃធនធានអប់រំ រវាងសាលានៅទីក្រុង និងជនបទនៅតែមានសារៈសំខាន់។ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) អាចផ្ដល់ឱកាសថ្មីដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួន ក្នុងចំណោមបញ្ហាទាំងនេះ។ តាមរយៈការគាំទ្រគ្រូឱ្យរៀបចំផែនការបង្រៀន ការវាយតម្លៃដោយស្វ័យប្រវត្តិ និងឧបករណ៍សិក្សាដែលអាចសម្របខ្លួនបាន ប្រព័ន្ធបញ្ញាសិប្បនិម្មិត (AI) អាចបង្កើនប្រសិទ្ធភាពនៃការបង្រៀន ខណៈពេលដែលវាជួយកាត់បន្ថយបន្ទុកកិច្ចការរដ្ឋបាល។ លើសពីនេះថ្នាលសិក្សាដែលជំរុញដោយបញ្ញាសិប្បនិម្មិត (AI) អាចជួយសិស្សឱ្យចូលរួមកាន់តែសកម្មជាមួយនឹងសម្ភារៈសិក្សា និងទទួលបានមតិកែលម្អជាលក្ខណៈបុគ្គល។

ទោះជាយ៉ាងណាក៏ដោយ ការដាក់ឱ្យប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) នៅក្នុងប្រព័ន្ធអប់រំក៏បង្កឱ្យមានសំណួរសំខាន់ៗផងដែរ។ គ្រូបង្រៀនអាចតម្រូវឱ្យមានការបណ្តុះបណ្តាលយ៉ាងសំខាន់ដើម្បីប្រើប្រាស់ឧបករណ៍បញ្ញាសិប្បនិម្មិត (AI) ឱ្យមានប្រសិទ្ធភាព ការព្រួយបារម្ភផ្នែកក្រមសីលធម៌ទាក់ទងនឹងសុចរិតភាពនៃការសិក្សា ឯកជនភាពទិន្នន័យ និងការពឹងផ្អែករបស់សិស្សលើបច្ចេកវិទ្យា ក៏ត្រូវតែត្រូវបានដោះស្រាយផងដែរ។ លើសពីនេះ អ្នកបង្កើតនយោបាយត្រូវតែពិចារណាពីរបៀបដែលការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ស្របតាមយុទ្ធសាស្ត្រកំណែទម្រង់អប់រំកាន់តែទូលំទូលាយ។

## ២. សំណួរគន្លឹះនៃការស្រាវជ្រាវ

ដើម្បីស្វែងយល់ពីបញ្ហាទាំងនេះ ការសិក្សានេះបានសិក្សាអំពីការរួមបញ្ចូលឧបករណ៍បង្រៀននិងរៀនដែលគាំទ្រដោយបញ្ញាសិប្បនិម្មិត (AI) នៅក្នុងសាលាមធ្យមសិក្សានៅកម្ពុជាដោយប្រើវិធីសាស្ត្រស្រាវជ្រាវសកម្មភាព។ ការសិក្សានេះមានគោលបំណងបង្កើតការយល់ដឹងជាក់ស្តែង អំពីរបៀបដែលបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) នៅក្នុងសាលាមធ្យមសិក្សានៅកម្ពុជា ដោយប្រើវិធីសាស្ត្រស្រាវជ្រាវសកម្មភាព។ ការសិក្សានេះមានគោលបំណងបង្កើតការយល់ដឹងជាក់ស្តែងអំពីរបៀប ដែលបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) អាចគាំទ្រដល់ការអនុវត្តការបង្រៀន និងការរៀនសូត្ររបស់សិស្សនៅក្នុងបរិបទអប់រំកម្ពុជា។

ការសិក្សានេះត្រូវបានដឹកនាំដោយសំណួរស្រាវជ្រាវដូចខាងក្រោម៖

១. តើឧបករណ៍បញ្ញាសិប្បនិម្មិត (AI) អាចបញ្ចូលទៅក្នុងការអនុវត្តការបង្រៀន និងរៀននៅមធ្យមសិក្សានៅកម្ពុជាដោយរបៀបណា?

២. តើការសិក្សាដែលគាំទ្រដោយបញ្ញាសិប្បនិម្មិត (AI) មានឥទ្ធិពលអ្វីខ្លះលើការអនុវត្តរបស់គ្រូបង្រៀន និងការចូលរួមរបស់សិស្ស?

៣. តើអ្វីជាបញ្ហាប្រឈម និងឱកាសដែលកើតមាននៅពេលអនុវត្តបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) នៅក្នុងថ្នាក់រៀនរបស់កម្ពុជា?

តាមរយៈការពិនិត្យមើលសំណួរទាំងនេះ ការសិក្សាស្វែងរកការរួមចំណែកដល់ការស្រាវជ្រាវដែលកំពុងរីកចម្រើនលើបញ្ញាសិប្បនិម្មិត (AI) ក្នុងវិស័យអប់រំ ខណៈពេលដែលផ្តល់អនុសាសន៍ជាក់ស្តែង សម្រាប់អ្នកបង្កើតគោលនយោបាយ អ្នកអប់រំ និងអ្នកដឹកនាំសាលានៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជា។

## ៣. វិធីសាស្ត្រប្រមូលទិន្នន័យ និងរបកគំហើញ

### ៣.១ វិធីសាស្ត្រប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សា វិធីសាស្ត្រស្រាវជ្រាវនេះត្រូវបានអនុវត្តឡើង តាមរយៈការរួមបញ្ចូលរវាងទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ។ ក្នុងនោះដែរ ការប្រមូលទិន្នន័យបឋមត្រូវបានធ្វើឡើង តាមរយៈការចែកចាយកម្រងសំណួរស្ទង់មតិតាមប្រព័ន្ធអនឡាញ (Google From) ទៅកាន់លោកគ្រូ-អ្នកគ្រូបង្រៀនកម្រិតមធ្យមសិក្សាមកពីវិទ្យាល័យចំនួនបី គឺ (១) វិទ្យាល័យព្រែកលៀប (២) វិទ្យាល័យជាស៊ីមព្រែកអញ្ចាញ និង (៣) វិទ្យាល័យហ៊ុនសែនកំពង់ចាម។ ឧបករណ៍ស្រាវជ្រាវនេះត្រូវបានបង្កើតឡើងជាទម្រង់សំណួរពហុជ្រើសរើស និង សំណួរបើកសម្រាប់ពិភាក្សាពី ទស្សនៈយល់ឃើញក្នុងគោលបំណងសិក្សាពីការដាក់បញ្ចូល និងការអនុវត្តឧបករណ៍បញ្ញាសិប្បនិម្មិត (AI) ក្នុងការបង្រៀននិងរៀន ព្រមទាំងវាយតម្លៃកម្រិតឥទ្ធិពលរបស់វាក្នុងសកម្មភាពបង្រៀនប្រចាំថ្ងៃ។ ជាមួយគ្នានេះកម្រងសំណួរក៏បានប្រមូលព័ត៌មានយ៉ាងលម្អិត អំពីបទពិសោធន៍ផ្ទាល់ខ្លួន បញ្ហាប្រឈម និងកាលានុវត្តភាព (ឱកាស) របស់លោកគ្រូ-អ្នកគ្រូក្នុងការប្រើប្រាស់បច្ចេកវិទ្យា AI នេះនៅក្នុងបរិបទអប់រំជាក់ស្តែងនៅកម្ពុជា។

ការវិភាគទិន្នន័យនឹងផ្អែកលើលទ្ធផលស្វ័យប្រវត្តិរបស់កម្មវិធីស្ទង់មតិតាមប្រព័ន្ធអនឡាញ ហើយអ្នកស្រាវជ្រាវនឹងធ្វើការវិភាគលើទិន្នន័យដែលបានបកស្រាយស្រាប់ និងស្រង់យកបទពិសោធន៍ជាក់ស្តែងរបស់លោកគ្រូ អ្នកគ្រូដែលកំពុងប្រើប្រាស់ជាប្រចាំនៅក្នុងការបង្រៀនរបស់ខ្លួន។

### ៣.២ របកគំហើញ

ការសិក្សានេះបានវិភាគទិន្នន័យដែលប្រមូលបានពី គំរូគ្រូបង្រៀនចំនួន១២០នាក់ នៅតាមវិទ្យាល័យចំនួន៣ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ចាម។ គំរូនេះឆ្លុះបញ្ចាំងពីការតំណាងដែលមានតុល្យភាពនៃកម្រិតនៃការអប់រំនៅមធ្យមសិក្សា ដោយមាន ៤៩,១% នៃអ្នកចូលរួម ដែលកំពុងបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ៥០,៩% នៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ លទ្ធផលនេះផ្តល់នូវទិដ្ឋភាពទូទៅ ដ៏ទូលំទូលាយអំពីរបៀបដែលបញ្ញាសិប្បនិម្មិត (AI) កំពុងត្រូវបានប្រើប្រាស់នៅគ្រប់ដំណាក់កាលផ្សេងៗគ្នានៃការអប់រំមធ្យមសិក្សានៅកម្ពុជា។

ជាពិសេស គ្រូបង្រៀនដែលមានឯកទេសផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យា បច្ចេកវិទ្យាព័ត៌មានវិទ្យា និងគមនាគមន៍ (ICT) ត្រូវបានរកឃើញថា បានបញ្ចូលឬប្រើប្រាស់ឧបករណ៍សិប្បនិម្មិត (AI) ទៅក្នុងការអនុវត្តការបង្រៀនរបស់ពួកគាត់ ហើយទំនងជាដោយសារតែពួកគាត់ស្គាល់បច្ចេកវិទ្យា និងឧបករណ៍ឌីជីថលបានច្រើនជាងគ្រូបង្រៀនឯកទេសផ្សេងៗ។

***ក. ការដាក់បញ្ចូលឧបករណ៍បញ្ញាសិប្បនិម្មិតទៅក្នុងការអនុវត្តការបង្រៀននិងរៀន.*** ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទីមួយស្ដីពីរបៀបបញ្ចូលឧបករណ៍បញ្ញាសិប្បនិម្មិត (AI) ទៅក្នុងការបង្រៀននិងការរៀនជាក់ស្តែង ការរកឃើញនេះបានបង្ហាញពីកម្មវិធីសំខាន់ៗមួយចំនួន។ ជាក់ស្តែង ២២.៥% នៃគ្រូបង្រៀនបានរាយការណ៍អំពីការបង្រៀនប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) សម្រាប់ការរៀបចំកិច្ចតែងការមេរៀន និងការបង្កើតសម្ភារៈបង្រៀនឌីជីថល ខណៈដែល១៤.២% បានប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) ដើម្បីគាំទ្រដល់ការសិក្សាឯករាជ្យ និងការសិក្សាឯករាជ្យ និងការសិក្សាដោយខ្លួនឯងរបស់សិស្ស។ មានតែ ០.៨%ប៉ុណ្ណោះដែលបានរាយការណ៍អំពីការប្រើប្រាស់បញ្ញាសិប្បនិម្មិត (AI) សម្រាប់វាយតម្លៃសិស្សដោយស្វ័យប្រវត្តិ។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើននៃអ្នកឆ្លើយសំណួរ (៦២.៥%) បានយល់ស្របថា ការរួមបញ្ចូលវិធីសាស្ត្រទាំងអស់នេះ តំណាងឱ្យយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតក្នុង ការរួមបញ្ចូលបញ្ញាសិប្បនិម្មិត (AI) នៅក្នុងការអប់រំមធ្យមសិក្សា។ លទ្ធផលទាំងនេះបានបង្ហាញពី វិធីសាស្ត្រលេចធ្លោចំនួនបួននៃការរួមបញ្ចូលបញ្ញាសិប្បនិម្មិត (AI) ដូចជា៖ ការជួយរៀបចំកិច្ចតែងការ ការគាំទ្រដល់ការស្រាវជ្រាវរបស់សិស្ស ការបង្កើតសម្ភារៈសិក្សាដែលមានភាពទាក់ទាញ ការផ្តល់ការវាយតម្លៃ និងព័ត៌មានត្រឡប់។ ជាមួយគ្នានេះ វិធីសាស្ត្រទាំងនេះបង្ហាញថា បញ្ញាសិប្បនិម្មិត (AI) អាចបង្កើនទាំងប្រសិទ្ធភាពនៃការបង្រៀន និង គុណភាពនៃការរៀនរបស់សិស្ស។

***ខ. ឥទ្ធិពលនៃការសិក្សាដែលគាំទ្រដោយបញ្ញាសិប្បនិម្មិត (AI) ទៅលើការអនុវត្តរបស់គ្រូបង្រៀននិងការចូលរួមរបស់សិស្ស.*** របកគំហើញដែលបានមកពីសំណួរស្រាវជ្រាវទី២ បានពង្រឹងបន្ថែមនូវឥទ្ធិពលវិជ្ជមាន របស់បញ្ញាសិប្បនិម្មិត (AI) លើការអប់រំ។ គ្រូបង្រៀនភាគច្រើន (៩៥,៨%) បានរាយការណ៍ថា បញ្ញាសិប្បនិម្មិត (AI) ជួយបង្កើនប្រសិទ្ធភាពនៃការបង្រៀន និងជំរុញការចូលរួមរបស់សិស្សយ៉ាងសកម្ម។ ចំណុចនេះបង្ហាញថា បញ្ញាសិប្បនិម្មិត (AI) មិនត្រឹមតែគាំទ្រគ្រូ ក្នុងការផ្តល់ខ្លឹមសារមេរៀនឱ្យកាន់តែមានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកទឹកចិត្តសិស្សឱ្យចូលរួមកាន់តែសកម្មក្នុងការសិក្សាផងដែរ។ ផ្ទុយទៅវិញអ្នកឆ្លើយតបចំនួន ៣% មិនបានរាយការណ៍ពីផលប៉ះពាល់ឱ្យកត់សម្គាល់នោះទេ ហើយសមាមាត្រតូចមួយ(១,២%) បានបង្ហាញការព្រួយបារម្ភថា បញ្ញាសិប្បនិម្មិត (AI) អាចនឹងជំនួសគ្រូបង្រៀននាពេលអនាគត។

ចំណេះដឹងបន្ថែមទៀត ត្រូវបានដកស្រង់ចេញពីបទពិសោធន៍ជាក់ស្តែង ដែលបានចែករំលែកដោយលោកគ្រូ អ្នកគ្រូ។ ជាក់ស្តែង គ្រូបង្រៀនភាសាអង់គ្លេសម្នាក់មកពីវិទ្យាល័យព្រែកលៀប នៃកម្មវិធីសាលារៀនជំនាន់ថ្មី បានរាយការណ៍ទៀងទាត់ថា បានប្រើប្រាស់ឧបករណ៍ AI ដើម្បីរៀបចំផែនការមេរៀន បង្កើតលំហាត់ និងអភិវឌ្ឍសម្ភារៈ បង្រៀន។ លោកគ្រូអ្នកគ្រូ ក៏បានលើកទឹកចិត្តសិស្សឱ្យប្រើប្រាស់ថ្នាលដូចជា Perplexity និង Gemini ដើម្បីកែលម្អវេយ្យាករណ៍ ពង្រីកវាក្យសព្ទ និងកែលម្អបំណិនសរសេរ។ លើសពីនេះ សិស្សទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់ AI សម្រាប់ការស្រាវជ្រាវ និងការសិក្សាផ្អែកលើគម្រោង ដែលលើកកម្ពស់ការសិក្សាដោយខ្លួនឯង និងអក្ខរកម្មឌីជីថល។ លោកគ្រូអ្នកគ្រូ ផ្សេងទៀតបានបញ្ជាក់ថា AI គឺជាជំនួយការដ៏មានតម្លៃក្នុងការរៀបចំសកម្មភាពអន្តរកម្ម រៀបចំការវាយតម្លៃកម្រិតខ្ពស់ដែលស្របតាមស្តង់ដារអន្តរជាតិដូចជា PISA និងការគាំទ្រការអង្កេត និងពិសោធន៍វិទ្យាសាស្ត្រ។

លើសពីនេះទៅទៀត ការរួមបញ្ចូលគ្នានៃបញ្ញាសិប្បនិម្មិត (AI) បានផ្លាស់ប្តូរឥរិយាបថនៃការបង្រៀន និងការចូលរួមរបស់សិស្សយ៉ាងខ្លាំង។ គ្រូបង្រៀនកំពុងផ្លាស់ប្តូរពីអ្នកផ្តល់




ចំណេះដឹងបែបប្រពៃណី ទៅជាអ្នកសម្របសម្រួលការរៀនសូត្រ។ បញ្ញាសិប្បនិម្មិត (AI) កាត់បន្ថយបន្ទុកការងារដដែលៗ

ដូចជាការរៀបចំកិច្ចតែងការមេរៀន និងការរៀបចំការវាយតម្លៃ ដែលអនុញ្ញាតឱ្យគ្រូបង្រៀនផ្តោតលើការគាំទ្រសិស្សជាលក្ខណៈបុគ្គល។ វាក៏អនុញ្ញាតឱ្យមានការសិក្សាបែបបុគ្គលផងដែរ ដោយសម្របខ្លឹមសារមេរៀនដើម្បីបំពេញតម្រូវការផ្សេងៗរបស់សិស្ស។ ក្នុងពេលជាមួយគ្នានេះ សិស្សបានក្លាយជាអ្នកចូលរួមសកម្មក្នុងដំណើរការសិក្សា។ ជាមួយនឹងការទទួលបានឧបករណ៍បញ្ញាសិប្បនិម្មិត (AI) សិស្សបានបង្ហាញពីទំនុកចិត្ត ការចង់ដឹងចង់ឃើញ និងឯករាជ្យភាពកាន់តែច្រើន ដែលរួមចំណែកដល់បរិស្ថានថ្នាក់រៀនដែលមានថាមវន្ត និងអន្តរកម្មកាន់តែច្រើន។

***គ បញ្ហាប្រឈម និងឱកាសដែលកើតឡើងនៅពេលអនុវត្តបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) នៅក្នុងថ្នាក់រៀនរបស់កម្ពុជា***




ទោះបីជាមានការវិវឌ្ឍជាវិជ្ជមានទាំងនេះក៏ដោយ ការរកឃើញនេះក៏បានបង្ហាញពី បញ្ហាប្រឈមមួយចំនួនក្នុងការធ្វើសម្រាហរណកម្ម AI ទៅក្នុងសាលារៀននៅកម្ពុជា។ ប្រហែល ៨០% នៃគ្រូបង្រៀនបានរាយការណ៍ថា ហេដ្ឋារចនាសម្ព័ន្ធឌីជីថល អក្ខរកម្ម ICT និង AI នៅមានកម្រិត ឬមិនគ្រប់គ្រាន់នៅជាឧបសគ្គចម្បងក្នុងការបញ្ចូល AI នៅក្នុងការបង្រៀន។ លើសពីនេះ ១២.៥% បានរាយការណ៍ថាសេវាអ៊ីនធឺណិតមិនស្ថិតស្ថេរជាឧបសគ្គសំខាន់ ជាពិសេសនៅតាមទីជនបទ។ ការព្រួយបារម្ភក៏ត្រូវបានលើកឡើងអំពីភាពជឿជាក់នៃព័ត៌មានដែលបង្កើតឡើងដោយ AI និងការប្រើប្រាស់ AI របស់សិស្សសម្រាប់ការបំពេញកិច្ចការផ្ទះដោយគ្មានការយល់ដឹងពិតប្រាកដ។







ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមទាំងនេះក៏មានឱកាសសំខាន់ៗផងដែរ។ បញ្ញាសិប្បនិម្មិត (AI) គឺមានសក្តានុពលក្នុងការបង្កើនប្រសិទ្ធភាពគ្រូបង្រៀនលើកកម្ពស់ស្វ័យសិក្សារបស់សិស្សនិងកែលម្អគុណភាពអប់រំ និងសមធម៌នៃការអប់រំទាំងមូល។ តាមរយៈការពង្រីកលទ្ធភាពទទួលបានធនធានសិក្សា និងស្របតាមនិន្នាការបច្ចេកវិទ្យាសកលបញ្ញាសិប្បនិម្មិត (AI) អាចជួយរៀបចំសិស្សសម្រាប់បរិយាកាសសិក្សា និងវិជ្ជាជីវៈអន្តរជាតិ។ ជារួម ការរកឃើញបានបង្ហាញថា ខណៈពេលដែលបញ្ហាប្រឈមនៅតែមានការធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពនៃបញ្ញាសិប្បនិម្មិត (AI) នៅក្នុងការអប់រំមធ្យមសិក្សានៅកម្ពុជាអាចផ្លាស់ប្តូរដំណើរការបង្រៀន និងរៀនដែលធ្វើឱ្យពួកគេកាន់តែមានភាពទាក់ទាញប្រកបដោយភាពច្នៃប្រឌិត និងការផ្តោតលើសិស្ស។

## ៤. ការពិភាក្សា និងអនុសាសន៍សម្រាប់កម្រិតគោលនយោបាយ

ការរកឃើញនេះបានបង្ហាញថា បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) មានសក្តានុពលក្នុងការលើកកម្ពស់ការអនុវត្តការបង្រៀន និងរៀននៅក្នុងសាលារៀនកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តជោគជ័យតម្រូវឱ្យមានប្រព័ន្ធគាំទ្រគ្រូខ្លាំង និងស្របតាមគំនិតផ្តួចផ្តើមកំណែទម្រង់អប់រំកាន់តែទូលំទូលាយ។

ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបញ្ញាសិប្បនិម្មិត (AI) ក្នុងវិស័យអប់រំ អ្នកបង្កើតគោលនយោបាយគួរតែពិចារណាបង្កើតយុទ្ធសាស្រ្តជាតិសម្រាប់សមាហរណកម្មបញ្ញាសិប្បនិម្មិត ដែលរួមមានការបណ្តុះបណ្តាលគ្រូ ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងគោលការណ៍ណែនាំប្រកបដោយក្រមសីលធម៌។

## មន្ទីរពិសោធន៍វិទ្យាសាស្ត្រ

# “ការពិសោធន៍ដ៏ត្រឹមត្រូវ”

ដោយ៖ Stanislas Kowalski   បកប្រែដោយ៖ អ៊ាង ចិត្រា

យើងមិនមែនធ្វើពិសោធន៍ក្នុងថ្នាក់រៀនរូបវិទ្យាដោយគ្រាន់តែដើម្បីភាពសប្បាយរីករាយនោះទេ។ មូលហេតុពិតប្រាកដគឺមានភាពស៊ីជម្រៅជាងនេះទៅទៀត យើងធ្វើការពិសោធន៍ពីព្រោះ វាគឺជាមូលដ្ឋានគ្រឹះនៃការផ្ទៀងផ្ទាត់តាមបែបវិទ្យាសាស្ត្រ។ ចំណែកឯភាពសប្បាយរីករាយវិញ គ្រាន់តែជាមូលហេតុបន្ទាប់បន្សំតែប៉ុណ្ណោះ។ អ្នកអប់រំបែបស្ថាបនានិយម នឹងប្រាប់អ្នកថា ការពិសោធន៍ធ្វើឱ្យសិស្សមានការចូលរួមចំណែកកាន់តែសកម្មក្នុងការរៀនសូត្រ។ វាគឺត្រឹមត្រូវ ប៉ុន្តែគ្រាន់តែជាផ្នែកឬមូលហេតុតូចមួយប៉ុណ្ណោះ ហើយមូលហេតុចម្បងនោះគឺទាក់ទងនឹង ញាណវិទ្យា (Epistemology)។ យើងគួរតែដឹងថា តើចំណេះដឹងរបស់យើងមានប្រភពមកពីណា។ ខុសពីប្រព័ន្ធបញ្ញា ឬទស្សនវិជ្ជាពីមុនៗ វិទ្យាសាស្ត្រគឺជាប្រភេទចំណេះដឹងដែលត្រូវបានកំណត់ដោយវិធីសាស្ត្រផ្ទៀងផ្ទាត់ឬបញ្ជាក់ជាប្រព័ន្ធ។ យើងមិនមានពេលគ្រប់គ្រាន់ដើម្បីស្វែងយល់ពី សមាសភាគទាំងអស់នៃវិធីសាស្ត្រវិទ្យាសាស្ត្រនោះទេ។ ញាណវិទ្យា (Epistemology) គឺជាផ្នែកមួយនៃទស្សនវិជ្ជាដែលសិក្សាពីអ្វីដែលជាចំណេះដឹង និងរបៀបដែលយើងអាចបង្កើតចំណេះដឹងថ្មី ដែលវាជាប្រធានបទដ៏ស្មុគស្មាញមួយ។ មានសៀវភៅរាប់ពាន់ក្បាលត្រូវបានគេសរសេរឡើង ដែលគ្រូបង្រៀន គួរតែអានវាឱ្យបានមួយ ឬពីរក្បាល។ ការធ្វើការពិសោធន៍ក្នុងមេរៀនរូបវិទ្យា ឬគីមីវិទ្យា មិនមែនដើម្បីធ្វើឱ្យមេរៀននោះកាន់តែគួរឱ្យចង់រៀន ឬងាយស្រួលយល់តែប៉ុណ្ណោះទេ វាគឺជាការបញ្ជាក់នូវរាល់ការអះអាងដែលយើងបានលើកឡើង។ អ្នកគ្រាន់តែបង្រៀនអំពីច្បាប់នៃចលនា ហើយប្រាប់សិស្សឱ្យជឿតាម ឬអ្នកអាចបញ្ជាក់ច្បាប់ទាំងនោះតាមរយៈការពិសោធន៍។ វាជារឿងគួរឱ្យសោកស្តាយដែលគ្រូបង្រៀនមួយចំនួន មិនអាចសូម្បីតែបង្ហាញភស្តុតាងថាផែនដីមានរាងមូល។ តាំងពីសតវត្សទី៤មុនគ្រិស្តសករាជមកម្ល៉េះ ទស្សនវិទូ អារីស្តូត (Aristotle) បានបង្ហាញភស្តុតាងយ៉ាងច្បាស់ថាផែនដីមានរាងមូល តាមរយៈការសង្កេតជាក់ស្តែង។

ឧទាហរណ៍៖ លោកបានកត់សម្គាល់ឃើញថា ស្រមោលរបស់ផែនដីដែលចាំងលើព្រះច័ន្ទនៅពេលមានចន្ទគ្រាស គឺមានរាងកោង។ មួយវិញទៀត នៅពេលមានកប៉ាល់បើកនៅទីឆ្ងាយ យើងតែងតែមើលឃើញដងក្ដោងរបស់វាមុនគេ មុននឹងឃើញតួ កប៉ាល់ទាំងមូលលេចឡើងផុតពីជើងមេឃ។ នៅប្រហែលឆ្នាំ ២៤០ នៅមុនគ្រិស្តសករាជ លោក អេរ៉ាតូស្តែន (Eratosthenes) បានគណនារង្វង់បរិមាត្រផែនដីបានយ៉ាងជោគជ័យ។ លោកធ្វើបែបនេះបាន តាមរយៈការវាស់មុំពន្លឺព្រះអាទិត្យនៅទីក្រុងពីរផ្សេងគ្នា (ដែលស្ថិតនៅលើខ្សែបណ្តោយផែនដីតែមួយ) ក្នុងអំឡុងថ្ងៃដែលវែងជាងគេប្រចាំឆ្នាំ។ កិច្ចការដែលពិបាកបំផុតនៅពេលនោះ គឺការវាស់ចម្ងាយរវាងទីក្រុងទាំងពីរ ចំណែកឯការគណនាបន្ទាប់មកទៀត គឺគ្រាន់តែប្រើប្រាស់រូបមន្តធរណីមាត្រធម្មតាប៉ុណ្ណោះ។ ផ្អែកលើប្រវត្តិសាស្ត្រនេះ យើងអាចទាញការសន្និដ្ឋានផ្នែកអប់រំបានថា៖ គ្រូបង្រៀនដែលបង្គាប់ឱ្យសិស្សជឿ ឬធ្វើតាមដោយងងឹតងងុល គឺមិនអាចផ្តល់ឥទ្ធិពលជ្រាលជ្រៅដល់សិស្សបានឡើយ បើប្រៀបធៀបនឹងគ្រូបង្រៀនដែលចេះពន្យល់បកស្រាយ និងបង្ហាញពីប្រភពជាក់លាក់នៃចំណេះដឹង។

តាមការពិត នៅតាមសាលារៀន យើងកម្រនឹងធ្វើពិសោធន៍ដូចដែលអ្នករូបវិទូធ្វើណាស់។ ដោយយើងធ្វើ "ការបង្ហាញ" ជំនួសវិញ។ ការធ្វើបែបនេះគឺល្អសម្រាប់ពេលបច្ចុប្បន្ន ប៉ុន្តែការបែងចែកឱ្យដាច់ គឺមានសារៈសំខាន់ណាស់។ អ្នកស្រាវជ្រាវមិនដឹងថានឹងមានអ្វីកើតឡើងនោះទេ ជាធម្មតាការបង្ហាញនៅក្នុងបន្ទប់ពិសោធន៍ នៃសាលាមធ្យមសិក្សាត្រូវបានកំណត់ទុកជាមុន ហើយគ្រប់យ៉ាងប្រព្រឹត្តទៅតាមផែនការ។ នៅពេលដែលការពិសោធន៍របស់អ្នកស្រាវជ្រាវបរាជ័យ គាត់ត្រូវតែពិនិត្យឡើងវិញនូវទ្រឹស្តីរបស់គាត់។ ហើយនៅពេលដែលការបង្ហាញរបស់គ្រូបង្រៀនបរាជ័យ យើងនឹងមិនពិនិត្យទ្រឹស្តីឡើងវិញទេ។ ជាធម្មតា យើងសន្មតថាគាត់គ្រាន់តែធ្វើឱ្យមានកំហុសមួយចំនួនក្នុងការរៀបចំតែប៉ុណ្ណោះ។

ហើយគាត់មិនបានតាំងខ្លួនថា ជាអ្នកផ្លាស់ប្តូរវិទ្យាសាស្ត្រនោះទេ ពីព្រោះការបង្ហាញរបស់គាត់ត្រូវបានអ្នកវិទ្យាសាស្ត្រជាច្រើនធ្វើឡើងវិញរាប់មិនអស់ ដែលពួកគេនោះជាមនុស្សដែលមានចំណេះដឹង និងជំនាញខ្លាំងជាងខ្លួនគាត់ជាគ្រូបង្រៀន ហើយវាមិនទំនងទាល់តែសោះដែលថាគ្រូបង្រៀនម្នាក់ពិតជាបានរកឃើញអ្វី ដែលថ្មីលើសពីសមត្ថភាពអ្នកវិទ្យាសាស្ត្រ។

គ្រូបង្រៀនមិនត្រូវរំពឹងខ្ពស់ពេកថា សិស្សវិទ្យាល័យនឹងអាចដើរតាមគន្លងរបស់អ្នកវិទ្យាសាស្ត្របានយ៉ាងល្អឥតខ្ចោះនោះទេ ហើយការទាមទារឱ្យសិស្សក្លាយជាអ្នកស្រាវជ្រាវអាជីពក៏ជាចំណុចដែលត្រូវពិចារណាឱ្យបានដិតដល់ផងដែរ។

ទាក់ទងនឹងបញ្ហានេះ លោក Philippe Meirieu ដែលជាអ្នកទ្រឹស្តីអប់រំដ៏ល្បីល្បាញម្នាក់ បានលើកឡើងជាឧទាហរណ៍ថា សិស្សថ្នាក់ទី១ គួរតែរៀនអានតាមរបៀបដែលលោក Champollion បកស្រាយអក្សររូបភាពអេស៊ីប (Hieroglyphs) ប៉ុន្តែការប្រៀបធៀបនេះហាក់មើលរំលងនូវភាពខុសប្លែកគ្នាជាមូលដ្ឋានរវាងកុមារ និងអ្នកប្រាជ្ញ។ ជាក់ស្តែង លោក Champollion គឺជាអ្នកជំនាញភាសាបុរាណដ៏ឆ្នើមម្នាក់ក្នុងសម័យកាលរបស់លោក ដែលបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវយ៉ាងតឹងរ៉ឹងបំផុត រួមជាមួយជំនួយពីផ្ទាំងថ្ម Rosetta ដើម្បីដោះស្រាយបញ្ហាដែលអ្នកដទៃបានបរាជ័យអស់រយៈពេលជាង ២០ឆ្នាំ ខណៈដែលសិស្សានុសិស្សគ្រាន់តែជាអ្នកចាប់ផ្តើមដំបូង ដែលត្រូវការការតម្រង់ទិសឱ្យសមស្របទៅតាមកម្រិតបញ្ញា និងបទពិសោធន៍ជាក់ស្តែងរបស់ពួកគេតែប៉ុណ្ណោះ។

គោលបំណងពិតប្រាកដនៃកិច្ចការអប់រំ គឺការជួយឱ្យសិស្សចំណេញពេលវេលា ដោយមិនចាំបាច់ទៅសាកល្បងខុសត្រូវ ឬឆ្លងកាត់មហន្តរាយដូចក្នុងប្រវត្តិសាស្ត្រវិទ្យាសាស្ត្រឡើងវិញនោះទេ។ ការបង្ខំឱ្យសិស្សដើរតាមលំអានប្រវត្តិសាស្ត្រទាំងស្រុង គឺជាការខ្ជះខ្ជាយថាមពល ប្រៀបដូចជាការប្រើកាំបិតភ្នោតទៅកាប់ឆ្ការផ្លូវថ្មី ទាំងដែលមានផ្លូវថ្នល់ស្រាប់ដូច្នោះដែរ។ ផ្ទុយទៅវិញ យើងគួរប្រើប្រាស់ចំណេះដឹងដែលមានស្រាប់ដើម្បីទៅឱ្យបានឆ្ងាយជាងមុន។ បើទោះជាយើងមិនអាចធ្វើពិសោធន៍ធំៗ (ដូចជាម៉ាស៊ីនបំណែកភាគល្អិត) នៅតាមសាលារៀនបានក៏ដោយ ប៉ុន្តែការបង្ហាញមេរៀនដ៏ល្អមួយ អាចជួយឱ្យសិស្សយល់ច្បាស់ពីគោលគំនិតវិទ្យាសាស្ត្រ និងរំលឹកពួកគេថា រាល់ទ្រឹស្តីទាំងអស់សុទ្ធតែត្រូវឆ្លងកាត់ការសាកល្បង ហើយអាចនឹងមានកំហុស។ ក្នុងករណីដែលមិនអាចអនុវត្តផ្ទាល់ យើងត្រូវប្រើការពិពណ៌នា និងការរៀនសូត្រពីប្រវត្តិសាស្ត្រ ដើម្បីទុកជាបទពិសោធន៍ និងជាមូលដ្ឋានគ្រឹះសម្រាប់អ្នក ជំនាន់ក្រោយត្រិះរិះ។ ផ្នត់គំនិតរបស់សិស្ស គ្រូបង្រៀន និងអ្នកស្រាវជ្រាវគឺខុសគ្នាខ្លាំងណាស់។ ការពិសោធន៍នៅវិទ្យាល័យគឺចាំបាច់ក្នុងការរៀបចំផ្នត់គំនិតរបស់សិស្ស សម្រាប់ការពង្រឹងផ្នែកបញ្ញាកម្រិតខ្ពស់។ សិស្សមានផ្នត់គំនិតជាក់លាក់ ដែលសមស្របទៅនឹងអ្វីដែលយើងរំពឹងពីពួកគេ។ ហើយពួកគេព្យាយាមរៀនដោយយកចិត្តទុកដាក់ ចងចាំអ្វីដែលគេបានរៀន និងជៀសវាងការមានកំហុស។ សិស្សមានអារម្មណ៍មិនល្អនៅពេលដែលអ្វីៗមិនប្រព្រឹត្តទៅដូចការរំពឹងទុក។

ប្រសិនបើមានការបង្ហាញណាមួយបរាជ័យ សិស្សមានអារម្មណ៍ថាពួកគេមានភាពមិនច្បាស់លាស់ និងមានប្រតិកម្មហាក់ដូចជាពួកគេបានធ្វើអ្វីមួយខុស ហើយនៅពេលដែលពួកគេមិនយល់ពីវា ពួកគេខ្លាចបានពិន្ទុមិនល្អ។ ការក្លាយជាគ្រូបង្រៀន តម្រូវឱ្យមានការផ្លាស់ប្តូរឥរិយាបថពីអ្នកដើរតាមដែលស្តាប់បង្គាប់ មកជាអ្នកដឹកនាំវិញ។ សម្រាប់អ្នកខ្លះ វាទាមទារឱ្យមានការលះបង់ចោលនូវឥរិយាបថអកម្ម ដើម្បីចាប់ផ្តើមមានគំនិតផ្តួចផ្តើម។

ការក្លាយជាអ្នកស្រាវជ្រាវ តម្រូវឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតមួយផ្សេងទៀត។ វាគឺជាការផ្លាស់ប្តូរដ៏ធំមួយនៅក្នុងគំរូ (paradigm)។ អ្នកស្រាវជ្រាវដ៏ល្អម្នាក់ត្រូវស្វែងយល់ពីអ្វីដែលមិនទាន់ស្គាល់។ គ្រូបង្រៀនចូលចិត្តចែករំលែកចំណេះដឹងដែលមុតមាំដែលមិនអាចប្រកែកបាន និងមិនមានភាពមន្ទិលសង្ស័យឡើយ។ ផ្ទុយទៅវិញ អ្នកស្រាវជ្រាវត្រេកអរនៅពេលដែលគាត់មិនដឹងអ្វីមួយ ពីព្រោះគាត់បានរកឃើញថាគាត់ត្រូវស្វែងយល់បន្ថែមពីវា។ គាត់ទទួលយកមន្ទិលសង្ស័យ នៅពេលដែលការពិសោធន៍បរាជ័យ គាត់អាចអបអរសាទរពីព្រោះគាត់កំពុងរៀនអ្វីមួយ។ រឿងនេះក៏ត្រឹមត្រូវផងដែរសម្រាប់វិស្វករលោក Elon Musk ដែលបានបាត់បង់រ៉ុក្កែត (rockets) ដ៏មានតម្លៃជាច្រើន។ ប៉ុន្តែនោះគឺជាផ្នែកនៃផែនការ ដែលការផ្ទុះរ៉ុក្កែត នីមួយៗគឺជាឱកាសសម្រាប់សិក្សាពីវា។ ការផ្ទុះរ៉ុក្កែត ដែលមានតម្លៃរាប់សិបលានដុល្លារ នៅតែជាឱកាសមួយ ពីព្រោះក្រុមការងាររបស់គាត់ត្រៀមខ្លួនរួចជាស្រេចដើម្បីប្រមូលទិន្នន័យយ៉ាងច្រើន។ ខ្ញុំចូលចិត្តគំនិតនៃការបំផុសដើម្បីការរៀនសូត្រ ដោយគ្មានការស្លន់ស្លោឡើយ នៅពេលដែលមានអ្វីដែលមិននឹកស្មានដល់កើតឡើង គឺមានតែការចង់ដឹងចង់ឃើញប៉ុណ្ណោះ។ ការផ្លាស់ប្តូរផ្នត់គំនិតនោះ មិនមែនកើតឡើងត្រឹមតែមួយយប់នោះទេ។ គ្រូបង្រៀនវាយតម្លៃសិស្សរបស់ពួកគេក្រោមពន្លឺ

នៃអ្វីដែលកាត់ជឿថាជាការពិត។ គ្រូមួយចំនួនមានការលំបាកយ៉ាងខ្លាំង នៅពេលដែលត្រូវសរសេរសារណាស្រាវជ្រាវ។ គ្រូធ្លាប់តែសួរសំណួរប្រឡង ដែលពួកគេដឹងចម្លើយរួចជាស្រេច ហើយពួកគាត់បានភ្លេចពីរបៀបសួរសំណួរធម្មតាដើម្បីរៀនពីអ្វីដែលពួកគាត់មិនដឹង។ គ្រូបង្រៀនមួយចំនួនបង្កើតកម្រងសំណួរស្ទង់មតិមិនសូវបានល្អឡើយ ដែលសំណួរទាំងនោះពេញទៅដោយសំណួរបង្កប់ន័យបង្ខំឱ្យឆ្លើយ (loaded questions)។ ការគិតបែបត្រិះរិះ (Critical thinking) តម្រូវឱ្យមានមន្ទិលសង្ស័យលើការសន្មត់របស់ខ្លួនឯង មិនមែនព្យាយាមបញ្ជាក់តែជំនឿរបស់ខ្លួនឯងនោះទេ។

ភាពចៃដន្យ ឬការរកឃើញចំណេះដឹងថ្មីដោយចៃដន្យដែលមិនបានរំពឹងទុក វាមិនមែនកើតឡើងដោយសារតែសំណាងសុទ្ធសាធនោះទេ។ ឧទាហរណ៍ជាក់ស្តែងរបស់លោក Fleming និងថ្នាំប៉េនីស៊ីលីន (penicillium) គឺគួរឱ្យចាប់អារម្មណ៍ណាស់។ លោក Fleming មិនមែនគ្រាន់តែភ្លេចចានអាហារមេរោគ (petri dish) នៅលើតុនោះទេ។ លោកមានសមត្ថភាពក្នុងការបកស្រាយព្រឹត្តិការណ៍នោះ។ មនុស្សផ្សេងទៀត ប្រហែលជាបោះចោលគំរូនោះបាត់ទៅហើយ។ ប៉ុន្តែលោក Fleming មិនធ្វើដូច្នោះទេ គឺលោកបានព្យាយាមស្វែងយល់អំពីវា ហើយបន្ទាប់មក វាបានចំណាយពេលជាង ១៥ឆ្នាំនៃការងារយ៉ាងលំបាក ដើម្បីបំប្លែងការរកឃើញរបស់លោក ឱ្យទៅជាឱសថដែលអាចប្រើប្រាស់បាន។ គម្រោងនេះបានធ្វើឱ្យមន្ទីរពិសោធន៍ជាច្រើនប្រកួតប្រជែងគ្នា ទាំងនៅក្នុងសហរដ្ឋអាមេរិក អង់គ្លេស ជប៉ុន អូស្ត្រាលី អាល្លឺម៉ង់ និងប្រទេសផ្សេងៗទៀត។ អ្នកគិតដ៏ពូកែៗរាប់ពាន់នាក់នៅក្នុងពិភពលោក បានចូលរួមមុនពេលពួកគេអាចញែក និងផលិតថ្នាំនោះជាលក្ខណៈឧស្សាហកម្មបាន។ វាគឺជាការស្រាវជ្រាវដ៏សំខាន់បំផុតរបស់សហរដ្ឋអាមេរិកក្នុងអំឡុងសង្គ្រាមលោកលើកទី២ បន្ទាប់ពីគម្រោង Manhattan (គ្រាប់បែកបរមាណូ)។ ភាពចៃដន្យកើតឡើងចំពោះតែចិត្តគំនិតដែលបានត្រៀមខ្លួនរួចរាល់ប៉ុណ្ណោះ។

ការបង្ហាញដែលយើងធ្វើនៅសាលា ប្រហែលជាមិនអាចឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងផ្នែកបញ្ញាទាំងអស់របស់អ្នកស្រាវជ្រាវពិតប្រាកដនោះទេ។ ប៉ុន្តែវានៅតែរៀបចំចិត្តគំនិតរបស់សិស្សសម្រាប់ការផ្លាស់ប្តូរដ៏ធំទៅកាន់ពិភពដែលមិនទាន់ស្គាល់ ដែលនឹងកើតឡើងប្រហែលជាក្នុងរយៈពេលច្រើនឆ្នាំទៀតប្រហែលជានៅថ្នាក់អនុបណ្ឌិត ឬប្រហែលជាយូរជាងនេះ នៅពេលដែលពួកគេក្លាយជាអ្នកសិក្សាដែលមានឯករាជ្យពេញលេញម្នាក់។

# “ការស្វែងរកឧទាហរណ៍នៃការពិសោធន៍”

**ដោយ៖ Stanislas Kowalski**
**បកប្រែដោយ៖ អ៊ឹម លាងស៊ឹម**

ការធ្វើពិសោធន៍នៅក្នុងថ្នាក់រៀនអាចជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន។ ទោះបីជាមានការរៀបរាប់អំពីការពិសោធខ្លះៗនៅក្នុងសៀវភៅសិក្សាគោលក៏ដោយ ប៉ុន្តែជារឿយៗការពន្យល់ និងផ្តល់ព័ត៌មានលម្អិតនៅមានកម្រិតនៅឡើយ។ បន្ថែមពីនេះគ្រូបង្រៀនអាចនឹងខ្វះខាតសម្ភារៈសម្រាប់ធ្វើការបង្ហាញការពិសោធឱ្យបានត្រឹមត្រូវ ឬខ្វះថវិកាសម្រាប់ទិញសារធាតុគីមីសំខាន់ៗផងដែរ។ ទោះជាយ៉ាងណាក៏ដោយ វីដេអូដែលអាចរកបាននៅលើអ៊ីនធឺណិត អាចជួយបំពេញចន្លោះខ្វះខាតនេះបានក្នុងកម្រិតដែរ។ នៅក្នុងអត្ថបទនេះ យើងនឹងពិនិត្យមើលឆាណែលដ៏ល្អមួយចំនួនដែលបង្ហាញពីវិធីសាស្ត្រវិទ្យាសាស្ត្រដ៏ត្រឹមត្រូវ ។ អត្ថបទនេះនឹងផ្តោតតែទៅលើឆាណែលដែលបង្ហាញពីការពិសោធន៍ប៉ុណ្ណោះដោយមិនរាប់បញ្ចូលនូវប្រភពធនធានដ៏មានតម្លៃជាច្រើនទៀតដែលគ្រាន់តែនិយាយអំពីវិទ្យាសាស្ត្រ។

វិធីល្អបំផុតក្នុងការស្វែងយល់ពីឆានែលទាំងនេះគឺ ការមើលកម្សាន្តនៅអំឡុងពេលវិស្សមកាលរបស់អ្នក ហើយរក្សាទុកវីដេអូណាដែលអាចមានប្រយោជន៍សម្រាប់ការបង្រៀនរបស់អ្នក។ ប្រសិនបើអ្នកស្វែងរកការពិសោធន៍ជាក់លាក់ណាមួយសម្រាប់មេរៀនបន្ទាប់របស់អ្នក វាអាចជាបញ្ហា ដែលអ្នកនឹងមិនអាចរកវាឃើញទាន់ពេល ហើយមេរៀនរបស់អ្នកនឹងមិនអាចរៀបចំបានល្អនោះទេ។ ដូច្នេះគួររៀបចំបណ្ណុំវីដេអូផ្ទាល់ខ្លួនរបស់អ្នកទុកជាមុន ដើម្បីអ្នកអាចយកអ្វីដែលអ្នកត្រូវការនៅពេលដែលអ្នកត្រូវការវា។ ជាធម្មតា ឆាណែលទាំងនោះត្រូវបានបង្កើតឡើងយ៉ាងល្អ និងមិនអាចលុបចោលនាពេលអនាគតដ៏ខ្លីនោះទេ។ ប៉ុន្តែត្រូវប្រុងប្រយ័ត្នថាបញ្ហាតំណភ្ជាប់ (link) មិនដំណើរការគឺតែងតែអាចកើតមានឡើង។

### លោក វីហ្សាត (Mr. Wizard)

- (2) Official Mr.Wizard's World Channel - YouTube
- ភាគច្រើនជាប្រធានបទរូបវិទ្យា និងវិទ្យាសាស្ត្រទូទៅ។

លោក វីហ្សាត (Mr. Wizard) គឺជាកម្មវិធីទូរទស្សន៍ចំណាស់មួយដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៥១ និងបានបញ្ចប់នៅឆ្នាំ ១៩៨៩ ។ ទោះជាយ៉ាងណាក៏ដោយ ខ្លឹមសារភាគច្រើននៃកម្មវិធីនេះនៅតែមានតម្លៃ និងអាចយកមកប្រើប្រាស់បាន។ ប្រសិនបើអ្នកពិនិត្យមើលឱ្យបានគ្រប់ឆាណែល នៅក្នុងបញ្ជីរបស់យើង អ្នកប្រហែលជាអាចរកឃើញថាការពិសោធន៍ជាច្រើនរបស់គាត់ត្រូវបានយកទៅធ្វើឡើងវិញដោយអ្នកផលិតមាតិការវ័យក្មេងជំនាន់ក្រោយ។

លោក វីហ្សាត បានអនុវត្តនូវវិធីសាស្ត្រគរុកោសល្យក្នុងការបង្រៀនយ៉ាងពិតប្រាកដ ទោះបីជាកម្មវិធីនោះត្រូវបានរៀបចំឡើងដោយការរៀបចំទុកជាមុន ជាជាងការបង្រៀននៅក្នុងថ្នាក់រៀនជាក់ស្តែងក៏ដោយ។ កុមារនៅក្នុងកម្មវិធីទូរទស្សន៍អាចមានប្រតិកម្មតបតបានល្អជាង និងលឿនជាងសិស្សធម្មតា។ ប៉ុន្តែរបៀបដែលលោក វីហ្សាត សួរសំណួរទៅកាន់សិស្សរបស់គាត់ គឺជារឿងដែលគ្រូបង្រៀនគួរតែធ្វើពិតប្រាកដមែន។ គាត់តែងតែចាប់ផ្តើមជាមួយនឹងសំនួរបែបរិះរក និងអនុញ្ញាតឱ្យកុមារធ្វើការទស្សន៍ទាយលទ្ធផលដោយខ្លួនឯង។ ការធ្វើបែបនេះគឺដើម្បីដាស់ការចង់ដឹងចង់ឃើញ ហើយក៏ដើម្បីបណ្តុះចំណេះដឹងថ្មីៗទៅក្នុងគំនិតរបស់កុមារផងដែរ។

លោក វីហ្សាត មិនដែលភ្លេចលើកឡើងពីវិធានការសុវត្ថិភាពឡើយ ហើយនោះគឺជាចំណុចល្អដ៏ធំធេងមួយនៅពេលដែលអ្នកប្រៀបធៀបវាទៅនឹងអ្នកផលិតមាតិកាថ្មីៗ។ សរុបមក វិធីសាស្ត្ររបស់លោកគឺមានភាពហ្មត់ចត់ ច្បាស់លាស់ និងមានប្រសិទ្ធភាព។

### នារីរូបវិទ្យា (Physics Girl)

- (16) Physics Girl - YouTube
- ភាគច្រើនជាប្រធានបទរូបវិទ្យា។

ម្ចាស់ឆាណែលនេះ ឈ្មោះ Dianna Cowern ដែលជាអតីតនិស្សិតបញ្ចប់ការសិក្សាមកពីវិទ្យាស្ថានបច្ចេកវិទ្យាម៉ាសាឈូសេត (MIT) ជាមួយនឹងចំណេះដឹងផ្នែកស្រាវជ្រាវយ៉ាងរឹងមាំ។ នាងបានសម្រេចចិត្តផ្តោតសំខាន់លើវិទ្យាសាស្ត្រដែលមានប្រជាប្រិយភាព ប៉ុន្តែនាងនៅតែរក្សាស្តង់ដាខ្ពស់ចំពោះសុពលភាពតាមលក្ខណៈវិទ្យាសាស្ត្រ។ បន្ថែមពីនេះ គាត់បង្ហាញខ្លឹមសារដើម ដោយសង្កត់ធ្ងន់យ៉ាងខ្លាំងទៅលើការសួរសំនួរនៃការសង្កេតតាមបែបវិទ្យាសាស្ត្រ។ ការពិសោធន៍របស់គាត់ងាយស្រួលយល់ និងអាចអនុវត្តតាមបាន។ តែគួរឱ្យសោកស្តាយ គាត់បានផ្អាកសកម្មភាពនៅលើ YouTube របស់គាត់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារបញ្ហាសុខភាព។ ដោយសារតែគាត់នៅក្មេងនៅឡើយ គាត់អាចនឹងមានឱកាសបន្តសកម្មភាពរបស់គាត់ឡើងវិញបាន។ ទោះជាយ៉ាងនេះក៏ដោយ វីដេអូចាស់ៗរបស់គាត់នៅតែល្អគ្រប់គ្រាន់សម្រាប់ការទស្សនា។

### Veritasium

- (16) Veritasium - YouTube
- ភាគច្រើនជាប្រធានបទរូបវិទ្យា និងវិទ្យាសាស្ត្រទូទៅ។

បច្ចុប្បន្ន Veritasium គឺជាឆាណែលដ៏សំខាន់មួយសម្រាប់ការផ្សព្វផ្សាយវិទ្យាសាស្ត្រនៅលើអ៊ីនធឺណិត។ វាមានភាពល្បីល្បាញដោយសារការបកស្រាយបំភ្លឺនូវជំនឿមិនត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ និងការយកសម្មតិកម្មមកធ្វើតេស្តសាកល្បងជាក់ស្តែង។ ឆាណែលនេះមិនចម្លងការពិសោធន៍ល្បីៗដូចដែលឆាណែល YouTube ផ្សេងទៀតធ្វើនោះឡើយ។ ម្ចាស់ឆាណែលនេះ គឺលោក Derek Alexander Muller ដែលមានសញ្ញាបត្រថ្នាក់បណ្ឌិតផ្នែកស្រាវជ្រាវអប់រំឯកទេសរូបវិទ្យា។

### Nile Red

- (16) NileRed - YouTube
- ប្រធានបទ៖ គីមីវិទ្យា
- ប្រធានបទសំខាន់ៗ

ម្ចាស់ឆាណែលនេះ គឺលោក Nigel Braun ហាក់ដូចជាមិនសូវយកចិត្តទុកដាក់ខ្លាំងចំពោះសុវត្ថិភាពនោះទេ។ ខ្ញុំនឹងមិនមានការភ្ញាក់ផ្អើលទេ ប្រសិនបើបានឮព័ត៌មានអំពីគ្រោះថ្នាក់ដល់អាយុជីវិតជាយថាហេតុ។ វាប្រហែលជាប្រសើរជាងក្នុងការមើលការពិសោធន៍របស់គាត់នៅលើអ៊ីនធឺណិតជាជាងការព្យាយាមធ្វើត្រាប់តាម។

ទោះជាយ៉ាងណាក៏ដោយ គាត់មានគុណសម្បត្តិដ៏អស្ចារ្យក្នុងនាមជាអ្នកទំនាក់ទំនងផ្នែកវិទ្យាសាស្ត្រ ពីព្រោះគាត់រៀបរាប់អំពីដំណើរការនៃការគិតរបស់គាត់យ៉ាងល្អិតល្អន់។ គាត់តែងតែទទួលស្គាល់នៅពេលដែលគាត់មានការភ្ញាក់ផ្អើល និងនៅពេលដែលអ្វីៗមិនកើតឡើងដូចការរំពឹងទុក។

## វីដេអូតារាងខួប (Periodic Table of Videos)

- តំណភ្ជាប់៖ (16) Periodic Videos - YouTube

វាគឺជាឆាណែលគីមីវិទ្យារបស់សាកលវិទ្យាល័យ Nottingham ។ វាចាប់ផ្តើមដោយ ការបកស្រាយពន្យល់ពីប្រព័ន្ធនៃធាតុគីមីទាំង ១១៨ ក្នុងតារាងខួប ប៉ុន្តែវាមាននូវមាតិកាជាច្រើនទៀតទាក់ទងនឹងគីមីវិទ្យា។

អ្នកធ្វើបទបង្ហាញដ៏លេចធ្លោជាងគេគឺ សាស្ត្រាចារ្យ Poliakoff ដែលគាត់ពូកែខាងពន្យល់ពីវិធីសាស្ត្រវិទ្យាសាស្ត្រយ៉ាងខ្លាំង។ គាត់បង្ហាញពី ផ្នត់គំនិតពិតប្រាកដរបស់អ្នកស្រាវជ្រាវជាពិសេសនៅពេលដែលការពិសោធន៍បរាជ័យ និង នៅពេលជួបប្រទះនូវលទ្ធផលគួរឱ្យភ្ញាក់ផ្អើល។ គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលអាចរីករាយនៅពេលមានរឿងដែលមិនបានរំពឹងទុកកើតឡើង។ វាពិតជាផ្តល់នូវអារម្មណ៍ស្រស់ស្រាយក្នុងការស្តាប់អំពីដំណើរការនៃការគិតនេះ។

## វិស្វកម្មអនុវត្ត (Practical Engineering)

- (16) Practical Engineering - YouTube

ហ្គ្រេឌី (Grady) គឺជាវិស្វករសំណង់ស៊ីវិលម្នាក់។ គាត់អាចពន្យល់ពីបច្ចេកវិទ្យានៅពីក្រោយហេដ្ឋារចនាសម្ព័ន្ធជុំវិញខ្លួនយើង និងលក្ខណៈពិសេសនៃទិដ្ឋភាពទំនើបដែលយើងតែងតែមើលរំលង។ គាត់មានបុគ្គលិកលក្ខណៈដែលអាចជំរុញឱ្យមានការចាប់អារម្មណ៍លើអាជីពជាវិស្វករសំណង់ស៊ីវិល។ អ្វីដែលធ្វើឱ្យ ឆាណែលរបស់គាត់មានភាពលេចធ្លោគឺសមត្ថភាពរបស់គាត់ក្នុងការបង្កើតគំរូ និងបង្ហាញពីគោលគំនិតផ្សេងៗ។

គាត់មានការគិតបែបអនុវត្ត ហើយបានពន្យល់ពីរបៀបដែលវិស្វករអាចស្វែងរកការកែសម្រួលដ៏ស័ក្តិសមក្នុងបញ្ហាជាច្រើនដែលពួកគេត្រូវតែយកមកពិចារណានៅពេលរៀបចំគម្រោងមួយ។ ចំណុចនេះតែមួយមុខ ក៏អាចធ្វើឱ្យឆាណែលនេះមានតម្លៃយ៉ាងខ្លាំងផងដែរ ព្រោះផ្នត់គំនិតដូចគ្នានេះអាចយកទៅអនុវត្តបានចំពោះសកម្មភាពរបស់មនុស្សជាច្រើនទៀត។

## បុរសវិស្វករ (The Engineer Guy)

- (9) engineerguy - YouTube

ទោះបីជាឆាណែលនេះហាក់ដូចជាស្ងាត់បន្តិច និងមិនសូវមានការបង្ហោះថ្មីៗជាប្រចាំក៏ដោយ ប៉ុន្តែគុណភាពនៃវីដេអូពិតជាគួរឱ្យចាប់អារម្មណ៍ណាស់។ ឆានែលនេះបានពន្យល់ពីវិស្វកម្មនៅពីក្រោយវត្ថុប្រើប្រាស់ប្រចាំថ្ងៃជាច្រើន ដូចជាស្កុត (duct tape) ដបទឹកសូដា ប្លាស្ទិក ឬប៊ិចចុចជាដើម។ ចំណុចពិសេសនៅក្នុងវីដេអូមួយ ស្តីពីកំប៉ុងអាលុយមីញ៉ូមដែលរៀបរាប់លម្អិតអំពីប្រវត្តិនៃវត្ថុដ៏សាមញ្ញនោះ និងបញ្ហាជាច្រើនដែលវិស្វករត្រូវដោះស្រាយ មុនពេលពួកគេបង្កើតបាននូវការរចនាដែលយើងបានស្គាល់សព្វថ្ងៃនេះ។

## រូបវិទ្យា និងតារាវិទ្យា TAMU (TAMU Physics & Astronomy)

- (25) TAMU Physics & Astronomy - YouTube

នេះគឺជាឆាណែលដែលគ្រប់គ្រងដោយ សាកលវិទ្យាល័យ Texas A&M (TAMU) ដ៏ល្បីល្បាញ។ សាកលវិទ្យាល័យនេះមានមូលដ្ឋានគ្រឹះរឹងមាំ និងអាចផ្តល់នូវការបង្ហាញដ៏អស្ចារ្យ ប៉ុន្តែភាគច្រើននៃការបង្ហាញទាំងនោះគឺគ្រាន់តែជាការពិសោធន៍បែបបុរាណដែលស័ក្តិសមសម្រាប់ សាលាមធ្យមសិក្សា ឬគ្រាន់តែជាការធ្វើឱ្យវិទ្យាសាស្ត្រមានភាពពេញនិយម ដែលអាចអនុវត្តបានជាមួយនឹងឧបករណ៍សាមញ្ញៗ និងតូចៗប៉ុណ្ណោះ។

ទោះបីជាមានអ្នករៀបចំជាច្រើននាក់ក៏ដោយ អ្នកស្រី Tatiana Erukhimova គឺមានភាពល្បីល្បាញជាងគេដោយសារតែភាពរស់រវើករបស់គាត់ និងរបៀបដែលគាត់បង្កើតអន្តរកម្មជាមួយទស្សនិកជនរបស់គាត់។ ការពិសោធន៍ជាច្រើនត្រូវបានបង្ហាញក្នុងទម្រង់ជាវីដេអូខ្លីៗ។ TAMU ក៏បានរៀបចំពិព័រណ៍រូបវិទ្យា និងវិស្វកម្មប្រចាំឆ្នាំចាប់តាំងពីឆ្នាំ ២០១១ មក ដោយមានភ្ញៀវកិត្តិយសល្បីៗជាច្រើនចូលរួម ហើយមហាជនគ្រប់វ័យ ជាពិសេសកុមារ ក៏អាចចូលរួមបានដែរ។ វីដេអូនេះបានផ្តិតយករូបភាពអំពីព្រឹត្តិការណ៍ទាំងនេះ អាចជាប្រភពគំនិត និងជាកម្លាំងជម្រុញទឹកចិត្តដ៏ល្អមួយ។

ឆាណែលជាភាសាខ្មែរ (Channels in Khmer)

https://www.duraseksa.com/home

## STEM និងបាតុភូត

# “ចន្ទគ្រាស និង ព្រះចន្ទក្រហម”

ដោយៈ **ទ្រី គឹមហ៊**  **ឡាយ ស្រីណុច** និង **កប ណាក់**

**បាតុភូតតារាសាស្ត្រប្រចាំឆ្នាំ៖** ការអប់រំវិទ្យាសាស្ត្រនៅក្នុងសតវត្សរ៍ទី ២១ និងក្នុងយុគសម័យបញ្ញាសិប្បនិមិត្ត Ai មិនមែនជាការអង្គុយតែទន្ទេញមេរៀនក្នុងឯកសារ ឬការមើលរូបភាពស្ងួតហួតហែងនៅលើក្ដារខៀន ដែលមិនទាក់ទាញទៀតនោះទេ។ វិធីបង្រៀនថ្មីៗផ្ដោតលើ «ការរៀនតាមរយៈការពិសោធន៍ជាក់ស្ដែង (Experiential Learning)» និងការផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងបាតុភូតក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ នៅក្នុងយុគសម័យបច្ចេកវិទ្យា និងការអប់រំតាមបែប STEM (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) ការរៀនសូត្រមិនអាចកម្រិតត្រឹមតែការអានសៀវភៅពុម្ព ឬការមើលរូបភាពនៅលើក្ដារខៀននោះទេ។ ក្នុងនាមជាអ្នកអប់រំ ការបង្កើតឱកាសឱ្យសិស្សបាន «ឃើញផ្ទាល់ភ្នែក ប៉ះផ្ទាល់ដៃ» គឺជាគន្លឹះក្នុងការដាស់គំនិតច្នៃប្រឌិត និងពង្រឹងការចងចាំរយៈពេលវែងរបស់ពួកគេ។ ថ្មីៗនេះ កម្មវិធីសង្កេតការណ៍តារាសាស្ត្រពិសេសមួយ ត្រូវបានរៀបចំឡើងដោយបង្កប់នូវយុទ្ធសាស្ត្របង្រៀន និង រៀនយ៉ាងមានប្រសិទ្ធភាព ដោយយកបាតុភូតធម្មជាតិដ៏កម្រមកធ្វើជា «ថ្នាក់រៀនដ៏រស់រវើក»។




ក្លឹបសិក្សានិងព្រឹត្តិការណ៍តារាសាស្រ្ត. ការរៀបចំគម្រោងនិងសង្កេតព្រះចន្ទក្រហមនេះ ជាការផ្សារភ្ជាប់បាតុភូតធម្មជាតិទាក់ទងនឹងចក្រវាឡ និងជាការបើកផ្ទាំងទស្សនីយភាពដ៏អស្ចារ្យបំផុតប្រចាំឆ្នាំ ដែលគ្មានការបង្កើតរូបភាពណាអាចប្រៀបផ្ទឹមបានឡើយនោះគឺ បាតុភូត «ចន្ទគ្រាសពេញ (Total Lunar Eclipse)» និងជាពេលព្រះចន្ទបង្ហាញខ្លួនយ៉ាងស្រស់ស្អាត និងប្លែកភ្នែកបំផុតដែលគេឱ្យឈ្មោះថា «ព្រះចន្ទក្រហម»។ នេះមិនមែនត្រឹមតែជាបាតុភូតធម្មជាតិធម្មតានោះទេ ប៉ុន្តែវាគឺជា "រាត្រីមាសសម្រាប់ការអប់រំ" ។ នេះជាមូលហេតុដែលយើង ត្រូវចាប់ផ្ដើមបេសកកម្មមួយគឺការនាំយក តេឡេស្កុប (Telescopes) ដែលជាការបំបាត់ភាពស្រមៃ មកប្រគល់ជូនលោកគ្រូ អ្នកគ្រូមុខវិជ្ជាឯកទេសរបស់យើង ក្នុងការបំប្លែងខ្លួនទៅជាអ្នកនាំផ្លូវអវកាស។ យើងចង់ពង្រឹងជំនាញបច្ចេកវិទ្យានេះដល់ពួកគាត់ ដើម្បីឱ្យពួកគាត់អាចនាំសិស្សានុសិស្សដើរចេញពីបន្ទប់រៀនដ៏ចង្អៀតមកបង្កើត «មន្ទីរពិសោធន៍មេឃពេលយប់» ដោយផ្ទាល់ដៃ (អង្កេតស្ទៀរមេឃ)។ យោងតាមគេហទំព័រនិងវេបសាយបាតុភូត Blood Moonនេះកើតឡើងនៅពេលយប់ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ១៨:១៥នាទី ដល់ម៉ោង ១៩:៣០នាទី ស្របពេលដែលបាតុភូតធម្មជាតិកើតឡើងដែលជាពេលវេលាមាស សម្រាប់ការបង្រៀនដ៏កម្របំផុតប្រចាំឆ្នាំ គឺជាការកើតឡើងស្របគ្នានៃបាតុភូតពីរគឺបាតុភូត Blood Moon៖ ជាពេលវេលាដែលព្រះចន្ទបង្ហាញខ្លួនយ៉ាងស្រស់ស្អាត ធំ និងមានពណ៌ក្រហមឆ្អៅប្លែកភ្នែកបំផុតប្រចាំឆ្នាំ ដែលទាក់ទាញអារម្មណ៍សិស្សខ្លាំងបំផុត និងចន្ទគ្រាស

ពេញលេញ (Total Lunar Eclipse)៖ ជាពេលដែលស្រមោលផែនដីបិទបាំងព្រះចន្ទយ៉ាងពេញលេញ ដែលបង្ហាញពីដំណើរគន្លងតារាសាស្ត្រជាក់ស្តែង ដើម្បីដោះស្រាយមន្ទិលសិស្សានុសិស្ស។ នៅពេលសិស្សម្នាក់ៗឱនសម្លឹងមើលកែវ(Lens)តេឡេទស្សន៍ ហើយស្រែកឡើងដោយភាពភ្ញាក់ផ្អើល ពេលឃើញផ្ទៃព្រះចន្ទពណ៌ក្រហមឆ្អៅ និងរណ្តៅក្រហូងភ្នំភ្លើងយ៉ាងច្បាស់នោះ គឺជាពេលដែលចំណេះដឹងត្រូវបានដិតជាប់ក្នុងខួរក្បាលរបស់ពួកគេ។ សិស្សបានបង្ហាញក្តីសប្បាយរីករាយយ៉ាងខ្លាំង ដោយសារវាជាលើកដំបូងដែលពួកគេបានប្រើប្រាស់ឧបករណ៍ទំនើបបែបនេះ និងបានថតរូបភាពព្រះចន្ទក្រហមតាមរយៈទូរសព្ទដៃរបស់ពួកគេទុកជាអនុស្សាវរីយ៍សិក្សា។ គម្រោងនេះបានបំលែងការរៀនសូត្រពីការទន្ទេញចាំមាត់ ឬបែបស្រមើស្រមៃទៅជាការរុករក និងមើលឃើញជាក់ស្តែង។ ក្នុងព្រឹត្តិការណ៍តារាសាស្ត្រដែលគ្រូដឹកនាំក្លឹប និង សិស្សបានប្រើប្រាស់ម៉ោងក្លឹបសិក្សា ដើម្បីរៀបចំការសង្កេតព្រះចន្ទក្រហមនេះដោយពិចារណាលើចំណុចសំខាន់ៗដូចជា៖

*១. ការរៀបចំផ្នែកបច្ចេកទេស និងឧបករណ៍* ព្រឹត្តិការណ៍នេះក៏ជាឱកាសល្អក្នុងការរៀបចំសកម្មភាពបង្រៀន ដោយប្រើប្រាស់សម្ភារៈឧបទ្ទេសសំខាន់នោះគឺ តេឡេស្កុប (Telescopes) ផ្សារភ្ជាប់ទៅនឹងមេរៀនថ្នាក់ទី១២ និងបាតុភូតធម្មជាតិដ៏កម្រនេះ។ ក្នុងពេលជាមួយគ្នានោះដែរមានបាតុភូតធម្មជាតិដ៏អស្ចារ្យពីរកើតឡើងផងដែរគឺជាពេលដែលព្រះចន្ទស្អាតជាងគេ និងមានពណ៌ក្រហមឆ្អៅប្រចាំឆ្នាំដែលគេឱ្យឈ្មោះថា Blood Moon និងបាតុភូតចន្ទគ្រាសពេញ (Total Lunar Eclipse)។

*២. សមាហរណកម្មមុខវិជ្ជានិងមេរៀន* សាកស្រមៃមើលថានៅក្នុងថ្នាក់រៀនថ្នាក់ទី១២ ដ៏ស្ងាត់ច្រងំមួយ សិស្សានុសិស្សកំពុងសំឡឹងមើលក្តារខៀនដែលពោរពេញដោយគំនូរព្រះចន្ទ ផែនដី និងគន្លងតារា។ ពួកគេព្យាយាមចងចាំទ្រឹស្តីស្មុគស្មាញនៅក្នុង ជំពូកទី២ «ព្រះចន្ទរបស់ផែនដី» និង ជំពូកទី៣ «ការស្រាវជ្រាវពិសកល» ដើម្បីត្រៀមប្រឡង។ ប៉ុន្តែសម្រាប់ពួកគេ សកលលោកដ៏ធំធេងនោះ នៅតែជាអ្វីមួយដែលឆ្ងាយដាច់កន្ទុយភ្នែក និងមានត្រឹមតែនៅលើក្រដាស។

**គម្រោង និងជ្រើសរើសទីតាំង៖** សម្រាប់លោកគ្រូ-អ្នកគ្រូដែលមានបំណងចង់ដឹកនាំសិស្សអនុវត្តគម្រោង និងរៀបចំព្រឹត្តិការណ៍សង្កេតព្រះចន្ទក្រហមអាចពិចារណាលើចំណុចសំខាន់ៗដែលអាចធ្វើទៅបានដែលរួមមានដូចជា៖

*១. ពិនិត្យកាលវិភាគនៃបាតុភូតតារាស្ត្រ៖* ត្រូវតាមដានព័ត៌មានពីបាតិភូតធម្មជាតិ (ចន្ទគ្រាស សូរ្យគ្រាស ឬយប់ដែលព្រះចន្ទពេញបូណ៌មីច្បាស់) ឱ្យបានច្បាស់លាស់ទាំងថ្ងៃខែនិងម៉ោង។

*២. ជ្រើសរើសទីតាំងចំហ៖* ទីតាំងត្រូវតែជាកន្លែងទូលាយគ្មានដើមឈើ ឬអគារបាំងនិងមានពន្លឺខាងតិចតួចដូចជាទីធ្លាកណ្តាលវាល ឬនៅលើដំបូលអគារសិក្សា។

*៣. បង្កើតសំណួរជំរុញការគិត៖* ដោយចោទជាសំណួរថាហេតុអ្វីបានជាព្រះចន្ទប្រែជាពណ៌ក្រហម? ឬ តើស្រមោលដែលបាំងនោះមានទម្រង់ដូចម្តេច? ឬចុះបើ... យើងអាចនាំពួកគេធ្វើដំណើរទៅកាន់ទីអវកាសនោះបាន?

*៤. ការអនុវត្តផែនការ៖* ព្រឹត្តិការណ៍សង្កេត Blood Moon ពេលយប់ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ១៨:១៥នាទី ដល់ម៉ោង ១៩:៣០នាទី។

**ភាពជោគជ័យនៃព្រឹត្តិការណ៍សង្កេត Blood Moon តាមការយល់ឃើញរបស់សិស្ស៖** ភាពជោគជ័យនៃការឆ្លុះមើលស្វែគម្រោងនេះ វាមិនមែនស្ថិតនៅលើភាពល្អឥតខ្ចោះនៃការប្រើប្រាស់ឧបករណ៍នោះទេ ប៉ុន្តែគឺស្ថិតនៅលើ «ភាពយកចិត្តទុកដាក់សង្កេត ពន្លឺនៃក្តីរំភើប និងការយល់ដឹងដ៏ជ្រាលជ្រៅរបស់សិស្សានុសិស្ស»។ តាមរយៈចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់សិស្សថ្នាក់ទី១២ យើងអាចសង្ខេបផលជះពីអ្វីដែលពួកគេទទួលបានមាន ៣ សំខាន់ៗគឺ៖

*ចំនុចសំខាន់ទី១៖ ការបំប្លែងទំព័រសៀវភៅ មកជាការសង្កេតផ្ទាល់ភ្នែក (Theory to Reality)*

សិស្សភាគច្រើនបានលើកឡើងថា កន្លងមកពួកគេធ្លាប់តែឃើញរូបភាព និងទ្រឹស្តីនៅលើក្រដាសសៀវភៅពុម្ព ឬផ្ទាំងអេក្រង់ទូរសព្ទ ដែលអ្នកផលិតមាតិកាបង្ហោះផ្សព្វផ្សាយតែប៉ុណ្ណោះ។ ការដែលបានសង្កេតមើលគន្លង និងស្រមោលផែនដីគ្របដណ្តប់លើព្រះចន្ទពណ៌ក្រហមឆ្អៅ ដោយផ្ទាល់ភ្នែក តាមរយៈតេឡេស្កុប បានធ្វើឱ្យមេរៀនផែនដីវិទ្យាក្លាយជាការដឹងលឺដ៏ជាក់ច្បាស់ និងយល់កាន់តែស៊ីជម្រៅជាងមុនទ្វេដង។



***ចំនុចសំខាន់ទី២៖ ការបណ្តុះការគិតនិងការស្វែងរកតាមបែបវិទ្យាសាស្ត្រ (Inquiry-Based Learning)***

បទបង្ហាញពីលោកគ្រូ-អ្នកគ្រូមិនមែនជាការបង្រៀនឱ្យទន្ទេញចាំមាត់នោះទេ ប៉ុន្តែជាការបង្កើតសំណួរចោទសួរ និងការបណ្តុះចម្ងល់។ សកម្មភាពនេះបានជំរុញឱ្យសិស្សបង្កើតទម្លាប់សង្កេតដោយហ្មត់ចត់ រៀនគិតវិភាគពីមូលហេតុនៃការផ្លាស់ប្តូរពណ៌របស់ព្រះចន្ទ និងស្វែងយល់ពីរបៀបដែលបច្ចេកវិទ្យាតេឡេ-ស្កុបអាចជួយមនុស្សជាតិឱ្យមើលឃើញវត្ថុអវកាសដ៏ឆ្ងាយសែនឆ្ងាយបាន។

***ចំនុចសំខាន់ទី៣៖ អនុស្សាវរីយ៍សិក្សារួមគ្នា និងការកសាងទំនាក់ទំនង (Social and Collaborative Learning)***

ការរៀនមិនមែនធ្វើឡើងតែម្នាក់ឯងនោះឡើយ។ រាត្រីសង្កេតការណ៍នេះបានក្លាយជាវេទិកាសង្គមដ៏រស់រវើក ដែលសិស្សានុសិស្សបានជួបជុំគ្នា ជជែកពិភាក្សា ដោះស្រាយចម្ងល់ជាមួយគ្នា និងបង្កើតទំនាក់ទំនងដ៏រឹងមាំជាមួយមិត្តភក្តិរួមជំនាន់ ឆ្លងកាត់ការចែករំលែកក្តីរំភើបនាពេលរាត្រី។

***សម្រង់ចំណាប់អារម្មណ៍ទាំង ៣ របស់សិស្ស៖***

"ខ្ញុំសប្បាយចិត្ត និងរីករាយនឹងទទួលបានចំណេះដឹងថ្មី តាមរយៈការធ្វើបទបង្ហាញរបស់គ្រូ និងសំណួរចម្លើយដែលបង្កើតជាចម្ងល់ឱ្យពួកយើងយកទៅស្រាវជ្រាវ ឬពិភាក្សាដោះស្រាយគ្នា។ ពីមុនធ្លាប់តែមើលតាមទូរស័ព្ទ ឬទូរទស្សន៍ តែឥឡូវបានមកមើលផ្ទាល់នឹងភ្នែកតាមតេឡេស្កុប។ បន្ថែមលើនេះ គឺការបានមើលបាតុភូតជាមួយមិត្តភក្តិជាច្រើនដែលបង្កើតបានជាទំនាក់ទំនងថ្មីៗដ៏អស្ចារ្យ។"

ស្រៀន សេងលី ། សិស្សថ្នាក់ទី១២





"ព្រឹត្តិការណ៍នេះធ្វើឱ្យខ្ញុំមានអារម្មណ៍ថា វិទ្យាសាស្ត្រមិនមែនជារឿងដែលនៅឆ្ងាយពីពួកយើងនោះទេ សូម្បីតែព្រះចន្ទដែលនៅឆ្ងាយសែនឆ្ងាយ ក៏ពួកយើងអាចប្រើចំណេះដឹងមកបកស្រាយបានដែរ។ លើសពីនេះទៅទៀត វាមិនត្រឹមតែផ្តល់ចំណេះដឹងផ្នែកតារាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាជួយបណ្តុះបណ្តាលឱ្យយើងមានការគិតបែបវិទ្យាសាស្ត្រ និងការសង្កេតដោយហ្មត់ចត់ទៀតផង។"

ម៉េង ស្រីនាង ། សិស្សថ្នាក់ទី១២E

"នេះគឺជាបាតុភូតតារាសាស្ត្រដ៏ជក់ចិត្តបំផុតមួយ ព្រោះវាជាការបង្ហាញឱ្យឃើញនូវចលនារបស់អង្គធាតុក្នុងប្រព័ន្ធព្រះអាទិត្យដោយផ្ទាល់ភ្នែក។ ចន្ទគ្រាសកើតឡើងនៅពេលដែលព្រះអាទិត្យ ផែនដី និងព្រះចន្ទ រៀបជួរគ្នាត្រង់តែមួយដោយមានផែនដីនៅកណ្តាល។"

សុខឡេង សុចិន្តា ། សិស្សថ្នាក់ទី១២E

## ចំណាប់អារម្មណ៍បន្ថែមពីសិស្សានុសិស្ស៖

បន្ថែមលើនេះ សិស្សានុសិស្សរួមជំនាន់ ដូចជាប្អូនប្រុស សៀក ឆេងឃាង (១២A) បានបង្ហាញការភ្ញាក់ផ្អើលយ៉ាងខ្លាំងចំពោះដំណើរវិវត្តន៍នៃបច្ចេកវិទ្យាតេឡេស្កុប ដែលអនុញ្ញាតឱ្យសម្លឹងឃើញវត្ថុអវកាសដ៏សែនឆ្ងាយបានយ៉ាងច្បាស់ និងបាតុភូតចន្ទគ្រាសពណ៌ក្រហមដែលមើលឃើញនឹងភ្នែកទទេ ចំណែកឯប្អូនស្រី នឿន សុផាន់នី (១២E) ក៏បានបន្ថែមដែរថា ការសិក្សាតារាវិទ្យាតាមបែបវិទ្យាសាស្ត្រជាក់ស្តែងបែបនេះ នាំមកនូវអារម្មណ៍ប្លែកថ្មី អស្ចារ្យ និងបង្កើតជាក្តីរំភើបដែលមិនធ្លាប់មានពីមុនមកក្នុងជីវិតសិក្សារបស់ពួកគេ។



# Cambodia International Conference on Mentoring Educators (CICME)

**4th Virtual Conference | From Phnom Penh, Cambodia | 5-7 October 2026**

## Welcome to CICME 2026!

The New Generation Pedagogical Research Department is proud to invite you to its Virtual Cambodia International Conferences on Mentoring Educators, which will be held online from Phnom Penh, Cambodia. Researchers, teacher trainers, advisors and consultants from Asia and around the globe are invited to join us in Cambodia to share knowledge and experiences with our developing community.

The detailed program will be released in September, after the selection of the presenters.

**Main Theme: "Mentoring: pathways to teacher and leader quality and professionalism"**

### Policy

- Research, Inspection and Mentoring, their roles in public policies (implementation and feedback).
- Mentoring as a tool to support the implementation of various school models and public reforms.
- Mentoring international partnership.

### Practice

- Mentoring during teaching practicum.
- Mentoring during principals' practicum.
- Induction mentoring for new teachers; coaching cycles.
- Continuous Professional Development and lesson study.
- Mentoring in school networks and remote mentoring.

### Innovation

- Mentoring to support technical projects.
- Keeping pace with technological innovation and the AI revolution.
- Using AI in mentoring.

### Leadership

- Mentoring standards; mentor preparation.
- School leadership in mentoring; monitoring & evaluation.
- Building a mentoring culture and Professional Learning Communities.

**Scan For Registration**

### ORGANIZATION

The conference is organized by New Generation Pedagogical Research Department (NGPRD) and the National Institute of Education (NIE). It is made possible thanks to the support of the Ministry of Education, Youth and Sport of Cambodia (MOEYS), Kampuchea Action to Promote Education (KAPE), and Texas A&M University.

This conference will be held in English through real-time online participation. It will provide opportunities for participants to share and hear about various ideas, programs, research, and discuss the challenges associated with mentoring educators online.

**For further information:**
Mr. Stanislas Kowalski at: ngprc.faculty@gmail.com
Local sponsors may email us at: ngprd@nie.edu.kh

**NO REGISTRATION FEES**

# “របៀបបង្រៀនអ្វីមួយដែលមិនមានសោះ”

ដោយ **Juliette Sochacki** បកប្រែដោយ **ឆាយទី ចាន់ិត**

នៅពេលដែលខ្ញុំបានព្យាយាមបង្រៀនភាសាអង់គ្លេសទាក់ទងកាលបច្ចុប្បន្ន (present tense) ដល់ក្រុមសិស្សដែលមានអាយុប្រមាណ៩ឆ្នាំនៅប្រទេសឥណ្ឌូនេស៊ី ខ្ញុំបានយល់ឃើញយ៉ាងលឿនថា ខ្ញុំធ្លាប់គិតថាវេយ្យាករណ៍ជារឿងធម្មតាហួសហេតុ។ សម្រាប់ខ្ញុំ ការបំបែកកិរិយាសព្ទ (conjugation) គឺជារឿងធម្មតាខ្លាំងណាស់ ដល់ថ្នាក់ខ្ញុំមិនដែលគិតថាត្រូវបកស្រាយវាយ៉ាងដូចម្ដេចផង។ ប៉ុន្តែបន្ទាប់មក ខ្ញុំបានរកឃើញថា នៅក្នុងភាសាឥណ្ឌូនេស៊ី មិនដូច្នេះទេ។ កិរិយាសព្ទគឺមិនមានការប្រែប្រួលអ្វីទេសម្រាប់ភាសាឥណ្ឌូនេស៊ី (ដូចជានៅក្នុងភាសាខ្មែរផងដែរ ប្រសិនបើខ្ញុំយល់មិនខុសទេ)។

ខ្ញុំឈរនៅមុខកុមារចំនួន២០នាក់ ដែលស្ទើរតែមិនអាចនិយាយអង់គ្លេសបាន ហើយសាកល្បងណែនាំគំនិតវេយ្យាករណ៍មួយដែលពិតជាប្លែកសម្រាប់ភាសារបស់ពួកគេ។ ខ្ញុំបានគូររូប ប្រើចលនា និងធ្វើឧទាហរណ៍ជាញឹកញាប់ ប៉ុន្តែខ្ញុំកាន់តែព្យាយាមពន្យល់ ពួកគេមានការយល់ច្រឡំកាន់តែច្រើនឡើងប៉ុណ្ណោះដែរ។ នៅពេលមួយ ខ្ញុំគិតថាពួកគេគ្រាន់តែងក់ក្បាលដើម្បីកុំឱ្យខ្ញុំអន់ចិត្តប៉ុណ្ណោះ ប៉ុន្តែពួកគេមិនបានយល់អ្វីសោះឡើយ។

ខ្ញុំសូមអរគុណ អ្នកម្ដាយម្នាក់ដែលស្ថិតនៅទីនោះដែលអាចនិយាយអង់គ្លេសបានល្អ។ គាត់បានជួយបកប្រែ ហើយយើងអាចបញ្ចប់មេរៀនបានយ៉ាងល្អជាមួយគ្នា។ ទោះជាយ៉ាងណា ខ្ញុំនៅតែមានអារម្មណ៍ចម្លែកមួយ នោះគឺការយល់ដឹងថា អ្វីដែលសាមញ្ញបំផុតសម្រាប់ខ្ញុំ អាចជារឿងមិនសាមញ្ញទាល់តែសោះសម្រាប់មនុស្សដទៃ។ វាជាពេលវេលាមួយដែលធ្វើឲ្យខ្ញុំទន់ខ្លួន ហើយវាបានធ្វើឲ្យខ្ញុំយល់ថា ការ

# “វិន័យ និងភាពខុសគ្នាខាងវប្បធម៌”

ដោយ **Stanislas Kowalski**
បកប្រែដោយ **ឆាយទី ចាន់ិត**

បង្រៀនភាសាមិនមែនត្រឹមតែបង្រៀនពាក្យនិងវេយ្យាករណ៍ទេ ប៉ុន្តែជាការរៀនមើលពិភពលោកតាមរយៈវេយ្យាករណ៍របស់ភាសាផ្សេងៗទៀតផងដែរ។ ខ្ញុំកំពុងបង្រៀនមេរៀនមួយអំពី ជំនាញសរសេរជាផ្នែកមួយនៃវគ្គសិក្សាភាសាបារាំងរបស់ខ្ញុំនៅ សាកលវិទ្យាល័យ Central South ក្នុងប្រទេសចិន។ ខ្ញុំបានសុំឱ្យសិស្សធ្វើអ្វីមួយដែលរឿងធម្មតាណាស់នៅក្នុងប្រទេសបារាំង ប៉ុន្តែវាហាក់មិនធម្មតានៅក្នុងប្រទេសចិន។ កាតពិនិត្យមើលទស្សនៈមួយនៅក្នុងផ្នែកដំបូងនៃអត្ថបទ និងមតិផ្ទុយគ្នានៅក្នុងផ្នែកទីពីរ ជាវិធីសាស្ត្រមួយប្រភេទដែលគេហៅថា Dialectic (សិល្បៈនៃការស៊ើបអង្កេត ឬការពិភាក្សាអំពីគំនិតដ៏ត្រឹមត្រូវ)គឺជា មូលដ្ឋាននៃទស្សនវិជ្ជាលោកខាងលិចអស់រយៈពេលជាងពីរសហស្សវត្សរ៍មកហើយ។ ប៉ុន្តែនៅក្នុងប្រទេសចិន សិស្សពូកែជាសិស្សដែលអាចនិយាយឡើងវិញនូវអ្វីដែលគ្រូរបស់ពួកគេបានបង្រៀន។ មិនយូរប៉ុន្មាន សិស្សម្នាក់ ដែលជាសិស្សពូកែបំផុត បានសម្រេចចិត្តធ្វើអ្វីមួយដែលមិនអាចនឹកស្មានដល់។ នាងបានចាកចេញពីថ្នាក់! ខ្ញុំបានដើរតាមនាង ដោយព្យាយាមយល់ពីស្វែងយល់ពីបញ្ហា។ នាងមានការខកចិត្តចំពោះអ្វីដែលនាងគិតថាជាការណែនាំមិនសមហេតុផល។ ខ្ញុំបានបញ្ចុះបញ្ចូលនាងឱ្យសាកល្បងវា។

ទន្ទឹមនឹងនេះ សិស្សផ្សេងទៀតដែលនៅសល់គឺនៅស្ងៀម។ ហើយខ្ញុំក៏គិតថា នៅប្រទេសរបស់ខ្ញុំ វានឹងលំបាក ឬស្ទើរតែអសមត្ថភាពក្នុងការតាមសិស្សម្នាក់ ដោយទុកសិស្សដែលនៅសល់ឲ្យគ្មានអ្នកត្រួតពិនិត្យ។ ភាពខុសគ្នាខាងវប្បធម៌ដូចគ្នាដែលបានបង្កើតបញ្ហាក៏បានផ្ដល់ឱ្យខ្ញុំនូវវិធីដើម្បីដោះស្រាយវាផងដែរ។

# អ្នកចូលរួមចំណែកក្នុងទស្សនាវដ្ដីគន្លឹះអប់រំ



**បណ្ឌិត ស៊ុន សុម៉ារ៉ា**

អ្នកជំនាញផ្នែក ដឹកនាំអប់រំ ការប្រឹក្សាគរុកោសល្យ និងការអភិវឌ្ឍសមត្ថភាព ដែលមានបទពិសោធជាង១៦ឆ្នាំ ក្នុងការជំរុញកំណែទម្រង់អប់រំ និង អភិវឌ្ឍសមត្ថភាពស្ថាប័នទាំងក្នុងវិស័យសាធារណៈឯកជន និង អង្គការជាតិ-អន្តរជាតិ។ បច្ចុប្បន្ន លោកគឺជាអ្នកសម្របសម្រួលកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ (ឯកទេសប្រឹក្សាគរុកោសល្យ) នៅដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD) នៃវិទ្យាស្ថានជាតិអប់រំហៅកាត់ថា NIE ក្រោមការប្រតិបត្តិរបស់អង្គការ KAPE។



**Stanislas Kowalski**

គ្រូប្រឹក្សាគរុកោសល្យ និង ជាសមាជិកស្ថាបនិកនៃដេប៉ាតេម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (New Generation Pedagogical Research Department).លោកបានបញ្ចប់ការសិក្សាមកពីសាកលវិទ្យាល័យ Université Jean Moulin ក្នុងទីក្រុង Lyon (ប្រទេសបារាំង) ផ្នែកអក្សរសាស្ត្របុរាណ។ លោកធ្លាប់បង្រៀន សិស្សគ្រប់វ័យ និង គ្រប់កម្រិត (ពីអក្ខរក្រមដល់សាកលវិទ្យាល័យ) នៅតាមបណ្ដាប្រទេសមួយចំនួន ដូចជា បារាំង ចិន ជីប៊ូទី និងកម្ពុជា ។ លោកក៏បាននិពន្ធសៀវភៅ និងសៀវភៅណែនាំជាច្រើនផងដែរ។



**ថៅ វណ្ណៈ**

អ្នករចនាក្រប និងរៀបរៀងអត្ថបទប្រចាំទស្សនាវដ្ដីគន្លឹះអប់រំ ហើយក៏ជាគ្រូបង្រៀនកម្រិតឧត្ដមមានបទពិសោធន៍ជាង ១០ឆ្នាំ លើវិស័យគណិតវិទ្យា STEM និងការអប់រំបែបឌីជីថល ព្រមទាំងជាគ្រូប្រឹក្សាគរុកោសល្យប្រចាំគម្រោង IDEAL។ លោកបានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ ឯកទេសប្រឹក្សាគរុកោសល្យពីដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD) នៃវិទ្យាស្ថានជាតិអប់រំ NIE ប្រទេសកម្ពុជា និងព័ន្ធកិច្ចក្នុងនាមជាអ្នកដឹកនាំពី APIIS ប្រទេសសិង្ហបុរី និងធ្លាប់ទទួលបានជ័យលាភីថ្នាក់ជាតិជាគ្រូបង្រៀនច្នៃប្រឌិតខ្ពស់ឆ្នាំ ២០២០ ផងដែរ។



**ស៊ឹម វណ្ណាសុខាលីលី**

គ្រូបង្រៀនភាសាអង់គ្លេសកម្រិតមធ្យមសិក្សាដែលមានបទពិសោធន៍ជាច្រើនឆ្នាំ ដូចជាវិធីសាស្ត្របង្រៀនផ្អែកលើការទំនាក់ទំនង និងការចូលរួមរបស់សិស្ស។ បច្ចុប្បន្ននេះកញ្ញាជាមន្ត្រីជំនួយការស្រាវជ្រាវក្នុងការស្រាវជ្រាវអំពីការបង្រៀនការកែលម្អកម្មវិធីសិក្សា និងលទ្ធផលសិក្សារបស់សិស្ស។ បានរួមចំណែកដល់ការដល់ ការលើកកម្ពស់គុណភាពបង្រៀននិងជួយឱ្យមានការសម្រេចចិត្តត្រឹមត្រូវក្នុងវិស័យអប់រំ។



**ផាន់ ប៊ុនណាត**

អ្នកដឹកនាំផ្នែកអប់រំដែលមានបទពិសោធន៍ជាង ១០ឆ្នាំ និងជាអ្នកសម្របសម្រួលការវាយតម្លៃទទួលស្គាល់គុណភាពអប់រំកម្មវិធីសាលារៀនជំនាន់ថ្មី (NGS)។ លោកធ្លាប់ជាប្រធានគម្រោង BEST Activity ដោយ USAID ដោយដឹកនាំគំនិតផ្តួចផ្តើមលើកម្មវិធីអក្ខរកម្មជាតិ កម្មវិធី សិក្សា និងកំណែទម្រង់អប់រំ ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។ និងជាអតីតរូបភាពអាហារូបករណ៍ Hubert H. Humphrey Fellow ឆ្នាំ២០១៩ នៅសាកលវិទ្យាល័យ Vanderbilt សហរដ្ឋអាមេរិក លើឯកទេសរដ្ឋបាល ការគ្រប់គ្រង និងគោលនយោបាយអប់រំ ព្រមទាំងមានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រង និងផែនការអប់រំពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។



**Juliette Sochacki**

និស្សិតហាត់ការនៅដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD) ទាក់ទងការនិពន្ធអត្ថបទសម្រាប់ទស្សនាវដ្ដី។ Juliette កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកកិច្ចសហប្រតិបត្តិការអន្តរជាតិនៅសាកលវិទ្យាល័យ Université libre de Bruxelles (ULB) ប្រទេសបែលហ្ស៊ិក (Belgium)។ Juliette ធ្លាប់ជាគ្រូបង្រៀនភាសាអង់គ្លេសស្ម័គ្រចិត្តនៅក្នុងទ្វីបអាស៊ី។



**ស៊ី ហុង**

គ្រូបង្រៀនកម្រិតឧត្តមជាមួយមានបទពិសោធន៍៥ឆ្នាំ ជាគ្រូបង្រៀនភាសាអង់គ្លេស និង៣ឆ្នាំជាគ្រូប្រឹក្សាគរុកោសល្យនៅក្នុងកម្មវិធី សាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ដែលផ្តោតលើការកែលម្អ វិធីសាស្ត្របង្រៀន ការគ្រប់គ្រងថ្នាក់រៀន និងបង្កើតបរិយាកាសសិក្សាវិជ្ជមាន ដើម្បីលើកកម្ពស់ជំនាញភាសាអង់គ្លេស និងការគិតវិភាគរបស់សិស្ស ហើយបន្តអភិវឌ្ឍវិជ្ជាជីវៈនិង រួមចំណែកក្នុង ការកែលម្អគុណភាពអប់រំក្នុងសហគមន៍។



**ចេង ភារី**

គ្រូបង្រៀនគណិតវិទ្យា ក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប និងជាសមាជិកក្រុម CPD របស់សាលារៀនដែលមានតួនាទី ក្នុងការចងក្រងឯកសា និង ជួយក្នុងការគាំទ្រលោកគ្រូ អ្នកគ្រូ តាមរយៈ សិក្ខាសាលា ឬ ការចែករំលែកតាម រយៈ PLC របស់សាលា។ អ្នកគ្រូមានបទពិសោធន៍៥ឆ្នាំ ជាគ្រូប្រឹក្សាគរុកោសល្យដោយបានបញ្ចប់សញ្ញាបត្រគ្រូឧត្តមពី NIE និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រឹក្សាគរុកោសល្យ ពី NGPRC។ ចំណង់ចំណូល៖ ចិត្តផ្តោតលើការពង្រឹងគុណភាពបង្រៀន និងលើកកម្ពស់វប្បធម៌វិជ្ជមាន និងការសហការគ្នា។



**អ៊ឹម លាងស៊ីម**

គ្រូឧទ្ទេសផ្នែកវិធីសាស្រ្តបង្រៀន និង ចំណេះដឹង ផ្នែកការបង្រៀនគណិតវិទ្យា នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ (PTEC) ដែលមានបទពិសោធន៍ជាង១០ឆ្នាំក្នុងវិស័យអប់រំ។ លោកស្រីបានចូល រួមយ៉ាងសកម្មក្នុងការ អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ហើយបានដឹកនាំសិស្សក្នុងកម្មវិធីតាំងពិព័រណ៍អន្តរជាតិនិងដូចជា កម្មវិធីផ្លាស់ប្តូរការសិក្សាមួយចំនួន។ ចំណង់ចំណូលចិត្តទៅលើការស្រាវជ្រាវ ការបង្រៀន ការបណ្តុះបណ្តាល និងការចែករំលែកពីវិធីសាស្រ្តបង្រៀន និងការបង្កើតសម្ភារៈឧបទេសដើម្បីឱ្យដំណើរការបង្រៀនមានភាពសកម្ម។



**អ៊ាង ចិន្ត្រា**

គ្រូបង្រៀនភាសាអង់គ្លេស និងជាគ្រូប្រឹក្សាគរុកោសល្យនៃវិទ្យាល័យ ហ៊ុន សែន ពាមជីកង។ ជាមួយបទពិសោធន៍ក្នុងវិស័យអប់រំជាង៨ឆ្នាំ ដូចជាវិធីសាស្រ្តបង្រៀនជាដើម ហើយត្រូវបានគេស្គាល់ថាជាអ្នកលើកកម្ពស់ការបង្រៀន និង ការរៀនសូត្រតាមបែបអន្តរកម្ម តាមបែបទំនើប និងជម្រុញឱ្យមាន ការរៀនសិក្សាពេញមួយជីវិតផងដែរ។



**ឆាយទី ចានិត**

គ្រូប្រឹក្សាគរុកោសល្យនៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី (ARS-NGS)។ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រឹក្សាគរុកោសល្យពី NGPRD និងមានបទពិសោធន៍បង្រៀន និងប្រឹក្សាគរុកោសល្យសរុប ៦ឆ្នាំ។ លោកផ្តោតលើការគាំទ្រ បង្វឹក និងអភិវឌ្ឍគ្រូបង្រៀន ដើម្បីពង្រឹងគុណភាពបង្រៀនបង្កើតបរិយាកាសសិក្សាមានប្រសិទ្ធភាព និង លើកកម្ពស់វប្បធម៌វិជ្ជមាន និងការសហការគ្នា។



**ឈាង ម៉េរី**

បុគ្គលិកអប់រំ ដែលបានបម្រើការក្នុងវិស័យអប់រំអស់រយៈពេល១០ ឆ្នាំ ទទួលបានបទពិសោធន៍ជាច្រើនដូចជា បង្រៀនសិស្សកម្រិតបឋមអស់រយៈពេល៧ឆ្នាំ និងបានបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេស ប្រឹក្សាគរុកោសល្យពី NIE។ បច្ចុប្បន្ននេះមានតួនាទីជាគ្រូប្រឹក្សាគរុកោសល្យនៃវិទ្យាល័យ ហ៊ុនសែន សេរីភាព ក្រុងតាខ្មៅ។ ចំណង់ចំណូលចិត្តក្នុងការអប់រំ និងចង់ឱ្យប្រទេសរបស់ខ្ញុំក្លាយជាប្រទេសដែលមានធនធានមនុស្សដ៏ខ្លាំងក្លា និងរឹងមាំ។



**ព្រឿងសួរ ទីតា**

គ្រូបង្រៀន និងគ្រូប្រឹក្សាគរុកោសល្យនៅវិទ្យាល័យ ហ៊ុនសែន សេរីភាព។ បានបញ្ចប់កម្រិតថ្នាក់បរិញ្ញាបត្រពីវិទ្យាស្ថានភាសាបរទេស និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អប់រំពីដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីជំនាន់ទី៥ នៃវិទ្យាស្ថានជាតិអប់រំ។ "ជាមួយបទពិសោធន៍រយៈពេល៩ឆ្នាំ នាងខ្ញុំបានដុសខាត់សមត្ថភាពក្នុងវិស័យរបស់ខ្ញុំមកដល់ពេលនេះ។ ការអប់រំ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងដំណើរឆ្ពោះទៅមុខរបស់ខ្ញុំ។



**ហេង ធារី**

គ្រូបង្រៀននៅសាលាបឋមសិក្សាមឿងចារ នៅក្នុងខេត្តតាកែវ។ មានបទពិសោធន៍៨ឆ្នាំក្នុងវិស័យអប់រំ។ ពេលទំនេរនាងខ្ញុំចូលចិត្តស្វែងរកអ្វីដែលថ្មីតាមរយៈការអានសៀវភៅ ស្តាប់វីដេអូ និងស្រាវជ្រាវ។



**គង់ សុគន្ធា**

គ្រូបង្រៀនភាសារបរទេសមុខវិជ្ជាភាសាអង់គ្លេសនៅ សាលារៀនមធ្យមសិក្សាសាធារណៈមួយនៅប្រទេសកម្ពុជា។ ឆ្លងកាត់បទពិសោធធ្វើការងារជាគ្រូបង្រៀន និងជាគ្រូប្រឹក្សាគរុកោសល្យជាច្រើនឆ្នាំ ធ្វើឱ្យនាងខ្ញុំមានចំណូលចិត្តចែករំលែកនូវសំឡេងរបស់ខ្ញុំតាមរយៈការសរសេរ និងអាន។



**អ៊ូ សុខលី**

គ្រូបង្រៀនជាប់កិច្ចសន្យា បង្រៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាមេម៉ៃ ។ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រកសិកម្ម ឯកទេស អភិវឌ្ឍន៍ជនបទ ហើយជាអ្នកនិពន្ធរឿងអប់រំសម្រាប់កុមារ ។ ជាបទពិសោធក្នុងអាជីព ជាគ្រូបង្រៀនជាប់កិច្ចសន្យា បានប្ដេជ្ញាចិត្តជួយកុមារក្រីក្រដែលកង្វះសម្ភារៈសិក្សាជួយសិស្ស រៀនយឺតតាមរយៈក្លឹបសិក្សា ព្រមទាំងចូលរួមជួយកុមារដែលខ្វះភាពកក់ក្ដៅក្នុងគ្រួសារ ផ្ដល់ឱកាសឱ្យកុមារចូលរៀនបានគ្រប់ៗគ្នាដោយមិនមានការរើសអើង ។



**ទ្រី គឹមហ៊ា**

មន្ត្រីសម្របសម្រួលប្រចាំសាលារៀនជំនាន់ថ្មី នៃវិទ្យាល័យសម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ ព្រមទាំងវិទ្យាល័យព្រែកលៀប និងជាគ្រូប្រឹក្សាគរុកោសល្យដែលមានបទពិសោធន៍ និងជំនាញច្បាស់លាស់ក្នុងការគាំទ្រ និងលើកកម្ពស់គុណភាពអប់រំក្នុង កម្មវិធីសាលារៀនជំនាន់ថ្មី (NGS) ដើម្បីគាំទ្រការប្រើប្រាស់បច្ចេកវិទ្យាអប់រំ និងពង្រឹងកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។



**ពាស ចិន្ដាឌួង**

អ្នកអប់រំដែលមានបទពិសោធន៍ជាង ២០ឆ្នាំ ទាំងក្នុងសាលារដ្ឋ និងសាលាឯកជន។ បច្ចុប្បន្ន លោកស្រីបម្រើការងារជាបណ្ណារក្សនៅសាលាបឋមសិក្សាអនុវត្ត ហ៊ុន សែន កំពង់ចាម ដោយដឹកនាំបណ្ណាល័យសាលារៀនជំនាន់ថ្មី (NGS) ដំបូងគេបង្អស់ ដែលជាគំរូដើមសម្រាប់បណ្ណាល័យសាលារៀនជំនាន់ថ្មីផ្សេងទៀត។ លោកស្រីគឺជាបុគ្គលិកដ៏មានតម្លៃម្នាក់ដែលទទួលបានការគោរព និងស្រឡាញ់យ៉ាងខ្លាំងពីសំណាក់សិស្សានុសិស្សអាណាព្យាបាល ព្រមទាំងសហការី។



**ឡាយ ស្រីណុច**

គ្រូបង្រៀន និងជាប្រធានក្រុមបច្ចេកទេសមុខវិជ្ជាផែនដីវិទ្យា និងបរិស្ថានវិទ្យា ដែលមានបទពិសោធន៍បង្រៀន១០ឆ្នាំ ក្នុងវិស័យអប់រំ។ លើសពីនេះ អ្នកគ្រូជាកម្លាំងចលករមួយយ៉ាងសកម្មក្នុងការជំរុញសកម្មភាពក្លឹបសិក្សា និងដឹកនាំគម្រោងស្រាវជ្រាវនានា (STEM) តាមបែបវិទ្យាសាស្ត្រ សំដៅបណ្ដុះស្មារតីច្នៃប្រឌិត និងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពដល់យុវជនជំនាន់ក្រោយ។



**កប ណាក់**

គ្រូបង្រៀនឯកទេសផែនដី និងបរិស្ថានវិទ្យា ព្រមទាំងជាគ្រូប្រឹក្សាគរុកោសល្យ និងប្រឹក្សាអាជីពនៅសាលារៀនជំនាន់ថ្មី នៃវិទ្យាល័យជាស៊ីម ព្រែកអញ្ចាញ និងជាមន្ត្រីសម្របសម្រួលផ្នែក STEM, CPD និងជាគ្រូបង្គោល AI ថ្នាក់ជាតិ។ លោកគ្រូផ្ដោតសំខាន់លើការអប់រំ STEM តាមរយៈការជំរុញវិធីសាស្ត្រស៊ើបអង្កេត បំណិនសតវត្សទី២១ (4Cs) សកម្មភាពប្រកួតប្រជែងអន្តរជាតិសម្រាប់សិស្ស ព្រមទាំងបាននាំយកនវានុវត្តន៍បច្ចេកវិទ្យា AI មកអនុវត្តដើម្បីលើកកម្ពស់គុណភាពបង្រៀន និងរៀន។



**សឿង វ៉ាន់**

អ្នកអប់រំកម្ពុជាដែលមានបទពិសោធន៍ជាង ៣០ឆ្នាំ ដោយធ្លាប់កាន់តំណែងជាគ្រូបង្រៀនអក្សរសាស្ត្រខ្មែរកម្រិតមធ្យមសិក្សា ទីប្រឹក្សាកម្មវិធីសិក្សា អ្នកសម្របសម្រួល/អ្នកគ្រប់គ្រងគម្រោងជាមួយអង្គការ KAPE និងជាអតីតនាយកវិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដែលជាសាលារៀនជំនាន់ថ្មីដំបូងគេបង្អស់នៅកម្ពុជា។ លោកក៏ជាអ្នកទ្រឹស្ដីឈានមុខគេលើទស្សនវិជ្ជាសាលារៀនជំនាន់ថ្មី និងធ្លាប់បានធ្វើទស្សនកិច្ចសិក្សាស្រាវជ្រាវពីប្រព័ន្ធអប់រំនៅប្រទេសថៃ អូស្ត្រាលី និងសាធារណរដ្ឋកូរ៉េផងដែរ។

## សង្ឃឹមបានជួបអ្នកម្តងទៀត នៅខែ មករា ឆ្នាំ២០២៧



ទំនាក់ទំនង Educational.magazine.combodia@gmail.com

ដេប៉ាតឺម៉ង់ ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD)

NGS
New Generation School

កម្មវិធីសាលារៀនជំនាន់ថ្មី (NGS)

Please, join us on Facebook